**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ឡឹក សាលីន**

**លី ឆោម**

សាស្ត្រាចារ្យណែនាំ ៖

**លោក ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំបាទទាំងពីរនាក់ឈ្មោះ **ឡឹក សាលីន** និង **លី នោម** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី០៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧ - ២០២១។

***សូមធ្វើការថ្លែងអំណរគុណនិងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះលោកអ្នកមានគុណទាំងបួនរបស់យើងខ្ញុំបាទ ៖***

លោកឪពុក **ឡឹក ឡុន** លោកឪពុក **ឯម លី**

អ្នកម្ដាយ **យន សាខុន** អ្នកម្ដាយ **ឆយ សួយ**

ដែលបានបង្កើតនូវរូបយើងខ្ញុំបាទទាំងពីរនាក់អោយស្គាល់ពន្លឺថ្ងៃនិងពិភពលោកដ៏ស្រស់ស្អាតមួយនេះផងដែរ។ ហើយយើងខ្ញុំបាទក៏ពិតមានសេចក្ដីដឹងគុណយ៉ាងក្រៃលែងដែលពុំអាចរកអ្វីមកប្រៀបផ្ទឹមពុំបានដែលលោកអ្នកមានគុណរបស់យើងទាំងបួននាក់ខិតខំពុះពារ តស៊ូលំបាកមិនខ្លាចនឿយហត់និងពន្លឺថ្ងៃ ក្នុងការបង្កើតមុខរបរដើម្បីចិញ្ចឹមរូបយើងខ្ញុំតាំងពីបានកើតចេញពីផ្ទៃរបស់អ្នកម្ដាយរួចមក។ ហើយអ្វីដែលកាន់តែអើបទៀតនោះ គឺលោកទាំងបួនបានបន្តខិតខំអោយរូបយើងខ្ញុំបាទទាំងពីរនាក់បានរៀនបានសូត្រតាំងតែពីថ្នាក់បឋមសិក្សា អនុវិទ្យា

ល័យ វិទ្យាល័យ ហើយក៏បន្តរមកជាហូរហែររហូតដល់ថ្នាក់ឧត្តមសិក្សាទៀតផង។ ហើយពេលនេះរូបយើងខ្ញុំបាទទាំងពីរនាក់ក៏ជិតនិងបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្នុងរយះពេលដ៏ខ្លីខាងមុខនេះផងដែរ។ លទ្ធផលដែលទទួលបាននាពេលកន្លងនិងរួមទាំងការជិតឈានដល់ការបញ្ចប់ថ្នាក់ឧត្តមសិក្សាទាំងអស់នេះហើយ គឺកើតចេញពីកម្លាំងញើសឈាមរបស់លោកអ្នកមានគុណទាំងបួននាក់របស់យើងខ្ញុំបាទក្នុងការតស៊ូជម្នះនូវភាពលំបាកគ្រប់សព្វបែបយ៉ាងដើម្បីអោយកូនៗរបស់លោកបានសម្រេចនូវក្ដីស្រម៉ៃរបស់ខ្លួនទៅពេលអនាគតផងដែរ។

ពិសេសជាងនេះទៅទៀតនោះយើងខ្ញុំបាទទាំងពីរនាក់ក៏សូមធ្វើការថ្លែងអំណរគុណយ៉ាងក្រៃលែងផងដែរដល់លោកគ្រូសាស្ត្រាចារ្យ **ហោ សុត័ណ្ណ** ដែលលោកគ្រូជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំបាទទាំងពីរនាក់យ៉ាងអស់ពីកម្លាំងកាយ កម្លាំងចិត្ត រួមទាំងបានផ្ដល់នូវពុទ្ធិល្អៗ ដំបូន្មានប្រៀនប្រដៅដល់រូបយើងខ្ញុំបាទទាំងពីរនាក់យ៉ាងក្រាស់ក្រែល ដោយរួមទាំងមានតាំងពីការលើកទឹកចិត្តដល់រូបយើងខ្ញុំបាទទាំងពីរនាក់ តាំងតែពីថ្ងៃចាប់ផ្ដើមសរសេររហូតទាល់តែទទួលបាននូវសមទ្ធិផលដ៏វិសេសវិសាសនេះជាស្ថាពរទៀតផងនោះដែរ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ឡឹក សាលីន** និង **លី នោម** ដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញនីតិសាស្រ្ត ជំនាន់ទី២១ នាឆ្នាំសិក្សា ២០១៧ - ២០២១។ ដោយឆ្លងកាត់ការបណ្តុះបណ្តាលអស់រយះពេល ៤ឆ្នាំកន្លងទៅនេះ ដោយមានការបង្ហាត់ និងបង្ហាញយ៉ាងយកចិត្តដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូដែលជាសាស្រ្តាចារ្យ និងក៏មានការជួយណែនាំបន្ថែមពីសំណាក់រៀមច្បងជំនាន់មុនៗផងនោះ ក៏បានធ្វើអោយខ្ញុំបាទមានការយល់ដឹងច្រើនទៅលើជំនាញមួយនេះ។ បើទោះបីជាពេលខ្លះធ្វើអោយយើងខ្ញុំទាំងពីរនាក់មានការជួបប្រទះនូវឧបសគ្គខ្លះៗ នៅក្នុងការសិក្សាយ៉ាងណាក៏ដោយក៏យើងទាំងពីរនាក់មិនបានរាថយក្នុងការក្រេបជញ្ជក់នូវចំណេះដឹងដែលលោកគ្រូ អ្នកគ្រូ ដែលជាសាស្រ្តាចារ្យ និងពីសំណាក់រៀមច្បងមុនៗ ដែលបានព្យាយាមក្នុងការពន្យល់នឹងផ្តល់មកអោយយើងខ្ញុំទាំងពីរនាក់ នូវចំណេះដឹងល្អៗតាំងតែពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្រ្តមួយនេះទៀតផង។

ក្រោយពីបានសិក្សាអស់រយះពេល ០៤ ឆ្នាំកន្លងទៅនេះគឺពួកយើងបានឆ្លងកាត់នូវការបណ្តុះបណ្តាលនូវមុខវិជ្ជាយ៉ាងច្រើនតាំងពីឆ្នាំទីមួយ ដល់ឆ្នាំទីបួន នៃថ្នាក់បរិញ្ញាបត្រមួយនេះ។ ប៉ុន្តែក្រោយការសង្កេតមើលទៅលើសកម្មភាពដោយរួមផ្សំនិងកត្តាចំណង់ចំណូលចិត្តទៅលើការអនុវត្តច្បាប់ព្រហ្មទណ្ឌ យើងខ្ញុំទាំងពីរនាក់គឺពិតមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ ក្រមព្រហ្មទណ្ឌ ម្ល៉េះហើយទើបបានជាយើងជ្រើសយកប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើនដែលមានក្នុងក្រមនេះមកធ្វើជាប្រធានបទស្រាវជ្រាវដើម្បីសម្រាំងចេញជាសារណាដែលជាស្នាដៃមួយថ្មីស្រឡាងមួយសម្រាប់ទុកជាស្នាដៃ ដែលទទួលបានពីលទ្ធផលនៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ក៏ដូចជាទុកសម្រាប់សិស្សប្អូនជំនាន់ក្រោយៗ រួមទាំងមិត្តអ្នកអានផ្សេងទៀតធ្វើការសិក្សាស្វែងយល់បន្ថែមទៅលើស្នាដៃនិងប្រធានបទមួយនេះ។ សម្រាប់ការសិក្សាទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ មួយនេះ គឺពួកយើងទាំងពីរនាក់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើរបៀបនៃការកំណត់អត្ថបទច្បាប់និងការចូលជាធរមាននៃច្បាប់ រួមទាំងរបៀបនៃការកំណត់ទីកន្លែង ឬជាដែនសមត្ថកិច្ចនៃតុលាការកម្ពុជាដើម្បីអនុវត្តបានចំពោះទណ្ឌិតជាជនជាតិខ្មែរ ឬជាជនបរទេស។ ដោយយល់ឃើញបែបនេះហើយទើបបានជាពួកខ្ញុំសម្រេចចិត្តជ្រើសយកប្រធាបបទ " **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** " មកធ្វើជាប្រធានបទដើម្បីសម្រាំងចេញជាសារណាដ៏ល្អមួយ សម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំទាំងពីរនាក់ ក៏ដូចជាទុកសម្រាប់អ្នកសិស្សប្អូនជំនាន់ក្រោយៗ ក៏ដូចជាមិត្តអ្នកអានផ្សេងៗ បានសិក្សាស្រាវជ្រាវបន្ថែមផងដែរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ....................................................................................................១

**ជំពូកទី១**

**ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា**

**១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** .......................................................៦

**១.១ ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ** ..........................................................៧

១.១.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ..............................................៧

១.១.១.១ គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស ..........................................៨

១.១.១.២ គោលការណ៍មិនប្រតិសកម្មចំពោះទោស .............................................១០

១.១.២ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើស និងទោស ..........................................................................................១១

១.១.២.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តិអំពីទោស ........................១២

១.១.២.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស ................................១២

**១.២ ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី** ............................................................១៣

**ជំពូកទី២**

**ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**

**១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងដែនដី** ..............................................................១៥

**១.១ ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា** ...........................................................................................១៥

១.១.១ សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា ..............................................១៦

១.១.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស ..........................................................................................១៩

១.១.៣ ការកម្រិតនៃដែនដី ..........................................................................២០

**១.២ ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ...............................................២១

១.២.១ អំពើណាមួយនៃបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........២២

១.២.២ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា ...................................................២២

១.២.៣ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស ........................................................២៤
១.២.៤ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា ...........................................២៦
១.២.៥ បទល្មើសដែលមានអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាក្រកម្ពុជា ..២៧
**១.៣ ការកំណត់ប្រព្រឹត្តបទល្មើសដោយនីតិបុគ្គល** ........................................................២៩
**២. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា**.........................................................................................២៩
**២.១ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាដោយឈរលើគោលការណ៍សញ្ជាតិ** ......................២៩
២.១.១ ករណីដែលជនល្មើសមានសញ្ជាតិខ្មែរ ..........................................................២៩
២.១.២ ករណីសញ្ជាតិរបស់ជនរងគ្រោះ ..................................................................៣១
២.១.៣ ការធ្វើបណ្ដឹងចោទប្រកាន់ ........................................................................៣១
**២.២ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះបទឧក្រិដ្ឋដែលប្រឆាំងនិងព្រះរាជាណាចក្រកម្ពុជា** ........................................................................................៣២
២.២.១ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា .........................................៣៣
២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ...................................................៣៦
២.២.៣ បទល្មើសក្លែងរូបិយវត្ថុ នឹងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ........................................................................................៣៧
២.២.៤ បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា .........................៣៨
២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ...........................៣៩
**២.៣ ការមិនចោទប្រកាន់ត្រួតគ្នា និងទោស** ........................................................................៤០
**សេចក្ដីសន្និដ្ឋាន** ........................................................................................................៤២
**អនុសាសន៍** ...............................................................................................................៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

បុគ្គលគ្រប់រូបដែលរស់នៅក្នុងសង្គមរមែងតែងមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ជាក់ស្តែងដើម្បីរក្សាអោយមាននូវទំនាក់ទំនងល្អក្នុងសង្គម នោះថ្នាក់ដឹកនាំសង្គមរមែងរិះរកគ្រប់មធ្យោបាយគ្រប់សព្វបែបយ៉ាងដើម្បី ការពារ ធ្វើអោយមានសណ្តាប់ធ្នាប់សាធារណៈទាំងនៅទីប្រជុំជន ក៏ដូចជាជនបទ ដើម្បីបង្ក្រាបអោយបានឬក៏កាត់បន្ថយនូវអំពើចោរកម្មនាសហគមន៍របស់ខ្លួន ដោយធ្វើយ៉ាងណាអោយសង្គមជាតិ ក៏ដូចជាប្រជាជាតិរបស់ខ្លួនស្វែងរកនូវសុខសុភមង្គលមួយបានយ៉ាងពិតប្រាកដ។ ទន្ទឹមនិងការធ្វើអោយមាននូវសុខសុវត្ថិភាពនេះ គឺវិធានច្បាប់ពិតជាដើរតួរយ៉ាងសំខាន់ណាស់នៅក្នុងការបង្ក្រាបនូវអំពើទាំងឡាយដែលតែងបង្កនូវចលាចល និងបង្ករជាអសន្តិសុខគ្រប់សព្វបែបយ៉ាងដល់សង្គមជាតិ។ បើយើងងាកមើលប្រទេសកម្ពុជាយើងវិញក្រោយពីបានឆ្លងកាត់នូវសង្គ្រាមមកជាច្រើនសារ យើងក៏សង្កេតឃើញថា

វិស័យជាច្រើននៅក្នុងប្រទេសកម្ពុជាបានកំពុងតែនិងលូតលាស់យ៉ាងលឿនគួរអោយកត់សម្គាល់ក្រោមការដឹកនាំដ៏ឈ្លាសវៃក្នុងគោលនយោបាយឈ្នះៗ របស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន។ ក្នុងនោះផងដែរយើងក៏សង្កេតឃើញថាវិស័យយុត្តិធម៌គឺបានធ្វើនូវកំណែរទម្រង់របស់ខ្លួនយ៉ាងលឿនគួរអោយកត់សម្គាល់ ដូចដែលយើងបានដឹងស្រាប់មកហើយគឺថា សព្វថ្ងៃនេះគឺយើងបានបង្កើតអោយមាននូវក្រមគោលទាំងបួនរួមមាន ៖ **ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី។** ហើយដោយក្រមទាំងបួនខាងលើនេះហើយត្រូវបានសភាអនុម័តនៅឆ្នាំផ្សេងៗគ្នានៃក្រមនីមួយៗ។ ដោយឡែកបើយើងនិយាយអំពីក្រមព្រហ្មទណ្ឌវិញ គឺថាក្រមនេះត្រូវបាន**ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខានិងបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ នៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ មានចំនួន ៦៧២មាត្រា**។ ក្រមនេះបានចូលជាធរមាននៅរាជធានីភ្នំពេញ ១០ថ្ងៃ ក្រោយពេលប្រកាសឲ្យប្រើ គឺនៅថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ២០ថ្ងៃ ក្រោយពេលប្រកាសឲ្យប្រើនៅទូទាំងប្រទេស គឺនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០៩។ តាមមាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ បទបញ្ញត្តិទូទៅនៃគន្ថីទី១ នៃក្រមព្រហ្មទណ្ឌ ត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រម ចំណែកឯបទបញ្ញាត្តិផ្សេងទៀតត្រូវយកទៅ អនុវត្តក្នុងរយៈពេល ១ឆ្នាំក្រោយការចូលជាធរមាននៃក្រម។ ហេតុដូច្នេះបទបញ្ញត្តិទាំងអស់ នៃក្រមព្រហ្មទណ្ឌត្រូវបានយកមកអនុវត្តនៅទូទាំងប្រទេសកម្ពុជាចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១០ រហូតមកដល់បច្ចុប្បន្ននេះ។ ក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិច្បាប់ដែលចែងអំពីបទល្មើស និងទោសដែលត្រូវអនុវត្តទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹង

ច្បាប់ព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសផ្សេងៗទៀតដែលត្រូវយកមកអនុវត្តទន្ទឹមនឹងគ្នាផងដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីរបបសារពត៌មានជាដើម។ ជារួមច្បាប់ព្រហ្មទណ្ឌរមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវ ចំពោះបទល្មើស។ ហើយបើយើងនិយាយពីសាខានៃនីតិព្រហ្មទណ្ឌវិញ គឺថានីតិព្រហ្មទណ្ឌនេះគឺត្រូវបានគេធ្វើការបែងចែកជា ៣ ប្រភេទរួមមាន ៖ **នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស និង នីតិវិធីព្រហ្មទណ្ឌ។**

ដូចដែលយើងបានដឹងស្រាប់ហើយថា នីតិព្រហ្មទណ្ឌ គឺពិតជាមានភាពទូលំទូលាយណាស់ដែលពាក់ព័ន្ធទៅនឹងរបៀបកំណត់នូវ បទល្មើស ទោស សម្រាប់អនុវត្តទៅលើជនដែលបានប្រព្រឹត្តបទល្មើស ឋានៈនៃចូលរួមប្រព្រឹត្តបទល្មើស ប្រធាននៃបទល្មើស ការកំណត់អំពីបុគ្គលដែលច្បាប់ចាត់ថាបានប្រព្រឹត្តនូវអំពើដែលនាំឲ្យមានទោស នឹងការប្រព្រឹត្តនូវអំពើមួយចំនួនទៀត ប៉ុន្តែច្បាប់កំណត់ថាពុំមានទោសឡើយប្រសិនបើបានបំពេញនូវល័ក្ខខ័ណ្ឌមួយចំនួនដែលច្បាប់បានតម្រូវឲ្យធ្វើ។ ហើយក្រមព្រហ្មទណ្ឌក៏បានកំណត់ផងដែរពីអានុភាពនៃច្បាប់នេះដែលមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស រហូតដល់អាចពន្លាតបានដល់រដ្ឋបរទេសដែលពលរដ្ឋខ្លួនបាននិងកំពុងស្នាក់នៅ រួមទាំងពេលវេលានៃការអនុវត្តច្បាប់នេះ មុននិងក្រោយការចូលជាធរមានទៀតផងដែរ។ ប៉ុន្តែបើទោះបីជានៅក្នុងក្រមព្រហ្មទណ្ឌមានចែងនូវចំណុច ឬទ្រឹស្តីនៃការអនុវត្តជាច្រើនក៏ដោយ ក៏នៅក្នុងបរិបទនៃការស្រាវជ្រាវនេះគឺយើងទាំងពីរនាក់សូមលើកយកតែប្រធានបទស្តីអំពី « **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » មកធ្វើការស្រាវជ្រាវតែប៉ុណ្ណោះ។ ហើយទោះបីជាដឹងថាប្រធានបទមួយនេះក៏ធ្លាប់ត្រូវបានរៀមច្បងជំនាន់មុនៗ បានយកមកធ្វើជាប្រធានបទសិក្សាស្រាវជ្រាវរួចហើយក៏ដោយ ក៏ពួកខ្ញុំបាទយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវបន្ថែមដោយបង្កើតនូវគំនិតថ្មីៗ វិធីសាស្ត្រថ្មីៗដើម្បីជាពុទ្ធិបន្ថែមដល់អ្នកសិក្សាជំនាន់ក្រោយបានអាន និងបានយល់ទៅលើប្រធានបទមួយនេះបន្ថែមទៀតផងដែរ។

ចំណែកឯក្រមនីតិវិធីព្រហ្មទណ្ឌ គឺ**ត្រូវបានសភាអនុម័តកាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧ ហើយក៏ត្រូវបានព្រះមហាក្សត្រទ្រង់ប្រកាសឲអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ក្រោយពីព្រឹទ្ធសភាអនុម័តយល់ព្រម នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ ដោយមាន ៦១២ មាត្រា ដោយចែកជា ១១ គន្ថីរផងដែរ។** នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះផងដែរ គឺមានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាម ដោយហ្មត់ចត់ ដើម្បីកំណត់ឲបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញាត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងក្តីព្រហ្មទណ្ឌផ្សេងៗទៀត កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។ យើងអាចនិយាយបានថាក្រមនីតិវិធីព្រហ្មទណ្ឌគឺ កំណត់នូវវិធាន ឬ ដំណាក់កាល

ទាំងបួននៃនីតិវិធីព្រហ្មទណ្ឌ។ ហើយដែលដំណាក់កាលទាំងបួននោះ រួមមាន ៖

- ដំណាក់ស៊ើបអង្កេត = ធ្វើឡើងដោយនគរបាលយុត្តិធម៌
- ដំណាក់កាលចោទប្រកាន់ = ធ្វើឡើងដោយស្ថាប័នអយ្យការ
- ដំណាក់កាលស៊ើបសួរ = ធ្វើឡើងដោយយុត្តាធិការស៊ើបសួរ
- ដំណាក់កាលជំនុំជម្រះ = ធ្វើឡើងដោយយុត្តាធិការជំនុំជម្រះ។

រីឯនៅក្នុងនីតិព្រហ្មទណ្ឌពិសេស គឺត្រូវបានដាក់ឲ្យប្រើប្រាស់ ឬចូលជាធរមាន ១ ឆ្នាំក្រោយការប្រកាសអោយប្រើនូវនីតិព្រហ្មទណ្ឌទូទៅ។ មានន័យថានៅក្នុងបញ្ញត្តិនៃក្រមព្រហ្មទណ្ឌគឺមាន ៦៧២ មាត្រា ដែលចែកជា ៦ គន្ថី ហើយចំពោះមាត្រា ១ ដល់មាត្រា ១៨២ គឺត្រូវចូលជាធរមានភ្លាមក្រោយពេលប្រកាសឲ្យប្រើ ហើយចាប់ពីមាត្រា ១៨៣ ដល់មាត្រា ៦៧២ គឺត្រូវចូលជាធរមាន ១ឆ្នាំក្រោយក្រោយពេលប្រកាសឲ្យប្រើ លើកលែងតែមាត្រាមួយចំនួនដែលមាននៅក្នុង ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។ ជារួមក្រមព្រហ្មទណ្ឌអាចអនុវត្តពេញលេញ នៅថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១១។ ហើយនីតិព្រហ្មទណ្ឌពិសេសដែលចែងអំពីបទល្មើសនេះ គឺត្រូវបានគេធ្វើការបែកចែកជា ៣ ផ្នែក រួមមាន :

- បទល្មើសប្រឆាំងនឹងបុគ្គល (មាត្រា១៨៣ - មាត្រា ៣៥២)
- បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ (មាត្រា៣៥៣ - មាត្រា៤៣១)
- បទល្មើសប្រឆាំងនឹងជាតិ (មាត្រា៤៣២ - មាត្រា៦៦៧)។

ហើយចំពោះក្រមព្រហ្មទណ្ឌនេះ មានគោលបំណងរក្សានូវសុខសុវត្ថិភាពក៏ដូចជាធ្វើអោយមាននូវស្ថេរភាពសង្គមតាមរយៈការដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តនូវទង្វើដែលផ្ទុយពីច្បាប់។ តែបើទោះបីជាមានអំពើយ៉ាងណាក៏ដោយ បើសិនជាអំពើនោះពុំមានចែងនៅក្នុងច្បាប់ ឬក៏ច្បាប់ចាត់ថាអំពើនោះពុំមែនជាបទល្មើសទេនោះ គឺប្រាកដណាស់ ជនដែលបានបង្កអំពើនោះគឺពុំមានទោសឡើយ។ ម៉្យាងទៀតដើម្បីអាចឲ្យយើងចាត់ទុកបានថាអំពើណាមួយជាបទល្មើសនោះ គឺត្រូវមានចែងនៅក្នុងច្បាប់ហើយ ដាច់ខាតក៏ត្រូវបំពេញអោយបាននូវធាតុផ្សំបទល្មើសទាំង ៣ ទើបគេអាចធ្វើការចោទប្រកាន់ ឬដាក់ទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តនោះបាន ហើយធាតុផ្សំបទល្មើសទាំង ៣ រួមមាន ៖

- ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់
- ធាតុផ្សំសត្យានុម័ត ឬធាតុសំភារះ
- ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ។

យ៉ាងណាមិញនៅក្នុងនីតិព្រហ្មទណ្ឌ ត្រូវបានគេធ្វើការបែងចែកចំណាត់ថ្នាក់នៃបទល្មើសផងដែរ ដោយ

បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។

- **បទឧក្រិដ្ឋ** ៖ បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ ៖
  - ជាទោសដាក់ពន្ធនាគារអស់មួយជីវិត
  - ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ ដល់ក្រោម ឬស្មើនឹង ៣០ ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។
- **បទមជ្ឈិម** ៖ បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ ថ្ងៃ ដល់ក្រោម ឬស្មើនឹង ៥ ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។
- **បទលហុ** ៖ បទល្មើសជាបទលហុ នៅក្នុងករណីដែល ៖
  - អតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ។ ទោសដាក់ពន្ធនាគារអាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។
  - បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

## ២. ចំណោទបញ្ហា

តើអ្វីទៅជាដែនអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា? ហើយថាតើដែនអនុវត្តច្បាប់នេះមានប៉ុន្មានប្រភេទ?អ្វីខ្លះ? ជាការពិតណាស់ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជាសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌដែលមានសិទ្ធ និងមានអនុភាពនៅក្នុងការអនុវត្តទៅលើបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុង និងក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ បានសេចក្តីថា ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមានវិសាលភាពធំធេងណាស់នៅទូទាំងដែនដីនៃរដ្ឋកម្ពុជាដោយអនុវត្តទៅលើគ្រប់ជនល្មើសទាំងអស់មិនថាតែជាជនជាតិខ្មែរ ឬជាជនបរទេសនោះទេ គឺច្បាប់នេះមានសិទ្ធអំណាចគ្រប់ដណ្តប់លើដែនដីជាតិទាំងមូល។ ហើយចំពោះដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនេះផងដែរ គឺត្រូវបានគេចែកជា ២ ប្រភេទធំៗ រួមមាន ៖ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និង ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំចង់ស្វែងយល់បន្ថែមនូវប្រធានបទស្តីអំពី « **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » នេះអោយបានកាន់តែច្រើន និងចង់សិក្សាស្វែងយល់អោយបានកាន់តែច្បាស់នូវដែនអនុវត្តច្បាប់នីមួយៗ និងអោយបានស៊ីជម្រៅល្អិតល្អន់អំពី

ប្រធានបទក៏ដូចជាដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានេះផងដែរ។ ព្រោះថាដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ ទាំងពីរដូចបាននិយាយខាងលើនេះ គឺពិតជាមានលក្ខណៈស្មុគស្មាញ និង បច្ចេកទេសយ៉ាងខ្លាំងដែលទាមទារអោយយើងមានការបកស្រាយយ៉ាងច្រើន និងទាមទារឲ្យយើងស្រាវជ្រាវទាំងបទដ្ឋានគតិយុត្តិជាតិ រួមទាំងបទដ្ឋានគតិយុត្តិអន្តរជាតិផងដែរ។

## ៤.សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្ដីពី « **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » នាំអោយខ្ញុំបាទទាំងពីរនាក់ទទួលបាននូវចំណេះដឹងយ៉ាងច្រើនដែលពាក់ព័ន្ធទៅលើរបៀបអនុវត្ត ក៏ដូចជាសមត្ថកិច្ច និងសិទ្ធអំណាចនៃប្រព័ន្ធតុលាការកម្ពុជានៅពេលដែលមានបទល្មើសណាមួយបានកើតឡើងមិនថាតែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅរដ្ឋក្រៅពីដែនដីនៃប្រទេសកម្ពុជានោះទេ គឺបានសេចក្ដីថាច្បាប់ព្រហ្មទណ្ឌកម្ពុជាមានវិសាលភាពអនុវត្តទៅដល់ដែនដីនៃរដ្ឋបរទេសនៅពេលដែលមានបទល្មើសណាមួយបានកើតឡើង ដោយឈរលើគោលការណ៍សញ្ជាតិ និងបទឧក្រិដ្ឋដោយឡែកមួយចំនួន។ ហើយម៉្យាងទៀតក៏អាចអោយយើងបានស្វែងយល់កាន់តែច្រើនទៅលើពេលវេលានៃការអនុវត្តច្បាប់ព្រហ្មទណ្ឌនេះផងដែរ ដែលពាក់ព័ន្ធបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តនៅមុន ឬក្រោយពីការចូលជាធរមាននៃច្បាប់នេះ។ មានន័យថា បើទោះបីជាបទល្មើសបានកំពុងនិងប្រព្រឹត្ត ឬក៏ធ្វើការចោទប្រកាន់នានា ពីសំណាក់អង្គការអយ្យការ ទាំងដែលបទល្មើសនេះស្ថិតក្រោមអានុភាពនៃច្បាប់ចាស់ ហើយច្បាប់ថ្មីដែលជាក្រមព្រហ្មទណ្ឌយើងនេះពុំបានចែងពីបទល្មើសនោះទេ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្ដន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចហើយទោសដែលចេញអំពីការផ្ដន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។ ទាំងនេះហើយជាអានុភាពនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាមានវិសាលភាពទៅលើ ច្បាប់ព្រហ្មទណ្ឌអន្តរកាលផងនោះដែរ។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ទាក់ទងនិងប្រធានបទនៃការស្រាវជ្រាវស្ដីអំពី « **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » នៅក្នុងចំណុចបន្ទាប់ យើងនឹងធ្វើការបកស្រាយអំពីចំណុចសំខាន់ៗដែលទាក់ទងទៅនឹងប្រធានបទ ដែលមានដូចតទៅ ៖

- **ជំពូកទី ១ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា**
- **ជំពូកទី ២ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**

# ជំពូកទី ១

# ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា

បើកាលណាគេនិយាយពីការអនុវត្តច្បាប់ព្រហ្មទណ្ឌ នោះគេប្រាកដជានឹកឃើញភ្លាមទៅដល់ " **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** " ។ ព្រោះថាដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនេះគឺចែងពីរបៀបនៃការអនុវត្តទៅលើបទល្មើស និង ទោសទាំងឡាយណាដែលបានចូលជាធរមានដោយក្រមនេះ រួមទាំងបទល្មើស និង ទោស ណាខ្លះដែលមិនអាចអនុវត្តបានដោយសារថា បទល្មើស និង ទោស ទាំងនោះបានប្រព្រឹត្តក្រោមអានុភាពនៃច្បាប់ចាស់ហើយដែលក្រមព្រហ្មទណ្ឌកម្ពុជាថ្មីនេះពុំបានចែង ម្ល៉េះហើយអំពើទាំងនោះមិនអាចយកទៅអនុវត្តបានឡើយ។ ក្រមនេះមានអានុភាពអនុវត្តគ្របដណ្តប់លើដែនដីជាតិទាំងមូល ហើយក៏អាចពង្រីកវិសាលភាពរបស់ខ្លួនទៅដល់បរទេសផងដែរ បើកាលណាអំពើទាំងនោះមានការពាក់ព័ន្ធដល់ពលរដ្ឋដែលមានសញ្ជាតិខ្មែរ។ ហើយដែនអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានេះគឺមានចែងយ៉ាងជាក់ច្បាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌគ្រិះ ឬ ច្បាប់សារធាតុនៅក្នុងជំពូកទី២ និងជំពូកទី៣ ចាប់ពីមាត្រា ៩ រហូតដល់ មាត្រា ២៣។

## ១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

ដោយយោងតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានចែងថា ៖ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ហើយត្រូវបានព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើ ត្រូវចូលជាធរមាននៅក្នុងរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឲ្យប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវបានចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ។ ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឲ្យទាន់តាមពេលកំណត់ខាងលើ។ មិនត្រឹមតែប៉ុណ្ណោះ មាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ក៏បានចែងអំពីការចូលជាធរមានផងដែរ ដែលឲ្យយកមកអនុវត្តភ្លាមនូវគន្ថីទី១ ក្រោយពីការចូលជាធរមាន រីឯបទប្បញ្ញត្តិផ្សេងទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេលមួយឆ្នាំ ក្រោយពីការចូលជាធរមាននៃក្រមនេះ។ លើសពីនេះទៅទៀត មាត្រា ៦១២ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរ នៅក្នុង កថាខណ្ឌទី២ ដោយបានចែងថា ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអនុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ។ ដើម្បីយល់ដឹងកាន់តែច្បាស់ថា តើគេអនុវត្តយ៉ាងដូចម្តេច? ហើយច្បាប់ដែលចូលជាធរមានហើយ តើអាចអនុវត្តនៅអតីត

កាលវិញបានដែរ ឬទេ? ដូច្នេះយើងសូមធ្វើការ បកស្រាយដោយចែកចេញជាពីរផ្នែកគឺ ៖ **១.១ ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ និង ១.២ ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី។**

## ១.១ ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ

ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ គឺជាច្បាប់ដែលកំណត់ពី បទល្មើស និង ទោស ដែលត្រូវអនុវត្តទៅលើបទល្មើសដែលបានប្រព្រឹត្ត រួមទាំងល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវរបស់ជនល្មើសនៃអំពើនោះ។ហើយច្បាប់នេះទៀតសោធ គឺមានតាំងពីច្បាប់ព្រហ្មទណ្ឌជាតិ និង ច្បាប់ព្រហ្មទណ្ឌអន្តជាតិ ដែលមានអានុភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយវិធានទូទៅ គឺនៅតែជាគោលការណ៍នៃភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និង គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និង ទោស ដដែល។ ម៉្យាងទៀត ចំពោះច្បាប់ព្រហ្មទណ្ឌគ្រឹះនេះ គេក៏ធ្វើការបែងចែកអោយមានភាពខុសគ្នានូវ ច្បាប់ថ្មីស្រាលជាង ឬ ធ្ងន់ជាងច្បាប់ចាស់ ដែលចែងអំពីបទល្មើស និង ទោស នេះឯង។ ដោយយល់ឃើញនូវអានុភាពនៃច្បាប់ថ្មីនេះហើយទើបយើងសង្កេតឃើញថាមានចែងនូវគោលការណ៍ពីរសំខាន់ៗគឺ **១.១.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និង ១.១.២ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើស និង ទោស។**

### ១.១.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍នេះគឺ ជាគោលការណ៍គ្រឹះនៃក្រមព្រហ្មទណ្ឌ ហើយក៏ជាគោលការណ៍ដែលមានអនុភាពអនុវត្តសម្រាប់តែឆ្ពោះទៅអនាគតប៉ុណ្ណោះ គឺមិនមានអានុភាពអនុវត្តទៅលើអំពើទាំងឡាយណាដែលបានប្រព្រឹត្តនាអតីតកាលនោះទេ។ ហេតុដូច្នេះបានន័យថា យើងមិនអាចយកច្បាប់ព្រហ្មទណ្ឌនេះទៅអនុវត្តចំពោះអំពើដែលបានកើតឡើង រួមទាំងទោសដែលបានប្រកាសឬអនុវត្តមុនច្បាប់នេះចូលជាធរមានបាននោះទេ[1]។ ហើយគោលការណ៍នេះគឺផ្អែកទាំងស្រុងទៅលើគោលកាណ៍នីត្យានុកូលភាពនៃបទល្មើសនិងទោស[2]។

ដោយសារថា គោលការណ៍នេះគឺជាគោលការណ៍គ្រឹះនិងក៏ជាគោលការណ៍ចម្បង ម្ល៉េះហើយរាល់អត្ថបទច្បាប់ព្រហ្មទណ្ឌដែលចែងមកក្នុងការកំណត់ពីបទល្មើស និង ទោស គឺដាច់ខាតត្រូវតែស្របតាមជានិច្ច។

ក្នុងការអនុវត្តនូវគោលកាណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ គឺប្រៀបដូចទៅនឹងនិយមន័យនៃច្បាប់ព្រហ្មទណ្ឌផងដែរ ដោយសារថាគោលការណ៍នេះក៏កំណត់ពីបទល្មើស និង ទោសផងដែរ ហើយគោលកាណ៍នេះរួម

[1] ប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០

[2] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

មាន ៖ **១.១.១.១ គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស និង ១.១.១.២ គោលការណ៍មិនប្រតិសកម្មចំពោះទោស ។**

**១.១.១.១ គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស**

អ្វីទៅជាភាពមិនប្រតិសកម្មទៅលើបទល្មើស? ជាការពិតណាស់ច្បាប់មួយ អាចយកទៅអនុវត្តបានលុះត្រាណាតែអត្ថបទច្បាប់នោះចូលជាធរមាន ១០ថ្ងៃ នៅរាជធានីភ្នំពេញ និងខេត្តកណ្ដាលក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅតាមបណ្ដារខេត្ត ២០ថ្ងៃក្រោយប្រកាសឲ្យប្រើ។ ប៉ុន្តែបើកាលណាអត្ថបទច្បាប់នោះត្រូវបានប្រកាសឲ្យប្រើជាការប្រញាប់ គឺត្រូវតែចូលជាធរមានភ្លាមៗក្រោយថ្ងៃប្រកាសអោយប្រើ[3]។ បើតាមន័យនេះយើងអាចកំណត់បានថា អំពើណាមួយដែលបង្កើតបានជាបទល្មើសអាចយកមកអនុវត្តទៅលើជនល្មើសបាន លុះណាតែអំពើទាំងនោះត្រូវបានប្រព្រឹត្តក្រោយការប្រកាសឲ្យប្រើនៃច្បាប់នេះតែប៉ុណ្ណោះ។ ដូច្នេះយើងមិនអាចយកមកអនុវត្តទៅលើអំពើណាដែលបានបង្ករជាចលាចលដល់សង្គមមុនការប្រកាសអោយប្រើនូវច្បាប់នេះបាននោះឡើយ។

តើអ្វីទៅជាអំពើដែលកើតមុនច្បាប់ថ្មីចូលជាធរមាន? ពិតណាស់អំពើនីមួយៗ តែងតែកើតមានឡើងជារៀងរាល់ថ្ងៃ ហើយជួនកាលអំពើទាំងនោះកើតមានឡើងនៅមុនអត្ថបទច្បាប់ថ្មីចូលជាធរមាន ខ្លះទៀតកើតឡើងនៅថ្ងៃ ចូលជាធរមាន និងខ្លះទៀតកើតឡើងក្រោយ ថ្ងៃចូលជាធរមាននៃច្បាប់ថ្មីៗដែលកំណត់ពីបទល្មើសណាមួយ។ ហេតុនេះអំពើដែលកើតមុនការចូលជាធរមាននៃច្បាប់រួមមាន ៖ **ក. បទល្មើសភ្លាមៗ ខ. បទល្មើសបន្តរជាហូរហែរ គ. បទល្មើសអូសបន្លាយ និង ឃ. បទល្មើសប្រព្រឹត្តជាទម្លាប់ ។**

**ក. បទល្មើសភ្លាមៗ**

បទល្មើសភ្លាមៗ គឺជាបទល្មើសដែលកើតឡើងតែមួយភ្លែត បានន័យថា បទល្មើសដែលកើតមានឡើងក្នុងពេលតែមួយជាមួយនឹងអំពើប្រព្រឹត្ត។ យើងអាចនិយាយបានម៉្យាងទៀតថា ការសម្រេចនូវបទល្មើសភ្លាមៗបានកើតឡើងហើយក៏បញ្ចប់ទៅវិញភ្លាមៗដែរ។

ឧទាហរណ៍ ៖

- **បទឃាតកម្ម** ជាបទល្មើសភ្លាមៗព្រោះថានៅពេលណាដែលជនល្មើសបានប្រើនូវគ្រប់មធ្យោបាយទុច្ចរិតដោយចេតនាទោះជាមានអាវុធក្តី ឬដោយគ្មានអាវុធក្តីដើម្បីផ្តាច់នូវជីវិតរបស់ជនរងគ្រោះ[4]។
- **បទលួច** រាល់អំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុ ផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់

[3] មាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើ នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

[4] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធខ្លួន[5]។

**ខ. បទល្មើសបន្តរជាហូរហែ**

បទល្មើសបន្តរជាហូរហែរ ជាបទល្មើសដែលផ្ទុយពីបទល្មើសភ្លាមៗត្រង់ថា បទល្មើសនេះមានអំពើជាសម្ភារះប្រព្រឹត្តឡើងបន្តរគ្នាជាហូរហែ និង ស៊ីសង្វាក់គ្នាក្នុងពេលវេលា។នេះបានសេចក្តីថា បទល្មើសបន្តជាហូរហែរ ជាបទល្មើសត្រូវបានប្រព្រឹត្តឡើងជាបន្តរបន្ទាប់គ្នាក្នុងរយះពេលមួយដែលបង្ហាញអោយឃើញនូវចេតនាទុច្ចរិតដែលស្ថិតនៅជាដរាប ឬទាមទាររយះពេលជាក់លាក់ណាមួយដើម្បីសម្រេចបទល្មើស។ ឧទាហរណ៍ ៖

- **បទទទួលផលចោរកម្ម** គេចាត់ថាជាបទល្មើសបន្តរជាហូរហែដោយសារអំពើនេះបានកើតឡើងជាបន្តរបន្ទាប់ជាប់គ្នាជារហូតឥតដាច់ពីកន្លែងមួយទៅកន្លែងមួយទៀតដែលទទួលបានតាមរយះអំពើទុច្ចរិតនៃអំពើលួច[6]។
- **បទស្តាប់ ឬថតសំដីឯកជន** ជាបទល្មើសបន្តរជាហូរហែ ដោយសារថាការថតពាក្យសំដីរបស់អ្នកដទៃនេះធ្វើឡើងដោយទាមទារពេលវេលាទោះខ្លី ឬ ច្រើនក៏ដោយដើម្បីសម្រេចឲបាននូវបទល្មើស[7] ។

**គ. បទល្មើសអូសបន្លាយ**

បទល្មើសអូសបន្លាយ ជាបទល្មើសដែលបង្ករគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែគ្មានអាក់ខានក្នុងរយះពេលណាមួយឡើយ។ និយាយម៉្យាងទៀត បទល្មើសអូសបន្លាយ សំដៅដល់បទល្មើសដែលបង្កើតឡើងដោយបណ្តារអំពើជាច្រើនប្រហាក់ប្រហែលគ្នា ដោយអំពើនីមួយៗចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរ។ ហើយអំពើដែលកើតឡើងប្រហាក់ប្រហែលគ្នាជាច្រើននេះ គេចាត់ទុកថាជាបទល្មើសតែមួយ។
ឧទាហរណ៍ ៖

- **បទផិត** ចាត់ថាជាបទល្មើសអូសបន្លាយ ដោយសារថា អំពើផិតក្បត់នេះត្រូវបានធ្វើឡើងម្តងហើយម្តងទៀតជាមួយនិងបុរស ឬ ស្ត្រីក្រៅពីស្វាមី ឬ ភរិយារបស់ខ្លួន[8]។
- **បទកាន់កាប់ ឬ ដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត** ដោយសារថាជននេះបានកាន់កាប់នូវអា

[5] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[6] មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[7] មាត្រា ៣០១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[8] មាត្រា ៧ និង មាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព

វុធតាមខ្លួនដោយគ្មានការអនុញ្ញាតពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនៅក្រៅពីវង្វង់លំនៅឋានរបស់ខ្លួន[9]។

**ឃ. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់**

បទល្មើសប្រភេទនេះ កើតឡើងដោយសារអំពើជាទម្លាប់ម្តងហើយ ម្តងទៀតតាមមធ្យោបាយផ្សេងៗគ្នា តាមរយៈរូបភាព ក៏ដូចជាស្ថានភាព រួមទាំងពេលវេលាផ្សេងៗគ្នាយ៉ាងណាក៏ដោយ បើកាលណាអំពើនេះកើតឡើងចាប់ពី២ដងឡើងទៅនោះបទល្មើសនេះជាបទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ហើយ។ទោះបីជាមានបទល្មើសច្រើនក៏ដោយ បើសិនណាអំពើទាំងនោះត្រូវបានប្រព្រឹត្តផ្សេងៗ ឬដាច់ដោយឡែកពីគ្នា នោះច្បាប់ពុំបានចាត់ទុកថាបទល្មើសនេះប្រព្រឹត្តជាទម្លាប់នោះទេ។

ឧទាហរណ៍ ៖

- **បទរុកកួនខាងផ្លូវភេទ** ចាត់ថាជាបទល្មើសប្រព្រឹត្តជាទម្លាប់ដោយសារថា អំពើដែលបុគ្គលម្នាក់បានរំលោភអំណាចនៃមុខងាររបស់ខ្លួនហើយបានធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដ៏ទៃក្នុងគោលបំណងការអនុគ្រោះខាងផ្លូវភេទ[10]។
- **បទគម្រាមកំហែង** បទល្មើសនេះធ្វើឡើងក្នុងការគម្រាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈឹមប្រឆាំងនឹងបុគ្គល កាលបើការគម្រាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ[11]។

**១.១.១.២ គោលការណ៍មិនប្រតិសកម្មចំពោះទោស**

អ្វីទៅជាភាពមិនប្រតិសកម្មនៃទោស? ជាក់ស្តែងណាស់ទោសមួយអាចយកទៅអនុវត្តចំពោះជនល្មើសបាន លុះត្រាណាទោសនោះមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន នៅពេលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[12]។ នេះបានន័យថា ទោះបីជាមានច្បាប់ចែងយ៉ាងជាក់លាក់ពីបទល្មើសណាមួយក៏ដោយ ក៏ទោសដែលចែងក្នុងច្បាប់នេះមិនអាចយកទៅប្រកាសបានដែរ ដោយសារថា ពុំមានកើតឡើងនូវបទល្មើសពីសំណាក់ប្រធាននៃបទល្មើស ឬនិយាយអោយខ្លីថា ច្បាប់ចែង តែអវត្តមាននៃអំពើល្មើសនោះតុលាការនៅតែមិនអាចប្រកាសទោសនេះបានដដែល។ ហើយបើផ្អែកតាមទ្រឹស្តីនៃគោលការណ៍មិនប្រតិសកម្មនៃបទល្មើស យើងអាចកំណត់ពីគោលការណ៍មិនប្រតិសកម្មនៃទោសបានថា បទល្មើសថ្មីមួយត្រូវបានប្រព្រឹត្តហើយអាចយកមកផ្តន្ទាទោសក្រោមអានុភាពនៃច្បាប់ថ្មីបាន លុះណាតែបទល្មើសនោះត្រូវបានប្រព្រឹត្ត

[9] មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[10] មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[11] មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[12] មាត្រា ៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ក្រោយការចូលជាធរមាននៃអត្ថបទច្បាប់ថ្មីតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ចំពោះទោសណាមួយដែលច្បាប់ចាស់និងថ្មីបានចែងមកដូចគ្នា គ្រាន់តែខុសអប្បបរមា និង អតិបរមា ដែលច្បាប់ចាស់ធ្ងន់ជាង ច្បាប់ថ្មី។ ក្រោយពីការប្រព្រឹត្ត និងត្រូវបានតុលាការសម្រេចផ្តន្ទាទោសទៅលើអំពើទាំងនោះ ហើយទោសដែលប្រកាសនេះគឺធ្ងន់ធ្ងរ ហើយក៏បានចូលជាស្ថាពរដោយសារតែពុំមានការប្តឹងបន្តពីសំណាក់ទណ្ឌិត ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា ឬក៏បុគ្គលដែលពាក់ព័ន្ធផ្សេងទៀត[13]។លុះក្រោយពីបានសម្រេចផ្តន្ទាទោសរួចមក ក្រមព្រហ្មទណ្ឌថ្មីក៏បានចូលជាធរមានហើយក៏បានចែងពីទោសដែលបានប្រកាសទៅលើទណ្ឌិតនោះ ស្រាលជាងច្បាប់ចាស់។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ក្រមព្រហ្មទណ្ឌថ្មីដែលបានចូលជាធរមានក្រោយនេះបានចែងពីករណីនេះផងដែរថា " **ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយ គឺត្រូវតែអនុវត្ត ទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ** " [14]។ នេះបានសេចក្តីថាបើទោះបីជាច្បាប់ថ្មីបានចែងពីទោសដែលប្រកាសនេះស្រាលជាងក៏ដោយ ក៏ទោសនោះនៅតែអនុវត្តក្រោមអានុភាពនៃច្បាប់ចាស់ដដែលទោះបីជាធ្ងន់ធ្ងរជាងច្បាប់ថ្មីយ៉ាងណាក៏ដោយ។ មួយវិញទៀតចំពោះទោសដែលច្បាប់ថ្មីបានចែងមកធ្ងន់ធ្ងរជាងច្បាប់ចាស់ ឬច្បាប់ចាស់ចែងស្រាលជាងច្បាប់ថ្មី តែទោសនេះបានប្រកាសហើយក៏បានចូលជាស្ថាពរមុនការចូលជាធរមាននៃច្បាប់ថ្មី នោះទោសដែលស្រាលនេះ គឺមានអានុភាពអនុវត្តដដែលបើទោះបីជាបទល្មើសនោះធ្ងន់ធ្ងរ និងមានការផ្តន្ទាទោសស្រាលក្រោមអានុភាពនៃច្បាប់ចាស់យ៉ាងណាក៏ដោយ ក៏នៅតែអនុវត្តបានដដែល។ដោយសារថា " **បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ** " [15]។

### ១.១.២ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើស និងទោស

ផ្ទុយពីគោលការណ៍នៃភាពមិនប្រតិសកម្មខាងលើ ក្រមព្រហ្មទណ្ឌថ្មីនេះក៏មានចែងយ៉ាងជាក់ច្បាស់ពីភាពអាចអនុវត្តត្រលប់ឆ្ពោះទៅកាន់អតីតកាល និងការអនុវត្តឆ្ពោះមកកាន់អនាគតកាលពីសំណាក់ច្បាប់ចាស់បានផងដែរ។ដែលភាពអាចអនុវត្តត្រលប់ទៅវិញទៅមកបាននេះហៅថា **គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ** ។ គោលការណ៍នេះ ក៏ជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍ដ៏ទៃទៀតនៃច្បាប់ព្រហ្មទណ្ឌផងដែរ។ហើយគោលការណ៍នេះគឺយើងសិក្សាទៅលើ **១.១.២.១ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិស**

[13] ការចូលជាស្ថាពរនេះ គឺជាការចូលជាស្ថាពរដែលត្រូវគិតតាំងពី ការប្តឹងជំទាស់ ការប្តឹងឧទ្ធរណ៍ ការប្តឹងសារទុក្ខជាដើម
[14] មាត្រា ១០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[15] មាត្រា ១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

**កម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តអំពីទោស និង១.១.២.២ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស ។**

**១.១.២.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តិអំពីទោស**

អ្វីទៅជាការអនុវត្តនូវច្បាប់ព្រហ្មទណ្ឌស្រាលជាង? ពិតណាស់បើសិនជាយើងសួរនូវសំណួរបែបនេះ នោះច្បាស់ណាស់ថាអ្នកច្បាប់ ក៏ដូចជាអ្នកសិក្សាច្បាប់គ្រប់រូប គឺប្រាកដជានឹកឃើញភ្លាមដល់ " **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** " ដែលមានបញ្ញត្តិនៃជំពូកទី ២ គន្លីទី១ ស្តីពីបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ។ ហើយអ្វីដែលពិសេសនោះគេប្រាកដជាយល់ភ្លាមដល់ ភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ តែម្តង។ ដោយភាពប្រតិសកម្មនេះបានបញ្ញត្តិផងដែរថា " **បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសស្រាលជាងត្រូវអនុវត្តភ្លាម** "[16] ។ បទប្បញ្ញត្តិនៃមាត្រានេះ គឺមានគោលបំណងដើម្បីអនុវត្តត្រលប់មកកាន់អតីតកាលវិញចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រោមអានុភាពនៃច្បាប់ចាស់ តែកិច្ចនីតិវិធីទាំងប៉ុន្មានពុំទាន់បានបញ្ចប់នៅឡើយទេ ឬអាចនិយាយបានម៉្យាងថា កិច្ចស៊ើបអង្កេតធ្វើដោយនគរបាលយុត្តិធម៌ កិច្ចចោទប្រកាន់ធ្វើដោយអង្គការអយ្យការ កិច្ចស៊ើបសួរធ្វើដោយចៅក្រមស៊ើបសួរ និងកិច្ចជំនុំជម្រះធ្វើឡើងយុត្តាធិការជំនុំជម្រះ បានបំពេញចប់សព្វគ្រប់អស់ហើយតាំងពីតុលាការជាន់ទាបរហូតដល់តុលាការជាន់ខ្ពស់ គ្រាន់តែសេចក្តីសម្រេចដើម្បីបញ្ជាក់ពីភាពមានពិរុទ្ធរបស់ជនជាប់ចោទពុំទាន់បានចូលជាស្ថាពរនៅឡើយ ដោយសារតែនៅមានការប្តឹងទាស់ ឬជំទាស់ផ្សេងៗដែលមិនអាចអោយតុលាការបញ្ជាក់ជាស្ថាពរបានឡើយពីទង្វើរបស់ជនជាប់ចោទ ក៏ព្រោះតែមាន បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ នឹងបណ្តឹងសារទុក្ខ ជាអាទិ៍ពីសំណាក់ប្រធាននៃបទល្មើស។

ក្រោយពីកិច្ចទាំងនោះពុំទាន់បានចប់សព្វគ្រប់ផងស្រាប់តែលេចវដ្តមាននូវអត្ថបទច្បាប់ថ្មី ហើយក៏ចែងពីបទល្មើសនោះដូចគ្នា គ្រាន់តែច្បាប់ថ្មីនេះមានចែងនូវទោសដែលត្រូវអនុវត្តទៅលើបទល្មើសចាស់នោះស្រាលជាងមុនប៉ុណ្ណោះ។ " **យោងតាមបញ្ហារនេះ គឺគេត្រូវយកក្រមព្រហ្មទណ្ឌថ្មីយើងនេះមកអនុវត្តដោយសារថា បទល្មើសដែលប្រព្រឹត្តក្រោមអានុភាពនៃច្បាប់ចាស់តែពុំទាន់បានចូលជាស្ថាពរនៅឡើយ នោះតុលាការត្រូវយកនូវច្បាប់ថ្មីដែលស្រាលជាងមកអនុវត្ត** " ។ នេះបើយោងតាមការបកស្រាយនៃមាត្រាច្បាប់ខាងលើដែលមានចែង។ ហើយការដែលច្បាប់មានអានុភាពអនុវត្តត្រលប់ទៅកាន់អតីតកាលនេះគេហៅថា គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាង ព្រោះថាយើងយកច្បាប់ថ្មីដែលស្រាលជាងមកអនុវត្តចំពោះបទល្មើសដែលចែងធ្ងន់ធ្ងរជាងនេះក្រោមការប្រព្រឹត្តដែលស្ថិតក្រោមអានុភាពនៃច្បាប់ចាស់។

**១.១.២.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស**

[16] មាត្រា ១០ កថាខណ្ឌទី ១ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

អ្វីជាច្បាប់ដែលលុបចោលបទល្មើស? ហើយក្នុងគោលបំណងអ្វី? បើកាលណាយើងសង្កត់ធ្ងន់ទៅលើសំណួរបែបនេះ គឺវាពិតជារឿងមួយដែលចម្លែកសម្រាប់សាធារណៈជនដែលឃើញនូវសំណួរបែបនេះ ប៉ុន្តែសម្រាប់និស្សិតច្បាប់ អ្នកអនុវត្តច្បាប់ អ្នកប្រកបវិជ្ជាជីវៈច្បាប់ ពិតជាយល់ច្បាស់ពីបញ្ហារនេះជាក់ជាមិនខានឡើយ។ ហើយគេក៏យល់ច្បាស់បន្ថែមទៀតថា អ្វីដែលគួរយកមកអនុវត្ត និងអ្វីដែលមិនគួរអនុវត្តនៅក្រោយការចូលជាធរមាននៃច្បាប់ណាមួយនោះ? ហើយការលុបចោលនូវមាត្រា ច្បាប់ក៏ដូចជា បទប្បញ្ញត្តិច្បាប់ណាមួយនោះ គឺធ្វើឡើងសុទ្ធតែមានហេតុ និង ផល ពីសំណាក់នីតិករជាអាទិ៍។

ក្នុងករណីខាងលើនេះក្រមព្រហ្មទណ្ឌថ្មីយើងក៏បានចែងផងដែរថា " **បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយត្រូវអនុវត្តភ្លាមៗអំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់** "[17]។ ករណីនេះបានបញ្ជាក់ពីការលុបចោលនូវបទល្មើសណាមួយដែលបានប្រព្រឹត្តនៅមុនការចូលជាធរមាននៃច្បាប់ថ្មីនេះ ឬជាបទល្មើសដែលបានប្រព្រឹត្តក្នុងសម័យអន្តរកាល។ ហើយអំពើដែលបង្កើតជាបទល្មើសនេះទៀតសោធ ត្រូវបានអយ្យការបាននិងកំពុងតែធ្វើការចោទប្រកាន់ក្រោយពីបានធ្វើការស៊ើបអង្កេតហើយក្តី ក៏ត្រូវតែបញ្ឈប់ដែរ។ម៉្យាងទៀត បើសិនជាកិច្ចនេះបានឈានដល់ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះហើយក្តីក៏ដោយ ក៏កិច្ចទាំងនោះត្រូវតែបញ្ឈប់ភ្លាមៗផងដែរ។ ដែលនេះហើយជា **អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលលុបចោលនូវបទល្មើស** នេះឯង។ ករណីនេះគឺនិយាយពីអំពើដែលបង្កើតជាបទល្មើស តែពុំទាន់បានសម្រេចហើយត្រូវបានក្រមថ្មីនេះលុបចោល។

បើចំពោះទោសវិញក៏ដូចគ្នាផងដែរថា " **ប្រសិនបើការផ្តន្ទាទោសជាស្ថាពរបានប្រកាសរួចហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្ត ឬត្រូវបញ្ឈប់តែម្តង** " [18] ។ នេះក៏បានសេចក្តីថា ទោសដែលត្រូវបានតុលាការប្រកាសអោយអនុវត្តចំពោះអំពើដែលប្រព្រឹត្តនៅសម័យអន្តរកាល ហើយក្រោយមកបទល្មើសនោះក៏លុបចោល ហេតុនេះទោសដែលតុលាការប្រកាសហើយត្រូវបានចូលជាស្ថាពរដើម្បីអោយទណ្ឌិតអនុវត្ត ឬ ទណ្ឌិតកំពុងតែអនុវត្តតែមិនទាន់បានចប់សព្វគ្រប់ហើយក្តី ក៏ការអនុវត្តចំពោះសេចក្តីសម្រេចរបស់តុលាការនេះគឺត្រូវតែបញ្ឈប់តែម្តង ក្រោមអានុភាពនៃក្រមព្រហ្មទណ្ឌថ្មីយើងនេះ។

## ១.២ ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី

ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី គឺជាច្បាប់ទាំងឡាយណាដែលចែងពីសមត្ថកិច្ចរបស់តុលាការស្ថាប័នតុលាការ កំណត់អំពីបែបបទនៃការចោទប្រកាន់ពីសំណាក់អង្គការអយ្យការ និងដំណើរការនៃនីតិវិធី

[17] មាត្រា ៩ កថាខ័ណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[18] មាត្រា ៩ កថាខ័ណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ដោយរួមទាំងផ្លូវប្តឹងតវ៉ា និងជាចុងក្រោយ គឺជាច្បាប់ដែលបញ្ញត្តិអំពីរបបនៃការអនុវត្តទោស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ជាដើម។ល។

ហើយការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌទម្រង់ ក៏ដូចជា ច្បាប់សារធាតុនេះគឺត្រូវអនុវត្តភ្លាមនៅក្រោយការចូលជាធរមាននៃក្រមថ្មីនេះតែម្តង គឺអនុវត្តភ្លាមៗទៅលើបទល្មើសណាដែលត្រូវបានប្រព្រឹត្តក្រោយការចូលជាធរមាន បើទោះបីជាបទល្មើសដែលប្រព្រឹត្តក្រោមអានុភាពនៃច្បាប់ថ្មីនេះធ្ងន់ធ្ងរជាងច្បាប់អន្តរកាលយ៉ាងណាក៏ដោយ។នេះបានសេចក្តីថា " **ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ** " [19]។

[19] មាត្រា ១១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៦១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

# ជំពូកទី ២
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

នៅក្នុងការកំណត់អំពីការអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងលំហ ក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ដែលចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ គឺបានកំណត់យ៉ាងច្បាស់ដោយចែងចេញជាពីរគឺ **១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងដែនដី និង ២. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។**

## ១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងដែនដី

ជាគោលការណ៍នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគិតរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ[20]។ មានន័យថា ឲ្យតែប្រព្រឹត្តបទល្មើសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺច្បាប់ព្រហ្មទណ្ឌមានអានុភាពអនុវត្តទាំងអស់ មិនថាជនជាតិអ្វីនោះទេ។ ហើយដើម្បីយល់ដឹងកាន់តែច្បាស់យើងសូមធ្វើការបែងចែកជាបីគឺ **១.១ ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ១.២ ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា និង ១.៣ ការកំណត់ប្រព្រឹត្តបទល្មើសដោយនីតិបុគ្គល។**

### ១.១ ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាជាច្បាប់គ្រឹះមួយដែលមានអនុភាពអនុវត្តគ្រប់បទល្មើសទាំងអស់ ឲ្យតែប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឬស្ថានភាពឯទៀតឡើយ។ ដើម្បីដឹងថាទីកន្លែងណាខ្លះ គឺជាដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលច្បាប់កម្ពុជាត្រូវបានយកអនុវត្តនៅពេលមានបទល្មើសកើតឡើង យើងសូមធ្វើការបែងចែកជាបីចំណុចគឺ **១.១.១ សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា ១.១.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស និង១.១.៣ ការកម្រិតនៃដែនដី។**

[20] មាត្រា ១២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

### ១.១.១ សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា

យោងតាមបញ្ញត្តិមាត្រា ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បានចែងថា ៖

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបំពានបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនដីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩[21]។ ហើយតើគេកំណត់ព្រំដែនគោក ដែនអាកាស និងដែនសមុទ្រ យ៉ាងដូចម្តេច? ទើបដឹងថាច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចយកទៅអនុវត្តបាន? ដូច្នេះយើងសូមធ្វើការបង្ហាញដូចខាងក្រោម៖

- **ព្រំប្រទល់ដីគោករបស់ប្រទេសកម្ពុជា** គឺមានព្រំប្រទល់ ខាងជើងជាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតលាវ ខាងកើតនិងខាងត្បូងជាប់ជាមួយ សាធារណរដ្ឋសង្គមនិយមវៀតណាម និងខាងលិចជាប់ជាមួយព្រះរាជាណាចក្រថៃ។
- **ដែនអាកាស** គឺជាការកំណត់មិនដាច់ខាត និងតាមជំនាញសុទ្ធសាធ គឺគេអាចធ្វើការកំណត់កំពស់លំហអាកាសរបស់រដ្ឋត្រឹមចំណុចមួយ ដែលយន្តហោះអាចហោះបាន ហើយត្រឹមចំណុចដែលយន្តហោះមិនអាចហោះបាន ត្រូវចាត់ទុកជាលំហអាកាសវិញ[22]។
- **ដែនសមុទ្រ** គឺជាលំហទឹកល្វឹងល្វើយដែលមានរហូតដល់ទៅ៧៣%គ្របដណ្តប់លើភពផែនដី។ តំបន់ឆ្នេរសមុទ្រកម្ពុជាដែលពោរពេញដោយភាពទាក់ទាញ គឺជាអចលទ្រព្យដែលមិនទាន់មានការអភិវឌ្ឍខ្លាំងក្លានៅឡើយទេ។ ឆ្នេរសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជាមានប្រវែង ៤៤០ គីឡូម៉ែត្រ ដែលលាតសន្ធឹងនៅតាមបណ្តោយនៃឈូងសមុទ្រថៃ ហើយរួមមានខេត្តចំនួន ៤ ដូចជា៖
    - ខេត្តកោះកុង
    - ខេត្តព្រះសីហនុ
    - ខេត្តកំពត
    - និងខេត្តកែប

ការកំណត់ព្រំដែនសមុទ្រដោយអនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ បានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នៅទីក្រុង

[21] មាត្រា ២ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើ នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

[22] នីតិអន្តរជាតិសាធារណៈ រៀបរៀងដោយសាស្ត្រាចារ្យ អ៊ឹង រដ្ឋា

Montego Bay ប្រទេសJamaica។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រនេះបាន កំណត់ដែនសមុទ្រដូចតទៅ៖

- បន្ទាត់មូលដ្ឋាន ជាគោលការណ៍ដើម្បីកំណត់ដែនសមុទ្រ ចាំបាច់ណាស់ត្រូវតែគូសបន្ទាត់មូលដ្ឋាន។ ហើយបន្ទាត់មូលដ្ឋាននេះ គឺជាខ្សែបន្ទាត់ទឹកនាចតាមបណ្តោយឆ្នេរ ដែលគេបង្កើតឡើងសម្រាប់វាស់តំបន់សមុទ្រ។បន្ទាត់មូលដ្ឋាន ត្រូវបានបែងចែកជា២ប្រភេទគឺ បន្ទាត់មូលដ្ឋានធម្មតា និងបន្ទាត់មូលដ្ឋានត្រង់។
  - បន្ទាត់មូលដ្ឋានធម្មតា ជាបន្ទាត់ខ្សែទឹកនាចតាមបណ្តោយឆ្នេរដោយមានបញ្ជាក់នៅក្នុងផែនទីមាត្រដ្ឋានខ្នាតធំហើយទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរ។
  - បន្ទាត់មូលដ្ឋានត្រង់វិញ គឺសំដៅទៅលើបន្ទាត់ដែលប្រើនៅពេលដែលឆ្នេរសុមុទ្ររបស់រដ្ឋណាមួយមានលក្ខណៈមិនត្រង់ស្មើ។ បន្ទាត់នេះត្រូវបានប្រើដើម្បីគូសភ្ជាប់ចំណុចនៅត្រង់មាត់ឆ្នេរ ឆ្នេរជតជ្រៅ កោះ រដ្ឋប្រជុំកោះ ដីដុះ ថ្មប៉ប្រះទឹក និង សមុទ្រ ព្រមទាំងឆកប្រវត្តិសាស្ត្រជាដើម។
- ដែនទឹកផ្ទៃក្នុង គឺជាតំបន់សមុទ្រដែលស្ថិតនៅផ្នែកខាងឆ្នេរសមុទ្ររបស់រដ្ឋ ហើយត្រូវរាប់បញ្ចូល ដូចជា កំពង់ផែ ឆក ពាម ដៃ សមុទ្រ។ល។ រដ្ឋជាប់ឆ្នេរមានសិទ្ធិ និងអធិបតេយ្យភាពពេញលេញក្នុងការគ្រប់គ្រង តំបន់នេះ។ នាវាបរទេសត្រូវសុំការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ មុននឹងឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុង។ លើសពីនេះ ទៅទៀត រដ្ឋជាប់ឆ្នេរអាចប្រើប្រាស់នូវអំណាចយុត្តាធិការទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌទៅលើនាវា បរទេសទាំងឡាយណាដែលធ្វើនាវាចរណ៍ឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុងនេះដោយគ្មានការអនុញ្ញាតិ។
- សមុទ្រដែនដី ត្រូវបានគេចាត់ទុកថាជាតំបន់នៅជាប់ដែនគោក។ ហើយសមុទ្រដែនដីនេះទៀតសោធ គឺជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ ១២ម៉ែល៍សមុទ្រ (ស្មើនឹង ២២គីឡូម៉ែត្រ)។ នៅក្នុងតំបន់នេះរដ្ឋជាប់ឆ្នេរមានអធិបតេយ្យភាពលើដែនទឹក លំហអាកាស បាតសមុទ្រ និងដីក្រោមបាត សមុទ្រ។ អាស្រ័យហេតុនេះហើយ រដ្ឋជាប់ឆ្នេរមានសិទ្ធិទាំងស្រុងក្នុងការធ្វើអាជីវកម្មនៅបាតសមុទ្រ និងក្នុងដីក្រោមបាតសមុទ្រ។ ការធ្វើនាវាចរណ៍របស់នាវាបរទេស នៅក្នុងតំបន់សមុទ្រដែនដី គឺមានកម្រិត។
- តំបន់តភ្ជាប់ ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ២៤ម៉ែល៍ សមុទ្រ។ នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋជាប់ឆ្នេរអាចការពារការបំពានច្បាប់ និងបទប្បញ្ញត្តិស្តីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាលរបស់ខ្លួនបាន។ ម្យ៉ាងវិញទៀត រដ្ឋជាប់ឆ្នេរក៏អាចធ្វើការដាក់

ទោសទៅលើការបំពានច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលកើតឡើងនៅក្នុងតំបន់នេះបាន។

នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋដទៃមានសិទ្ធិក្នុងការធ្វើនាវាចរណ៍ សិទ្ធិក្នុងការហោះពីលើ ប៉ុន្តែពុំមានសិទ្ធិក្នុងការនេសាទ ការទាញយករ៉ែនោះទេ។ ចំណែកឯសិទ្ធិក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ការដាក់ខ្សែកាបវិញ រដ្ឋ ដទៃត្រូវតែមានការព្រមព្រៀងពីរដ្ឋជាប់ឆ្នេរ។

- តំបន់សេដ្ឋកិច្ចផ្តាច់មុខ ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋាន ហើយលាតសន្ធឹងទៅកាន់លំហសមុទ្រមានចម្ងាយ ២០០ម៉ែល៍សមុទ្រ (ស្មើនឹង ៣៧០គីឡូម៉ែត្រ)។ រដ្ឋជាប់ឆ្នេរមានសិទ្ធិពេញលេញ ក្នុងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស ការចាត់ចែងលើធនធានធម្មជាតិរួមមាន ទាំងធនធានធម្មជាតិមាន ជីវិត និងគ្មានជីវិតដែលស្ថិតនៅបាតសមុទ្រ និងដីក្រោមបាតសមុទ្រ។ រដ្ឋជាប់ឆ្នេរត្រូវគោរពសិទ្ធិ និង កាតព្វកិច្ចរបស់រដ្ឋដទៃផងដែរ នៅពេលដែលប្រើប្រាស់សិទ្ធិ និងបំពេញកាតព្វកិច្ចនៅក្នុងតំបន់ សេដ្ឋកិច្ច ផ្តាច់មុខ។

នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋទាំងអស់ទោះជារដ្ឋជាប់ឆ្នេរក៏ដោយ ឬរដ្ឋមិនជាប់ឆ្នេរក៏ដោយ ក៏មានសេរីភាពក្នុងការធ្វើនាវាចរណ៍ ហោះពីខាងលើ ដាក់ខ្សែកាប ដាក់បំពង់បង្ហូរក្រោមសមុទ្រ ព្រមទាំងការប្រើប្រាស់ផ្សេងទៀតដែលស្របតាមច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសេរីភាពទាំងនេះ។

- លំហសមុទ្រអន្តរជាតិ ជាតំបន់សមុទ្រដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ។ គ្រប់បណ្តាប្រទេស ទាំងអស់នៅជុំវិញពិភពលោក មានសេរីភាពក្នុងការប្រើប្រាស់តំបន់លំហសមុទ្រអន្តរជាតិដែលមានដូចជា ការធ្វើនាវាចរណ៍ ការហោះពីលើ ការដាក់បំពង់បង្ហូរ ការដាក់ខ្សែកាប ការនេសាទ ការស្រាវជ្រាវវិទ្យាសាស្ត្រ ជាដើម។ រដ្ឋទាំងអស់ត្រូវឈរលើគោលការណ៍ថែរក្សាសន្តិភាព ក្នុងការប្រើប្រាស់តំបន់លំហសមុទ្រអន្តរជាតិ ហើយការប្រើប្រាស់នូវកំលាំងយោធាត្រូវបានហាមឃាត់។
- ខ្ពង់រាបបាតសមុទ្រ ជាដីនៅបាតសមុទ្រដែលដុះបន្តចេញពីដែនដីគោក។ យោងទៅតាមអនុសញ្ញា Montego Bay នៅឆ្នាំ១៩៨២ ស្តីពីច្បាប់សមុទ្រ បានកំណត់តំបន់ខ្ពង់រាបបាតសមុទ្រ ថាតំបន់ ខ្ពង់រាបបាត សមុទ្ររបស់បណ្តារដ្ឋជាប់ឆ្នេររួមមាន៖ បាតសមុទ្រ និងដីក្រោមបាតសមុទ្រ ដែលស្ថិតនៅហួសពីតំបន់ សមុទ្រដែនដីរបស់រដ្ឋជាប់ឆ្នេរ ដែលជាការពន្លយចេញនៃដែនដីគោករបស់រដ្ឋជាប់ឆ្នេរ ចុះទៅក្នុងទឹកសមុទ្រ រហូតដល់ជំពាំចោតខ្លាំងនៃបាតសមុទ្រ[23]។

ជារួមមក យើងនិយាយបានថាទោះបីជាមានច្បាប់ដែលកំណត់ពីព្រំដែនសមុទ្រក៏ពិតមែនប៉ុន្តែបញ្ហាវិវាទនៅលើដែនសមុទ្រនៅតែកើតមានឡើងជៀសមិនរួចឡើយ។ ហេតុដូច្នេះទើបច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណា

[23] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ

ចក្រកម្ពុជា ឆ្នាំ ២០០៩ បានកំណត់យ៉ាងច្បាស់ដោយរួមបញ្ចូលទាំងលំហអាកាសនិងសមុទ្រដែលមានចំណង ចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

### ១.១.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស

មិនត្រឹមតែកំណត់ត្រឹមទំហំដូចដែលមានចែងក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ឬត្រឹម ដែនគោក ដែនអាកាស និងដែនសមុទ្រប៉ុណ្ណោះទេ ក៏នៅមានទីកន្លែងមួយចំនួនទៀត ដែលកំណត់ថាជាដែនដីនៃព្រះរាជាណាក្រកម្ពុជា ហើយច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាក៏មានអនុភាពអនុវត្តផងដែរ ដែលទីកន្លែងទាំងនោះរួមមាន ស្ថានទូត[24] ឬស្ថានកុងស៊ុល[25] របស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស។ បើយើងក្រលែកទៅមើល **អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១ (Vienna Convention on Diplomatic Relation 1961) នៃប្រការ ២២ បានកំណត់ថា ៖**

១. ទីតាំងនៃបេសកកម្មមិនអាចរំលោភបានឡើយ បណ្តាភ្នាក់ងារនៃរដ្ឋម្ចាស់ផ្ទះមិនអាចចូលក្នុងទីតាំងបេសកម្មរបស់ពួកគេទេ លើកលែងតែមានការយល់ព្រមពីប្រធានបេសកកម្ម។

២. រដ្ឋដែលជាម្ចាស់ផ្ទះ គឺស្ថិតនៅក្រោមកាតព្វកិច្ចពិសេសដើម្បីចាត់វិធានការសមស្របទាំងអស់ដើម្បីការពារបរិវេណនៃបេសកកម្មប្រឆាំងនឹងការឈ្លានពានឬការបំផ្លិចបំផ្លាញណាមួយនិងដើម្បីការពាររាល់ការរំខានដល់សន្តិភាពនៃបេសកកម្មឬការចុះខ្សោយសេចក្តីថ្លៃថ្នូររបស់ខ្លួន។

៣. ទីកន្លែងនៃបេសកកម្ម គ្រឿងសង្ហារឹម និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ពួកគេ និងមធ្យោបាយនៃការដឹកជញ្ជូនបេសកកម្មនឹងមិនមានភាពសុំពីការស្វែងរកភាពចាំបាច់ឯកសារភ្ជាប់ ឬការប្រតិបត្តិឡើយ[26]។

ដូច្នេះ ចំពោះដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនមែនសំដៅយកត្រឹមតែដែនដីដែលយើងបានដឹងនៅក្នុងស្ថានភាពថានៅលើទឹកដីកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែស្ថានទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅឯបរទេសក៏យើងចាត់ទុកថាគឺជាដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ អាស្រ័យហេតុនេះគឺ ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាមានអានុភាពអនុវត្តចំពោះបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងស្ថានទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស។

---

[24] ស្ថានទូត ជាការិយាល័យឬនិវេសនដ្ឋានផ្លូវការរបស់អគ្គរដ្ឋទូតនៅបរទេស។

[25] ស្ថានកុងស៊ុល ជាការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានី ឬទីក្រុងសំខាន់ៗរបស់រដ្ឋមួយទៀតក្នុងគោលបំណងជួយគាំទ្រ និងការពារប្រជាពលរដ្ឋរបស់គេក្នុងការធ្វើដំណើរ និងស្នាក់នៅទីនោះ។

[26] ប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

### ១.១.៣ ការគ្រមិតនៃដែនដី

ទោះបីពុំមានចែងជាក់លាក់នៅក្នុងមាត្រាណាមួយនៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាក៏ដោយ ថាករណីណាខ្លះដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនអាចយកគោលការណ៍ដែនដីអនុវត្តបានក៏ពិតមែន ក៏ច្បាប់អន្តរជាតិបានទទួលស្គាល់នូវអភ័យឯកសិទ្ធិ ចំពោះឯកអគ្គរដ្ឋទូត និងភ្នាក់ងារទូត ព្រមទាំងក្រុមគ្រួសារផងដែរ។ ដោយអភ័យឯកសិទ្ធិមួយនេះគឺ **ត្រូវបានទទួលស្គាល់ដោយអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ១៩៦១** (Vienna Convention on Diplomatic Relation 18 April1961) **ហើយព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន នៅថ្ងៃទី៣១ ខែសីហា ១៩៦៥ និងចូលជាធរមាននៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦៥។** ដោយយើងអាចនិយាយបានថា អភ័យឯកសិទ្ធិ គឺជាមូលហេតុនៃការមិនដាក់ទោស ដោយសារតែស្ថានភាពពិសេសរបស់ចារីនៃបទល្មើសនៅពេលប្រព្រឹត្តបទល្មើសនោះដែលហេតុនាំឲ្យការចោទប្រកាន់ពីបទល្មើស មិនអាចធ្វើទៅបានឡើយ។ ដោយយើងអាចនិយាយបានថា អភ័យឯកសិទ្ធិមួយនេះ គឺទទួលបានមកពីរដ្ឋដែលជាម្ចាស់ផ្ទះ។

**ដោយយោងតាមប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត បានចែងថា ៖**

បុគ្គលនៃភ្នាក់ងារទូត មិនអាចរំលោភបំពានបានឡើយ។ ភ្នាក់ងារទូតមិនទទួលខុសត្រូវចំពោះទម្រង់នៃការចាប់ខ្លួន ឬការឃុំខ្លួនណាមួយឡើយ។ រដ្ឋដែលទទួលបានត្រូវគោរពភ្នាក់ងារទូត និងចាត់វិធានការសមស្របទាំងឡាយដើម្បីការពារការវាយប្រហាររបស់ខ្លួនទៅលើ សេរីភាព ឬសេចក្តីថ្លៃថ្នូរ របស់ភ្នាក់ងារទូត[27]។ ភ្នាក់ងារការទូត គឺជាប្រធានបេសកកម្មឬជាសមាជិកបុគ្គលិកការទូតនៃបេសកកម្ម[28]។

**មួយវិញទៀតប្រការ ៣៧ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត បានចែងថា ៖**

១.សមាជិកគ្រួសារនៃភ្នាក់ងារការទូតដែលបង្កើតជាចំណែកនៃគ្រួសាររបស់គាត់ប្រសិនបើពួកគេមិនមែនជាសញ្ជាតិនៃរដ្ឋទទួលបានសិទ្ធិនិងអភ័យឯកសិទ្ធិដែលមានចែងក្នុងមាត្រា ២៩ ដល់ ៣៦ ។

២. សមាជិកនៃបុគ្គលិករដ្ឋបាលនិងបច្ចេកទេសនៃបេសកកម្មរួមជាមួយសមាជិកនៃក្រុមគ្រួសាររបស់ពួកគេដែលបង្កើតជាចំណែកនៃគ្រួសាររៀងៗខ្លួនប្រសិនបើពួកគេមិនមែនជាសញ្ជាតិឬមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួលបានសិទ្ធិនិងអភ័យឯកសិទ្ធិដែលមានចែងក្នុងមាត្រា ២៩ ដល់ ៣៥ លើកលែងតែអភ័យឯកសិទ្ធិនិងយុត្តាធិការរដ្ឋបាលនៃរដ្ឋទទួលដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ៣១ មិនត្រូវលាតត្រដាងនូវសកម្មភាពដែលបានធ្វើនៅក្រៅមុខងាររបស់ខ្លួនឡើយ ពួកគេក៏នឹងទទួលបានឯកសិទ្ធិដូចមានចែងក្នុងមាត្រា

[27] ប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

[28] ប្រការ ១ ចំណុច (ង) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

៣៦ កថាខណ្ឌទី ១ ទាក់ទងនឹងមាត្រាដែលបាននាំចូលនៅពេលដំឡើងដំបូង។

៣. សមាជិកនៃបុគ្គលិកសេវាកម្មនៃបេសកកម្ម ដែលមិនមែនជាសញ្ជាតិឬមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋដែលទទួលបាននឹងមានអភ័យឯកសិទ្ធិ ទាក់ទងនឹងសកម្មភាពដែលបានអនុវត្តក្នុងពេលបំពេញភារកិច្ចរបស់ពួកគេលើកលែងពន្ធនិងអាករលើវិមានដែលពួកគេទទួលដោយហេតុផល ការងារនិងការលើកលែងរបស់ពួកគេមានចែងក្នុងមាត្រា ៣៣ ។

៤. ការងារក្នុងន័យផ្សេងទៀតពួកគេអាចទទួលបានសិទ្ធិនិងអភ័យឯកសិទ្ធិតែក្នុងកម្រិតដែលទទួលបានដោយរដ្ឋ។ ទោះយ៉ាងណាក៏ដោយរដ្ឋដែលទទួលបានត្រូវតែអនុវត្តយុត្តាធិការរបស់ខ្លួនលើមនុស្សទាំងនោះក្នុងលក្ខណៈមួយដែលមិនធ្វើឱ្យរំខានដល់ការអនុវត្តមុខងាររបស់បេសកកម្ម[29]។ មាត្រាមួយនេះបានបញ្ជាក់យ៉ាងច្បាស់គឺលើកលែងតែពលរដ្ឋដែលជាម្ចាស់នៃរដ្ឋនោះ គឺមិនអាចទទួលបានអភ័យឯកសិទ្ធិឡើយ ដោយហេតុថាពលរដ្ឋដែលមានសញ្ជាតិនៅរដ្ឋនោះគឺត្រូវស្ថិតក្រោមច្បាប់របស់ប្រទេសនោះ។

**ឧទាហរណ៍** ៖ មាននារីម្នាក់ជាជនជាតិខ្មែរបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភ្នាក់ងារទូតប្រទេសបារាំង នៅឯប្រទេសថៃ គឺប្រាកដណាស់នារីដែលជាជនជាតិខ្មែរនោះនឹងទទួលបានអភ័យឯកសិទ្ធិដូចមានចែងក្នុងមាត្រា ៣៧ ខាងលើ តែប្រសិនបើនារីជនជាតិខ្មែរមានសញ្ជាតិថៃផងនោះ គឺមិនទទួលបានអភ័យឯកសិទ្ធិឡើយ ដោយហេតុថា ជនណាដែលមានសញ្ជាតិនៃរដ្ឋណាមួយ គឺត្រូវស្ថិតក្រោមច្បាប់ប្រទេសរដ្ឋមួយនោះ។

## ១.២ ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្រៅពីដែនដីដែលយើងបាននិយាយនៅក្នុងចំណុចខាងលើ ច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្តផងដែរចំពោះទីកន្លែងមួយចំនួន ដែលត្រូវបានចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលមានបទល្មើសបានកើតឡើង។ បទល្មើសមួយចំនួនអាចប្រព្រឹត្តមិនមែននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុងនោះទេ ប៉ុន្តែច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាយើងបានចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជារបស់យើងផងដែរ ដែលនៅក្នុងនោះច្បាប់កម្ពុជាយើងបានចែងកំណត់ថាជាប្រភេទបទល្មើសដែល ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[30] ដោយទីកន្លែងមានដូចជា ៖ **១.២.១ អំពើណាមួយនៃបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ១.២.២ បទល្មើស**

[29] ប្រការ ៣៧ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

[30] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០ (បច្ចុប្បន្នជារដ្ឋមន្ត្រី ក្រសួងយុត្តិធម៌)

**ដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា ១.២.៣ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស ១.២.៤ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា ១.២.៥ បទល្មើសដែលមានអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាក្រកម្ពុជា។**

### ១.២.១ អំពើណាមួយនៃបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

គោលការណ៍របស់ច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា គឺអនុវត្តទៅលើករណីដែលមានធាតុផ្សំទាំងអស់មាននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមានករណីខ្លះ មិនមានធាតុផ្សំទាំងអស់ នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាអាចយកទៅអនុវត្តបានដែរ ដោយចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាក្រកម្ពុជា។

**ដោយយោងតាមមាត្រា១៣ នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ បានចែងថា ៖**

បទល្មើសត្រូវបានចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[31]។

**ឧទាហរណ៍៖** ករណីដែលជនល្មើសបានប្រើមធ្យោបាយដឹកឈើពីព្រះរាជាណាចក្រកម្ពុជាទៅព្រះរាជាណាចក្រថៃតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីយកឈើនោះទៅឲ្យឈ្មួញដែលរងចាំទទួលនៅឯព្រះរាជាណាចក្រថៃ ស្រាប់តែនគរបាលរបស់ព្រះរាជាណាចក្រកម្ពុជាស្រាវជ្រាវពិនិត្យរកឃើញនៅនៅច្រកព្រំដែនអន្តរជាតិក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ មុនពេលឆ្លងទៅព្រះរាជាណាចក្រថៃ។ ហេតុនេះហើយយើងអាចចាត់ទុកថាជាវាបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមមាត្រា ១៣ នៃក្រមព្រហ្មទណ្ឌ។

### ១.២.២ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

វាជាករណីមួយ ដែលច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាមានអនុភាពអនុវត្ត ក្រៅពីដែនគោក ដែនអាកាស និងដែនសមុទ្រ។ **យោងតាមក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤ បានចែងថា៖** ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ[32]។ ពាក្យថានាវាកម្ពុជា គឺសំដៅដល់នាវាទាំងឡាយណាដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានប្រភពមកពីណា ឬផលិតនៅប្រទេសណាក៏ដោយ ឲ្យតែបានចុះបញ្ជីនៅព្រះរាជា

[31] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[32] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ណាចក្រកម្ពុជា គឺយើងអាចនិយាយបានថាជានាវាដែលមានសញ្ជាតិកម្ពុជាហើយ។ រីឯពាក្យថានាវា មានន័យថា ជាអគារសមុទ្រនៃប្រភេទណាមួយក៏ដោយដែលមិនស្ថិតជាប់ជាអចិន្ត្រៃយ៍ទៅនឹងសមុទ្រ រាប់បញ្ចូលទាំងនាវាដែលដើរដោយកម្លាំងថាមពល នាវាមុជទឹក ឬនាវាបណ្ដែតទឹកផ្សេងៗទៀត[33]។

**យោងតាមមាត្រា ៣ នៃច្បាប់ស្ដីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ២០០៥ បានចែងថា ៖**

១. ជនណាម្នាក់ដែលជាជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ប្រសិនបើជននោះប្រព្រឹត្តដោយខុសច្បាប់ និង ដោយចេតនា៖

ក. រឹបអូស ឬ ធ្វើការត្រួតត្រាទៅលើនាវាដោយប្រើហិង្សា ឬ ការគំរាមកំហែង ឬការបំភិតបំភ័យតាមទ្រង់ទ្រាយណាមួយ ឬ

ខ. ប្រព្រឹត្តអំពើហិង្សាទៅលើមនុស្សនៅលើនាវា ប្រសិនបើអំពើនោះអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

គ. បំផ្លាញនាវា ឬ បង្កការខូតខាតដល់នាវា ឬទំនិញរបស់នាវាដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ឃ.ដាក់ ឬ ធ្វើឲ្យមានការដាក់នៅលើនាវា ដោយមធ្យោបាយណាក៏ដោយនូវឧបករណ៍ ឬសារធាតុដែលអាចបំផ្លិចបំផ្លាញដល់នាវានោះ ឬដែលអាចបង្កការខូតខាតដល់នាវា ឬទំនិញរបស់នាវានោះ ដែលធ្វើឲ្យគ្រោះថ្នាក់ ឬអាចធ្វើឲ្យ គ្រោះថ្នាក់ដល់សុវត្ថិភាពណាស់ក្នុងការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ង. បំផ្លាញ ឬធ្វើឲ្យអោយខូតខាតយ៉ាងធ្ងន់ធ្ងរដល់ឧបករណ៍សម្រាប់ការធ្វើនាវាចរណ៍តាមសមុទ្រ ឬ ធ្វើឲ្យរំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការរបស់នាវា ប្រសិនបើទង្វើបែបនោះអាចធ្វើឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ឬ

ច. ផ្ដល់ពត៌មានដែលខ្លួនដឹងថា «មិនពិត» ដែលជាហេតុធ្វើឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ឬ

ឆ. បង្ករបួសស្នាម ឬធ្វើឃាតជនណាម្នាក់ បើអំពើទាំងនោះ មានចំណងទាក់ទងជាមួយនឹងបទល្មើសមួយនៃបទល្មើសទាំងឡាយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក ដល់ ច ដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬប៉ុនប៉ង

[33] មាត្រា ១ នៃច្បាប់ស្ដីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ២០០៥

ប្រព្រឹត្ត។

២. ចាត់ទុកជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយផងដែរ ប្រសិនបើជននោះ ៖

ក. ប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬ

ខ. ជំរុញជនណាម្នាក់ផ្សេងទៀត ឲ្យប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬសមគំនិតជាមួយនឹងជនណាម្នាក់ដែលប្រព្រឹត្តបទល្មើសបែបណាមួយនោះ ឬ

គ. គំរាមកំហែង ដោយមាន ឬ គ្មានលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ជាតិ ក្នុងគោលបំណងបង្ខិតបង្ខំរូបវន្តបុគ្គល ឬនីតិបុគ្គលឲ្យធ្វើឬមិនឲ្យធ្វើអំពើណាមួយ ឲ្យប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ១ វាក្យខ័ណ្ឌ ខ គ និង ង ប្រសិនបើការគំរាមកំហែងនោះអាចធ្វើឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការនាវាចរណ៍របស់នាវានោះ។

ជារួមការចុះបញ្ជីនាវាដើម្បីទទួលបានជានាវាដែលសញ្ជាតិកម្ពុជា គឺមានសុពលភាពកំណត់ជាក់លាក់ដែលហៅថា វិញ្ញាបនបត្រសន្តិសុខនាវា ត្រូវមានសុពលភាព ប្រាំ ឆ្នាំ[34]។ នៅពេលនាវាទាំងឡាយណា ដែលអះអាងថាស្ថិតក្រោមទង់ជាតិកម្ពុជា ឬសញ្ជាតិកម្ពុជា ក្រោយថ្ងៃអស់សុពលភាពនេះ ត្រូវបានចាត់ទុកថាខុសច្បាប់ និង អាចត្រូវបានដាក់ទោសដោយច្បាប់ និងបទបញ្ញត្តិអន្តរជាតិ។

### ១.២.៣ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងច្បាប់ព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឲ្យពិនិត្យមើល ឬឲ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ[35]។ មានន័យថាជាប្រភេទបទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស ប៉ុន្តែតាមអនុភាពនៃកិច្ចព្រមព្រៀងអន្តរជាតិ ឬសន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិនោះ យើងអាចមានសិទ្ធិចូលទៅពិនិត្យមើល ឬក៏អាចត្រូវបានគេស្នើសុំឲ្យយើងជួយអន្តគមន៍ដើម្បីទៅពិនិត្យមើលនៅក្នុងស្ថានភាពនោះ។ ក្នុងករណីប្រសិនបើមានបទល្មើសកើតឡើង នោះប្រាកដណាស់ បទល្មើសនោះគឺស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា។ ដូច្នេះច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាគឺមានអានុភាពអនុវត្តទៅលើករណីនោះ ទោះបីជានាវាបរទេសក៏ដោយ[36]។

---

[34] មាត្រា ៤៨ នៃអនុក្រឹត្យស្តីពី សន្តិសុខនាវា និង សន្តិសុខបបនីយកណ្ឌផែ

[35] មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[36] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០ (បច្ចុប្បន្នជារដ្ឋមន្ត្រី ក្រសួងយុត្តិធម៌)

**ជាក់ស្តែងមាត្រា ២៧ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ បានចែងថា ៖**

**យុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេស**

១. យុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋជាប់ឆ្នេរសមុទ្រមិនគួរយកមកប្រើប្រាស់លើនាវាបរទេស ដែលឆ្លងកាត់ដែនសមុទ្រ ដើម្បីចាប់ខ្លួនជនណាម្នាក់ ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តលើនាវា ក្នុងអំឡុងពេលឆ្លងកាត់ឡើយ លើកលែងតែករណីដូចខាងក្រោម ៖

ក. ប្រសិនបើផលវិបាកនៃបទល្មើសបន្តប៉ះពាល់ដល់រដ្ឋជាប់ឆ្នេរសមុទ្រ។

ខ. ប្រសិនបើបទល្មើសជាប្រភេទបទល្មើសមួយដែលរំខានដល់សន្តិភាពរបស់ប្រទេស ឬសណ្តាប់ធ្នាប់ល្អនៃដែនសមុទ្រ។

គ. ប្រសិនបើមានការស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋានពីសំណាក់ម្ចាស់នាវា ឬភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋមានទង់ជាតិលើនាវា។ ឬ

ឃ. ប្រសិនបើវិធានការនោះចាំបាច់ ដើម្បីបង្ក្រាបការជួញដូរថ្នាំណាកូទិន ឬសាធាតុប៉ះពាល់ផ្លូវចិត្តខុសច្បាប់។

២.បញ្ញត្តិខាងលើមិនប៉ះពាល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងការចាត់វិធានការណាមួយដែលអនុញ្ញាតដោយច្បាប់របស់ខ្លួន ក្នុងគោលបំណងចាប់ខ្លួន ឬស៊ើបអង្កេតលើនាវាដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួន បន្ទាប់ពីនាវាចាកចេញពីផ្ទៃទឹកក្នុង។

៣. ក្នុងករណីដែលចែងក្នុងកថាខណ្ឌ ១ និង ២ ប្រសិនបើប្រធាននាវាស្នើសុំ រដ្ឋជាប់ឆ្នេរ ត្រូវជូនដំណឹងភ្នាក់ងារទូត ឬមន្ត្រីកុងស៊ុលនៃរដ្ឋដែលមានទង់ជាតិលើនាវា មុនពេលចាត់វិធានការណាមួយ និងត្រូវសម្រួលទំនាក់ទំនងរវាងភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលនោះជាមួយនឹងនាវិក។ ក្នុងករណីបន្ទាន់ អាចប្រាស្រ័យទាក់ទងធ្វើការជូនដំណឹង ខណៈពេលកំពុងចាត់វិធានការ។

៤. ក្នុងការពិចារណាថាតើគួរធ្វើការចាប់ខ្លួនឬយ៉ាងណា ឬរបៀបណា អាជ្ញាធរមូលដ្ឋានត្រូវគិតពីផលប្រយោជន៍នៃការធ្វើនាវាចរណ៍។

៥. លើកលែងតែមានចែងក្នុងភាគទី ១២ ឬទាក់ទងនឹងការល្មើសច្បាប់ និងបទបញ្ញត្តិដែលអនុម័តអនុលោមតាមភាគីទី៥ រដ្ឋជាប់ឆ្នេរមិនអាចចាត់វិធានការណាមួយលើនាវាបរទេស ដែលឆ្លងកាត់ដែនសមុទ្រ ដើម្បីចាប់ខ្លួនមនុស្សណាម្នាក់ ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តមុនពេលនាវាចូលក្នុងដែនសមុទ្ររបស់ខ្លួន ប្រសិនបើនាវានោះដែរធ្វើដំណើរពីកំពុងផែ បរទេស គ្រាន់តែឆ្លងកាត់ដែនសមុទ្រ មិនបានចូលក្នុងដែនទឹកខាង

ក្នុងទេ។

### ១.២.៤ បទល្មើសដែលបានកើតឡើងនៅក្នុងអាកាសយានកម្ពុជា

ក្នុងចំណុចនេះគឺជាបទល្មើសដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបទល្មើសប្រព្រឹត្តនៅក្នុងនាវាកម្ពុជាផងដែរ ព្រោះសំដៅដល់គោលការណ៍សញ្ជាតិដូចគ្នា ដោយបានចុះបញ្ជីនៅកម្ពុជាដូចគ្នា។ អាកាសយាន គឺជាយានទាំងឡាយណា ដែលអាចរក្សាទម្របានក្នុងលំហអាកាសដោយបានមកពីផលនៃប្រតិកម្មខ្យល់ក្នុងសម្ពាធបតិយាកាស។ រីឯអាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា មានន័យថា អាកាសយានចុះបញ្ជីនៅប្រទេសណា និងមានសញ្ជាតិជាប្រទេសនោះ បើអាកាសយាននោះចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា គឺមានសញ្ជាតិខ្មែរហើយ។ អាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា និងមានសញ្ជាតិខ្មែរ ហើយក្នុងរយៈពេលដែលការចុះបញ្ជីនោះនៅមានសុពលភាព អាកាសយាននោះពុំមានសិទ្ធិចុះបញ្ជីនៅរដ្ឋណាមួយផ្សេងទៀតបានទេ។ ហើយអាកាសយានដែលបានចុះបញ្ជីនៅរដ្ឋណាមួយរួចហើយ ពុំមានសិទ្ធិចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ក្នុងរយៈពេលដែលនៅក្នុងរដ្ឋផ្សេងនោះមានសុពលភាពនៅឡើយ[37]។

**យោងតាមមាត្រា ១៦ នៃក្រមព្រហ្មទណ្ឌបានចែងថាៈ**

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយាន ដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយានស្ថិតនៅទីណាក៏ដោយ[38]។

**យោងតាម មាត្រា ៤៧ ច្បាប់ស្តីពី អាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា ៖**

ត្រូវចាត់ទុកថាជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ជនណាដែលស្ថិតនៅលើអាកាសយានកំពុងហោះហើរ បានប្រព្រឹត្តអំពើណាមួយដូចខាងក្រោមៈ

- ការចាប់ពង្រត់អាកាសយានដោយប្រើកម្លាំង
- ការគំរាមកំហែង ការបំភិតបំភ័យ ការដណ្តើមកាន់កាប់ត្រួតត្រាអាកាសយាន ឬការរឹបអូស ឬ
- ការប៉ុនប៉ងប្រព្រឹត្តអំពើខាងលើ

អ្នកចូលរួមប្រព្រឹត្ត និងអ្នកសមគំនិតជាមួយដើម្បីប្រព្រឹត្តអំពើខាងលើ ត្រូវចាត់ទុកជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដែរ[39]។

**លើសពីនេះទៅទៀតក្នុងច្បាប់ដដែលនេះ ក្នុងមាត្រា ៤៩ បានចែងថា ៖**

---

[37] មាត្រា ៦ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

[38] មាត្រា ១៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[39] មាត្រា ៤៧ ច្បាប់ស្តីពី អាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ទោសកម្មដែលមានចែងដូចខាងក្រោមនេះ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃតុលាការព្រះរាជាណាចក្រកម្ពុជា ៖

១. ទោសកម្មណាមួយ ឬអំពើផ្សេងទៀត ដែលប្រព្រឹត្តលើអាកាសយានណាមួយ ដែលចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះនៅទីណាក៏ដោយ។

២. ទោសកម្មណាមួយ ឬ អំពើផ្សេងទៀត ដែលបានប្រព្រឹត្តនៅក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីសញ្ជាតិនៃអាកាសយាន។

៣. ទោសកម្មណាមួយ ឬ អំពើផ្សេងទៀត ដែលបានប្រព្រឹត្តនៅលើអាកាសយាន ដែលចុះចតនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជនល្មើសនៅលើអាកាសយាននោះ។

៤. ទោសកម្មណាមួយ ឬ អំពើផ្សេងទៀត ដែលបានប្រព្រឹត្តនៅលើអាកាសយាន ដែលជួលដោយគ្មានក្រុមអាកាសយានិក[40]ទៅឲ្យអ្នកជួល ដែលអ្នកជួលអាកាសយាននោះមានមូលដ្ឋានធ្វើអាជីវកម្ម ឬ ដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍របស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥. ទោសកម្មណាមួយ ឬអំពើផ្សេងទៀត ដែលបានចែងក្នុងអនុសញ្ញានានាស្តីពីសន្តិសុខ ដែលជនល្មើសស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាក្រកម្ពុជា ហើយពុំទាន់បានប្រគល់ខ្លួនស្របតាមមាត្រា ៨ នៃអនុសញ្ញាក្រុងឡាអេ ឬ អនុសញ្ញាម៉ុងតេរ៉េអាល់ ឬប្រគល់ខ្លួនទៅប្រទេសផ្សេងណាមួយដែលបានរៀបរាប់ក្នុងមាត្រា ៤ ចំណុច

ទី ១ នៃអនុសញ្ញាក្រុងឡាអេ ឬ មាត្រា ៥ ចំណុចទី១ នៃអនុសញ្ញាម៉ុងរ៉េអាល់។

ព្រះរាជាណាចក្រកម្ពុជា អាចអនុវត្តយុត្តាធិការបន្ថែមស្របទៅតាមអនុសញ្ញាស្តីពីសន្តិសុខ[41]។

### ១.២.៥ បទល្មើសដែលមានអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

បើទោះបីជាបទឧក្រិដ្ឋ ឬមជ្ឈឹមបានប្រព្រឹត្តនៅឯបរទេស ច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួន ចំពោះអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ឲ្យតែអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនេះបានប្រព្រឹត្តសកម្មភាពជាសម្ភារៈ នៃការផ្តើមគំនិត ឬសមគំនិត នៅលើដែនដីកម្ពុជា ហើយបទល្មើសត្រូវតែផ្តន្ទាទោសដោយច្បាប់កម្ពុជា និងច្បាប់បរទេស ព្រមទាំងអត្ថិភាពនៃបទល្មើសកើតចេញពីសេចក្តីសំរេចស្ថាពរមួយរបស់តុលាការបរទេស។ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត

[40] ក្រុមអាកាសយាននិក គឺជាបញ្ជាការអាកាសយាន និងសមាជិកដទៃទៀតដែលបំពេញភារកិច្ច និងជាប់ពាក់ព័ន្ធក្នុងកិច្ចប្រតិបត្តិការអាកាសយានក្នុងពេលហោះហើរ។

[41] មាត្រា ៤៩ ច្បាប់ស្តីពី អាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលបានប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមត្រូវបានបំពេញ ៖

- បទល្មើសត្រូវផ្តន្ទាទោសស្របតាមច្បាប់កម្ពុជា និងច្បាប់បរទេសផង និង
- អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស[42]។

សម្រាប់ល័ក្ខខ័ណ្ឌទី១នេះ យើងអាចនិយាយបានថា គឺគេមិនសំខាន់លើរឿងឈ្មោះបទល្មើសរបស់ច្បាប់ប្រទេសកម្ពុជាដូចគ្នាទៅនឹងឈ្មោះបទល្មើសតាមច្បាប់របស់បរទេសឡើយ ហើយក៏គេមិនសំដៅទៅលើទោសរបស់ច្បាប់កម្ពុជា ថាដូចគ្នាទៅនឹងច្បាប់បរទេសឬអត់នោះទេ។ ក៏ប៉ុន្តែអ្វីដែលសំខាន់គឺឲ្យតែមានច្បាប់បញ្ញត្តិទុកជាមុនថា អំពើដែលបានប្រព្រឹត្តនោះ គឺជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដូចគ្នា ដែលស្របតាមច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាផង និងបរទេសផង គឺប្រាកដណាស់ថានឹងចូលក្នុងលក្ខខណ្ឌទី១។

សម្រាប់ល័ក្ខខ័ណ្ឌទី២ វិញ អត្ថិភាពស្មើការកើតមាននៃបទល្មើសនេះ គឺបានន័យថា ត្រូវតែមានតុលាការរបស់បរទេស ដែលជននោះបានប្រព្រឹត្តបទល្មើសចេញនូវសេចក្តីសម្រេចគឺអាចជា សាលក្រម ឬសាលដីកា ជាស្ថាពរដើម្បីបញ្ជាក់ថាអំពើដែលបានប្រព្រឹត្តនោះពិតជាកើតមាននូវបទល្មើសស្របតាមច្បាប់ព្រហ្មទណ្ឌនិងត្រូវផ្តន្ទាទោសពិតប្រាកដមែន ទើបអាចបំពេញគ្រប់នូវល័ក្ខខ័ណ្ឌទីពីរបាន[43]។

ដោយយោងតាមប្រសាសន៍របស់ ឯឧត្តម បណ្ឌិត ហ៊ី សោភា ប្រធានតាក់តែងនូវក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បានឲ្យដឹងនូវគោលគំនិតនៃមាត្រាខាងលើថាប្រសិនបើច្បាប់ព្រហ្មទណ្ឌ មិនថែងការពារដល់ប្រជាពលរដ្ឋកម្ពុជានោះទេ ហើយទុកឲ្យច្បាប់បរទេសយកពលរដ្ឋខ្មែរទៅផ្តន្ទាទោស តាមច្បាប់របស់ប្រទេសនោះ វាប្រាកដណាស់ថា ប្រជាពលរដ្ឋកម្ពុជានឹងទទួលរងនូវការលំបាកយ៉ាងខ្លាំងនៅពេលដែលប្រទេសខ្លួនមិនគិតគូរដល់ពួកគេ។ ករណីដូចជា ប្រជាពលរដ្ឋកម្ពុជាប្រព្រឹត្តបទល្មើសស្របតាមច្បាប់របស់បរទេសដាក់គុកច្រើនជាងច្បាប់កម្ពុជា ឬក៏ច្បាប់បរទេសពិន័យច្រើនជាងច្បាប់កម្ពុជា។ ហេតុនេះបើយើងឲ្យច្បាប់កម្ពុជាមានអនុភាពទៅយកពួកគាត់មកផ្តន្ទាទោស ដូច្នេះប្រជាជនកម្ពុជានឹងទទួលរងផ្តន្ទាទោសស្រាលជាងច្បាប់របស់បរទេស គឺមានន័យថាស្មើនឹងកម្ពុជាពិតជាគិតគូរដល់ប្រជាជនរបស់ខ្លួនខ្លាំងមែនទែន។ យើងអាចនិយាយបានថា មានតែប្រជាជនរបស់ខ្លួននោះទេ ទើបយល់ដឹងច្បាស់ពីទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ដំបររបស់ព្រះរាជាណាចក្រកម្ពុជារបស់ខ្លួនឯង ជាងបរទេស[44]។

---

[42] មាត្រា ១៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[43] ដកស្រង់ចេញពីសៀវភៅ នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀង និងវាយអត្ថបទដោយ ៖ កៅ សីហា ឆ្នាំ ២០១៣

[44] ដកស្រង់ចេញពីសៀវភៅ នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀង និងវាយអត្ថបទដោយ ៖ កៅ សីហា ឆ្នាំ ២០១៣

### ១.៣ ការកំណត់ប្រព្រឹត្តបទល្មើសដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើស ដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មទទួលរងដោយរូបវន្តបុគ្គល[45]។ នៅពេលដែលនីតិបុគ្គលឯកជនដែលទទួលស្គាល់ដោយច្បាប់រួមមានដូចជា ក្រុមហ៊ុន អង្គការ សមាគម រោងចក្រ... ដោយមានប្រធាន ឬអ្នកតំណាង ឬភ្នាក់ងាររបស់ខ្លួនដែលជារូបវន្តបុគ្គលនោះទៅប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ។ ដូច្នេះនៅពេលដែលចៅក្រមកំណត់ទោសដែលត្រូវទទួលរងលើរូបវន្តបុគ្គលអាចជា ប្រធាន ឬអ្នកតំណាង ឬភ្នាក់ងារ រួចហើយ ក្នុងបទប្បញ្ញត្តិបន្ទាប់នៃបញ្ញត្តិដែលត្រូវផ្តន្ទាទោសចំពោះរូបវន្តបុគ្គល ក៏មានចែងអំពីបទប្បញ្ញត្តិដែលកំណត់ទោសចំពោះនីតិបុគ្គលផងដែរ។ ដោយអនុលោមតាមមាត្រា ៤២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ហេតុនេះត្រូវមានទោសដូចរូបវន្តបុគ្គលដែរ ហើយត្រូវដាក់ឈ្មោះបទល្មើសដូចគ្នាតែម្តង។

## ២. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្រៅពីអំពីបញ្ហាអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាក៏បានចែងអំពីសមត្ថកិច្ច ឬក៏អានុភាពអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដូច្នេះយើងសូមធ្វើការបែងចែងជាបីចំណុចគឺ ៖ **២.១ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាដោយឈរលើគោលការណ៍សញ្ជាតិ ២.២ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះបទឧក្រិដ្ឋដែលប្រឆាំងនិងព្រះរាជាណាចក្រកម្ពុជា និង ២.៣ ការមិនចោទប្រកាន់ត្រួតគ្នា និងទោស។**

### ២.១ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាដោយឈរលើគោលការណ៍សញ្ជាតិ

#### ២.១.១ ករណីដែលជនល្មើសមានសញ្ជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។ បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ[46]។ នេះជាករណីដែលបន្ទាប់ពីខ្លួនបានប្រព្រឹត្តអំពើល្មើសនៅបរទេស ជននោះរត់គេចខ្លួនមកជ្រកកោននៅកម្ពុជា និងទទួលបានសញ្ជាតិខ្មែរ ដោយសង្ឃឹមថាគេចផុតពីទណ្ឌកម្មគ្រប់ប្រភេទ។ បទប្បញ្ញត្តិនេះ គឺបានចែងយ៉ាង

[45] មាត្រា ១៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[46] មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ច្បាស់អំពីជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះ គឺ ចែងចេញទៅតាមប្រភេទនៃបទល្មើសដូចជា ៖ **ចំពោះបទឧក្រិដ្ឋ និង ចំពោះបទមជ្ឈិម។**

- ✓ **ចំពោះបទឧក្រិដ្ឋ**

ជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើជនល្មើសដែលប្រព្រឹត្តបទល្មើសនេះតែម្តង នេះមានន័យថាច្បាប់ព្រហ្មទណ្ឌទណ្ឌកម្ពុជាអាចធ្វើការដាក់ទោសទៅលើជននេះបានផងដែរ។

- ✓ **ចំពោះបទមជ្ឈិម**

ពលរដ្ឋខ្មែរដែលជាជនល្មើសប្រព្រឹត្តនៅក្រៅប្រទេសកម្ពុជាអាចនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌកម្ពុជាបាន គឺទាល់តែបទល្មើសដែលគាត់ប្រព្រឹត្តនោះ ត្រូវបានប្រទេសនោះគេកំណត់ថា គឺជាបទល្មើសហើយត្រូវផ្តន្ទាទោសផងដែរ។ ប្រសិនបើជាប្រទេសនោះគេមិនកំណត់អំពើហ្នឹងថាជាបទល្មើសដែលត្រូវផ្តន្ទាទោសទេនោះ គឺថាករណីនេះច្បាប់ព្រហ្មទណ្ឌកម្ពុជាយើង មិនអាចយកទៅអនុវត្តចំពោះបទល្មើសនេះទេ នេះ ចំពោះករណីបទមជ្ឈិម[47]។

**ឧទាហរណ៍ ៖** បុគ្គលម្នាក់ ជាជនជាតិខ្មែរមានសញ្ជាតិខ្មែរ បានប្រព្រឹត្តបទល្មើសមួយប្រភេទនៅឯក្រៅប្រទេស ហើយបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្ត ច្បាប់ព្រហ្មទណ្ឌកម្ពុជាបានកំណត់ថាជាបទមជ្ឈិម ដូច្នេះបើនៅប្រទេសនោះគេកំណត់ថាបទល្មើសមួយហ្នឹងជាបទមជ្ឈិមដែរ នោះច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងមានអនុភាពអនុវត្តទៅលើបទល្មើសមួយនោះ។ ប្រសិនបើករណីមួយនេះប្រទេសនោះគេចាត់ទុកថាជា បទលហុ គឺប្រាកដណាស់ ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាមិនមានអនុភាពអនុវត្តបានឡើយ។

មិនត្រឹមតែប៉ុណ្ណោះទេ នៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ១៩ នេះ បើតាមការបញ្ជាក់ឲ្យដឹងពីសំណាក់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានតាក់តែងនូវក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បច្ចុប្បន្នជារដ្ឋមន្ត្រីនៃ ក្រសួងយុត្តិធម៌ បានឲ្យដឹងនូវគោលគំនិតនៃកថាខណ្ឌមួយនេះ ដោយមានប្រសាសន៍ថា « **មិនគ្រាន់តែពលរដ្ឋខ្មែរដើមដំបូងនោះទេសូម្បីតែជនបរទេសដែលបានទទួលសញ្ជាតិខ្មែរ គឺបន្ទាប់ពីខ្លួនបានប្រព្រឹត្តបទល្មើស និងត្រូវបានចោទប្រកាន់ ហើយខ្លួនបានសុំចូលសញ្ជាតិខ្មែរដើម្បីក្លាយជាពលរដ្ឋខ្មែរក៏ដោយ ក៏មិនអាចគេចផុតពីសំណាញ់ច្បាប់ព្រហ្មទណ្ឌកម្ពុជានោះឡើយ** » ។ ចំណុចពិសេស គឺនៅត្រង់មូលហេតុថា មានជនបរទេសដែលបានប្រព្រឹត្តបទល្មើសនៅបរទេសរួចហើយ ក៏ស្រាប់តែរត់មករស់នៅក្នុងស្រុកខ្មែរ ក្នុងគោលបំណង

[47] ប្រសាសន៍របស់ ឯកឧត្តម ប៊ុន ហ៊ុន អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០

ដើម្បីគេចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទើបខ្លួនសុំចូលសញ្ជាតិខ្មែរ ឬសុំក្លាយជាពលរដ្ឋខ្មែរ។ ផ្ទុយទៅវិញគឺ មិនមានន័យថា កម្ពុជាមិនមានច្បាប់ដើម្បីផ្តន្ទាទោសដល់ជនខិលខូច ឬកម្ពុជាការពារដល់ជនដែលបានប្រព្រឹត្តបទល្មើសទាំងអស់នោះទេ អាស្រ័យហេតុនេះហើយទើបច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិនូវបទបញ្ញត្តិមួយចំនួននេះឡើង ដើម្បីជាផលប្រយោជន៍មិនចង់ឲដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្លាយទៅជាទីជម្រកនៃមេឧក្រិដ្ឋជនធំៗ នៅលើពិភពលោក ដែលបានប្រព្រឹត្តបទល្មើសនៅក្រៅប្រទេស រួចហើយចូលមកប្រទេសកម្ពុជាដែលមានអធិបតេយ្យភាពពេញលេញនេះដោយក្តីសុខសាន្តឡើយ[48]។

### ២.១.២ ករណីសញ្ជាតិរបស់ជនរងគ្រោះ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត[49]។ បទបញ្ញត្តិនេះចែងតែចំពោះបទឧក្រិដ្ឋប៉ុណ្ណោះ គឺមិនមានចែងចំពោះបទមជ្ឈិម ឬលហុនោះទេ។ យើងអាចនិយាយបានថា ប្រសិនបើពលរដ្ឋកម្ពុជាណាម្នាក់ ឬច្រើននាក់ត្រូវបានជនល្មើសប្រព្រឹត្តបទល្មើសដែលជាប្រភេទបទឧក្រិដ្ឋទៅលើពលរដ្ឋខ្មែរណាម្នាក់ ឬច្រើននាក់ នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជនល្មើសនោះគឺជាពលរដ្ឋខ្មែរ ឬក៏មិនមែនជាខ្មែរក៏ដោយ គឺថាច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអនុភាពអនុវត្តទៅលើបទល្មើសមួយនោះផងដែរ[50]។ ប៉ុន្តែបើសិនជាប្រព្រឹត្តបទមជ្ឈិម ឬបទលហុ គឺនៅក្នុងច្បាប់កម្ពុជាមិនមានចែងនោះទេ ដូច្នេះច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនមានអនុភាពអនុវត្តនោះទេ ព្រោះវាជាសមត្ថកិច្ចរបស់ប្រទេសដែលមានពលរដ្ឋកម្ពុជាជាជនរងគ្រោះ ដែលកំពុងរស់នៅក្នុងប្រទេសនោះ។ សរុបមកវិញយើងអាចនិយាយបានថា ទាក់ទងនិងសញ្ជាតិជនរងគ្រោះដែលជាពលរដ្ឋខ្មែរនេះ គឺមានតែសម្រាប់តែបទឧក្រិដ្ឋតែប៉ុណ្ណោះ នៅពេលដែលបទឧក្រិដ្ឋមួយនេះបានប្រព្រឹត្តនៅឯក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយមានពលរដ្ឋខ្មែរជាជនរងគ្រោះ។

### ២.១.៣ ការធ្វើបណ្តឹងចោទប្រកាន់

ទាក់ទងទៅនឹងបទបញ្ញត្តិ បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយជនជាតិខ្មែរ និងជនរងគ្រោះជាជនជាតិខ្មែរ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ។ ការចោទប្រកាន់ត្រូវតែមានប

[48] ដកស្រង់ចេញពីសៀវភៅ នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀង និងវាយអត្ថបទដោយ ៖ កៅ សីហា ឆ្នាំ ២០១៣

[49] មាត្រា ២០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[50] ប្រសាសន៍របស់ ឯកឧត្តម ប៊ុន ហ៊ុន អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០

ណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត[51] ឬបណ្តឹងបរិហារ[52] ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលជាអំពើនោះបានប្រព្រឹត្ត[53]។ ទាក់ទងនឹងបញ្ហានេះ ទោះបីជាគាត់ជាជនល្មើសដែលជាពលរដ្ឋខ្មែរក៏ដោយ ឬក៏ជាជនរងគ្រោះជាពលរដ្ឋខ្មែរក៏ដោយ អាចដំណើរការនីតិវិធីនៃការចោទប្រកាន់បាន ទាល់តែខាងស្ថាប័នអយ្យការជាអ្នកធ្វើការប្តឹងចោទ ហើយការប្តឹងចោទនេះធ្វើទៅបានទាល់តែមានបណ្តឹងអំពីជនរងគ្រោះ ឬពី សិទ្ធិវន្ត ឬក៏មានបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលបានប្រព្រឹត្តអំពើនោះ។ ព្រោះមានតែស្ថាប័នអយ្យការតែប៉ុណ្ណោះដែលអាចធ្វើចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[54]។ មិនត្រឹមតែប៉ុណ្ណោះ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុខនឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[55]។ នេះជាលក្ខខណ្ឌនៃដំណើការនីតិវិធី ប្រសិនបើមិនមានការប្តឹងដូចលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនេះទេ គឺមិនអាចដំណើរការនីតិវិធីបាននោះទេ។

## ២.២ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះបទឧក្រិដ្ឋដែលប្រឆាំងនិងព្រះរាជាណាចក្រកម្ពុជា

ក្រៅពីបទល្មើសដែលត្រូវបានកំណត់សមត្ថកិច្ចដោយឈរលើគោលការណ៍សញ្ជាតិ ក៏មានបទល្មើសព្រហ្មទណ្ឌពិសេសមួយចំនួនទៀត បើទោះបីជាជនល្មើសមានសញ្ជាតិអ្វីក៏ដោយ និងទោះបីជារដ្ឋបរទេសនោះគ្មានច្បាប់កំណត់ថាជាបទល្មើសក៏ដោយ ឱ្យតែបទល្មើសនោះត្រូវបានប្រព្រឹត្ត ហើយដែលច្បាប់កម្ពុជាកំណត់ថាជាបទឧក្រិដ្ឋ នោះគឺតុលាការកម្ពុជាមានសមត្ថកិច្ចតែម្តង។ ជាទូទៅប្រភេទនៃបទល្មើសទាំងនោះ គឺភាគច្រើនពាក់ព័ន្ធនឹងការប្រឆាំង ឬការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ និងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានសមត្ថកិច្ចរបស់តុលាការកម្ពុជា បានតម្រូវឲ្យទទួលស្គាល់ ដោយហេតុថាមានការ

[51] សិទ្ធិវន្ត គឺជាអ្នកមានសិទ្ធិណាមួយ អ្នកមានឧបនិស្ស័យនិងអនុវត្តសិទ្ធណាមួយ

[52] បណ្តឹងបរិហារ គឺជាបណ្តឹងដែលមានគោលបំណងលាតត្រដាងពីអត្ថិភាពនៃបទល្មើសណាមួយ

[53] មាត្រា ២១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[54] មាត្រា ៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

[55] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

បំពានដល់អត្ថប្រយោជន៍នៃជាតិកម្ពុជា។ហើយបទល្មើសទាំងនោះរួមមាន ៖ **២.២.១ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ២.២.៣ បទល្មើសក្លែងរូបិយវត្ថុ នឹងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ២.២.៤ បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា និង ២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា**[56]។

**២.២.១ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា**

បើនិយាយពីបទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា គឺរួមមាន ៖ ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ និង ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ។

- **ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ៖** យោងតាមមាត្រា ៤៣៣ ដល់ ៤៣៨ នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា មិនមានចែងអំពីអំពើបរិហារជេរប្រមាថដល់ព្រះមហាក្សត្រនោះទេ មានតែចែងពីអំពើរំលោភបំពានក្នុងករណីដែលមានការរំលោភបំពានអង្គព្រះមហាក្សត្រ **ប៉ុន្តែនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០៣ ដែលចែងពីមាត្រា ៤៣៧ ស្ទួន គឺនិយាយពី ការប្រមាថអង្គព្រះមហាក្សត្រ។** យោងតាមមាត្រា ៤៣៣ បទរាជឃាតកម្មចែងថា ៖ រាជឃាតកម្ម គឺជាឃាតកម្មចំពោះព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសអស់មួយជីវិត។ ដោយយើងអាចនិយាយបានថា អំពើដែលជនណា ឬជាក្រុមមានការចាត់តាំង[57](ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬដោយឆន្ទៈផ្ទាល់របស់ចារី) ដែលបានប្រព្រឹត្តបទល្មើសត្រូវមានទោសដោយយោងតាមបទបញ្ញត្តិនេះ។ វិធានការណ៍ការពារដល់ព្រះមហាក្សត្រយោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ទោះជាជនដែលប្រព្រឹត្តបទល្មើសនោះ ជាជនដែលចេញពីឋានៈក្សត្រក៏ដោយ ត្រូវតែទទួលទោសនូវអំពើដែលបានប្រព្រឹត្ត។ មាត្រា ៤៣៤ បទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រចែងថា៖ ទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ២០ឆ្នាំ។ មាត្រា ៤៣៥ បទហិង្សាចំពោះអង្គព្រះមហាក្សត្រ ចែងថា ៖ អំពើហិង្សាប្រព្រឹត្តដោយចេនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ។ មាត្រា ៤៣៦ ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ចែងថា ៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំកាលបើអំពើ

[56] មាត្រា ២២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[57] ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន។

នេះនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់អង្គព្រះមហាក្សត្រ។ មាត្រា ៤៣៧ ស្ថានទម្ងន់ទោសដោយសារការចូលទិវង្គត ចែងថា៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ ឆ្នាំទៅ ៣០ ឆ្នាំ កាលបើអំពើនេះ នាំឲ្យមានការចូលទិវង្គតដោយគ្មានចេនានឹងធ្វើឲ្យមានការចូលទិវង្គតទេ។

**ហើយមាត្រា ៧៣៧ (ស្ទួន) បទប្រមាថចំពោះអង្គព្រះមហាក្សត្រ បានចែងថា ៖**

ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល។

ការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងការពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទប្រមាថចំពោះអង្គព្រះមហាក្សត្រ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ ( ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល ) នៃក្រមនេះ។

២. ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ) នៃក្រមនេះ។

៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ។

៤. ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ។

៥. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ ( ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៦. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ ( ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន ) នៃក្រមនេះ។

៧. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន ) នៃក្រមនេះ។

៨. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបកំណត់ដោយមាត្រា ១៨០ ( ការបិទផ្សាយសេចក្តីសម្រេច ) នៃក្រមនេះ។

៩. ការផ្សាយសេចក្តីសម្រេចផ្តន្ទានៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ ( ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍ ) នៃក្រមនេះ។

- **ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ** គឺសំដៅដល់អំពើដូចជា ៖
  - **អំពើក្បត់ជាតិ និងចារកម្ម ៖** កាលបើបទល្មើសប្រព្រឹត្តដោយពលរដ្ឋខ្មែរ ឬដោយយោធិនខ្មែរ និងជាចារកម្មកាលបើបទល្មើសនេះប្រព្រឹត្តដោយបុគ្គលជាជនបរទេសដទៃទៀត[58]។
  - **ឧបឃាត និងការរួមគំនិតក្បត់ ៖** បទឧបឃាត គឺជាការប្រព្រឹត្តអំពើហិង្សាមួយ ឬច្រើន ក្នុងគោលបំណងបង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ[59]។
  - **អំពើរួមគំនិតក្បត់ ៖** គឺជាគម្រោងដែលបង្កើតឡើងដោយមនុស្សច្រើននាក់ដើម្បីប្រព្រឹត្តឧបឃាតកាលបើគម្រោងនេះ ត្រូវបានសម្តែងចេញជារូបរាងច្បាស់លាស់ ដោយអំពើជាក់ស្តែងមួយ ឬច្រើន[60]។
  - **កុបកម្ម ៖** គឺជាអំពើហិង្សាជាសមូហភាព ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ[61]។
  - **ការដណ្តើមយកអំណាចបញ្ជា និងការបង្កើតកងកម្លាំងប្រដាប់អាវុធ ៖** អំពើដណ្តើមយកអំណាចយោធា ជាអំពើដណ្តើមដោយគ្មានសិទ្ធិ ឬ គ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ទៅ ៣០ ឆ្នាំ[62]។

[58] មាត្រា ៤៣៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[59] មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[60] មាត្រា ៤៥៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[61] មាត្រា ៤៥៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[62] មាត្រា ៤៦១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

- **ការផ្តើតកងកម្លាំងប្រដាប់អាវុធ** ជាការគ្មានសិទ្ធិ ឬគ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ទៅ ៣០ ឆ្នាំ[63]។
- **ការប៉ះពាល់ដល់សន្តិសុខនៃកងយោពលខេមរភូមិន្ទ ៖** មានន័យថា ជាការញុះញង់ឲ្យយោធិនចូលបម្រើរដ្ឋបរទេស ឬភ្នាក់ងារបរទេស ឬជាការរារាំងដំណើរការជាធម្មតានៃសម្ភារៈយោធា។
- **ការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ ៖** គឺលក្ខណៈជាការសម្ងាត់នៃការការពារជាតិ គឺព័ត៌មាន វិធី វត្ថុ ឯកសារ សលាកបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យា ដែលការផ្សព្វផ្សាយត្រូវបានកម្រិត[64]។

### ២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា

ត្រាផ្លូវការរបស់ក្រសួង ស្ថាប័ន រដ្ឋអំណាច គ្រប់ជាន់ថ្នាក់ នីមួយត្រូវមានរូបភាពប្រាសាទកំពូលបីជុំវិញរង្វង់ ដែលសរសេរអក្សរឈ្មោះកម្ពុជានៅខាងលើ និងឈ្មោះអង្គភាពនៅខាងក្រោម។ ដោយទណ្ឌកម្មទាក់ទងបទល្មើសក្លែងត្រាមួយនេះ គឺមានចែងដាក់លាក់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជាបច្ចុប្បន្ន តាមបទញ្ញត្តិមាត្រា ៦៦១ បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា បានចែងថា ៖ ការក្លែងបន្លំត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ពីរ ទៅ ប្រាំ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល។ មាត្រា ៦៦២ បទប្រើប្រាស់ត្រាក្លែង បានចែងថា ៖ ការប្រើប្រាស់ត្រាផ្លូវការរបស់ព្រះរាជាណាក្រកម្ពុជាដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ពីរ ឆ្នាំ ទៅ ប្រាំ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០រៀល ទៅ ១០.០០០.០០០ រៀល។ មាត្រា ៦៦៣ បទក្លែងប្រដាសដែលមានក្បាលលិខិតផ្លូវការ បានចែងថា ៖ ការក្លែងបន្លំប្រដាសដែលមានក្បាលលិខិតផ្លូវការប្រើប្រាស់ ដោយអាជ្ញាធរសាធារណៈនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ ខែទៅ មួយឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ មាត្រា ៦៦៤ បទប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ បានចែងថា ៖ ការប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ ខែទៅ មួយឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ មាត្រា ៦៦៥ បទផលិត ជាអាទិ៍ ក្រដាសពុម្ពដែលបង្កើតឲ្យមានការភ័ន្តច្រឡំ បានចែងថា ៖ ការធ្វើ ការលក់ ការចែងចាយ ឬការប្រើប្រាស់ក្រដាស ពុម្ពជាមួយនឹងក្រដាសអាជ្ញាធរសាធារណៈ ដែលមានភាពប្រហាក់ប្រហែលគ្នា ដែលអាចបង្កើតឲ្យមានការភ័ន្តច្រឡំនៅក្នុងស្មារតីរបស់សាធារណជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ ខែទៅ មួយឆ្នាំ និងពិន័យជា

---

[63] មាត្រា ៤៦៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[64] មាត្រា ៤៧៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈឹមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈឹមខាងលើដែរ។

**២.២.៣ បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា**

ពាក្យថា រូបិយវត្ថុ គឺជាអ្វីដែលគេទទួលស្គាល់ជាទូទៅ និងត្រូវបានគេប្រើប្រាស់ដោយផ្ទាល់នៅក្នុងការទិញទំនិញ សេវានានា ឬអាចហៅម្យ៉ាងទៀតថា ជាមធ្យោបាយនៃការចាយវាយទូទាត់បំណុល ដែលត្រូវបានគេទទួលស្គាល់ជាសកល។ រីឯ ធនបត្រជាតិ គឺជា រូបិយវត្ថុដែលប្រើក្នុងព្រះរាជាណាក្រកម្ពុជា ដែលផលិតដោយធនាគារជាតិកម្ពុជា។

ហើយអ្នកដែលក្លែងរូបិយវត្ថុ និងធនបត្រជាតិ ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា យោងតាមមាត្រា ៦៤៥ បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល បានចែងថា ៖

ការក្លែងបន្លំក្រដាសប្រាក់ ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ដប់ប្រាំ ឆ្នាំ ទៅ សាមសិប ឆ្នាំ ឬអស់មួយជីវិត។ មាត្រា ៦៤៦ បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល បានចែងថា ៖ ការក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល ដែលបោះពុម្ពផ្សាយដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ដប់ ឆ្នាំ ទៅ ម្ភៃ ឆ្នាំ ។ មាត្រា ៦៤៧ ការដាក់ឲ្យធ្វើចរាចរណ៍រូបិយវត្ថុ និងរូបិយបណ្ណក្លែង ចែងថា ៖ ការដាក់ឲ្យធ្វើចរាចរណ៍រូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង ៦៤៦ នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ប្រាំ ទៅ ដប់ ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ដប់ ឆ្នាំ ទៅ ម្ភៃ ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង។ មាត្រា ៦៤៨ បទសន្និធិរូបិយវត្ថុ[65] និង រូបិយបណ្ណក្លែង ចែងថា៖ អំពើដឹកជញ្ជូន ឬ សន្និធិរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង ៦៤៦ នៃក្រមនេះ ដើម្បីយកទៅដាក់ឲ្យធ្វើចរាចរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ប្រាំ ទៅ ដប់ ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ដប់ ឆ្នាំ ទៅ ម្ភៃ ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង។ មាត្រា ៦៤៩ បទក្លែងបន្លំរូបិយវត្ថុ និង រូបិយបណ្ណដែលអស់តម្លៃនីត្យានុកូល ចែងថា៖ ការក្លែងបន្លំរូបិយវត្ថុ ឬរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ ឆ្នាំ ទៅ បី ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ រៀល ទៅ ៦.០០០.០០០ រៀល។ មាត្រា ៦៥០ បទកាន់កាប់ដោយខុសច្បាប់នូវសម្ភារៈផលិតរូបិយវត្ថុនិងរូបិយបណ្ណ ចែងថា ៖ ការកាន់កាប់ដោយគ្មានការអនុញ្ញាត នូវ ឧបករណ៍ និងសម្ភារៈដែលជាពិសេស សម្រាប់ធ្វើរូបិយវត្ថុ ឬរូបិយបណ្ណ ត្រូវផ្តន្ទាទោសដាក់

[65] (សំនិធិ ឬ សន្និធិ) ការសន្សំទុក, ការសំចៃទុក ឬការទុកសំចៃ

ពន្ធនាគារពី ប្រាំ ឆ្នាំ ទៅ ដប់ ឆ្នាំ ។ មាត្រា ៦៥១ បទដាក់ឲ្យធ្វើចរាចរណ៍ជាថ្មី នូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង ចែងថា ៖ អំពើរបស់បុគ្គលណាដែលបានទទួលរូបិយវត្ថុ ឬរូបិយបណ្ណ ក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង មាត្រា ៦៤៦ នៃក្រមនេះ ដោយគិត ថាជារូបិយវត្ថុ ឬរូបិយបណ្ណពិត ហើយយកទៅដាក់ឲ្យធ្វើចរាចរណ៍ជាថ្មី ក្រោយពីបានដឹងថាជារបស់ក្លែងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ មួយថ្ងៃ ទៅ ប្រាំមួយ ថ្ងៃ និងពិន័យជា ប្រាក់ពី ១០០ ០០០ រៀល ទៅ ១០ ០០០ ០០០ រៀល។ មាត្រា ៦៥២ ការលើកលែងឲ្យរួចផុតពីទោស ចែងថា៖ បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងក្នុងផ្នែកនេះ នឹង ត្រូវបានលើកលែងឲ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឲ្យបទល្មើសនោះមិនបានសម្រេច និងនាំឲ្យ ដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងៗទៀត ដោយបានឲ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ។

### ២.២.៤ បទល្មើសប្រឆាំងនិងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋនីមួយៗអាចធ្វើទំនាក់ទងការទូតរវាងរដ្ឋរបស់ខ្លួនទៅនឹងរដ្ឋផ្សេងមួយទៀត ដោយមានអ្នកតំណាង របស់ខ្លួនមាននៅក្នុងរដ្ឋមួយនោះ ដើម្បីជាអ្នកការពារផលប្រយោជន៍របស់រដ្ឋ និងកាត់បន្ថយជម្លោះជាដើម។ ភ្នាក់ងារការទូត គឺជាប្រធានបេសកកម្មឬជាសមាជិកបុគ្គលិកការទូតនៃបេសកកម្ម[66]។ មន្ត្រី កុងស៊ុល ជាជន ណាដែលទទួលបន្ទុក បំពេញមុខងារកុងស៊ុលដោយគិតទាំងប្រធានប៉ុស្តិ៍កុងស៊ុលផងដែរ[67]។

**ដោយយោងតាមប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១ បានចែង ថា ៖**

បុគ្គលនៃភ្នាក់ងារការទូតមិនអាចរំលោភបានឡើយ។ គាត់មិនទទួលខុសត្រូវចំពោះទម្រង់នៃការចាប់ ខ្លួនរឺការឃុំខ្លួនណាមួយឡើយ។ រដ្ឋដែលទទួលបានត្រូវគោរពភ្នាក់ងារទូត និងចាត់វិធានការសមស្រប ទាំងឡាយដើម្បីការពារការវាយប្រហាររបស់ខ្លួនទៅលើ សេរីភាព ឬសេចក្តីថ្លៃថ្នូរ របស់ភ្នាក់ងារទូត។

**ចំណែកឯ ប្រការ ៤១ នៃច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនង កុងស៊ុល ឆ្នាំ ២០០៥ ចែងថា ៖ សិទ្ធិមិនត្រូវគេបំពានមន្ត្រីកុងស៊ុល**

១. មន្ត្រីកុងស៊ុលមិនអាចត្រូវចាប់ខ្លួន ឬ ឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោសឡើយលើកលែងតែមានបទ ឧក្រិដ្ឋធ្ងន់ធ្ងរ និងបន្ទាប់ពីមានសេចក្តីសម្រេចណាមួយពីអាជ្ញាធរមានសមត្ថកិច្ចតុលាការ។

២. លើកលែងតែករណីដូចចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះមន្ត្រីកុងស៊ុលមិនអាចត្រូវជាប់ពន្ធនាគារ ឬ នៅ

[66] ប្រការ ១ ចំណុច (ង) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

[67] ប្រការ ១ ចំណុច (ឃ) នៃអនុសញ្ញាស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ២០០៥

ក្រោមរូបភាពណាមួយផ្សេងទៀតនៃការកំរិតសេរីភាពផ្ទាល់ខ្លួនរបស់គេបានឡើយ លើកលែងតែមានការអនុវត្ត នូវសេចក្តីសម្រេចជាស្ថាពររបស់តុលាការ។

៣. កាលណាមានបណ្តឹងព្រហ្មទណ្ឌ ត្រូវដាក់ប្តឹងចោទប្រកាន់ចំពោះមុខមន្ត្រីកុងស៊ុលណាម្នាក់ មន្ត្រីនោះត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។ ក៏ប៉ុន្តែបណ្តឹងនោះត្រូវធ្វើដោយការគោរពដោយសារតួនាទីជាផ្លូវរបស់មន្ត្រីនោះ និងធ្វើឲ្យរំខានតិចបំផុតដល់ការបំពេញមុខងារកុងស៊ុល លើកលែងតែករណីដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ។ ចំពោះបញ្ហាដែលចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ប្រសិនបើមានការចាំបាច់ត្រូវឃុំខ្លួនមន្ត្រីកុងស៊ុលណាម្នាក់ ការប្តឹងចោទប្រកាន់ចំពោះមន្ត្រីនោះត្រូវធ្វើក្នុងរយៈពេលដ៏ខ្លីបំផុត។

### ២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

ទីតាំងនៃបេសកកម្ម គឺជាអាគារឺផ្នែកខ្លះនៃអាគារនិងដីនៅលើដីដោយមិនគិតពីកម្មសិទ្ធិដែលត្រូវបានប្រើសម្រាប់គោលបំណងនៃបេសកកម្មរួមទាំងលំនៅដ្ឋានរបស់ប្រធានបេសកកម្ម[68]។ ចំណែកឯ ទីស្ថានកុងស៊ុល ជាអគារ ឬ បណ្តារផ្នែកនៃអគារ និងផ្ទៃដីបន្តភ្ជាប់ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ដែលត្រូវប្រើប្រាស់ដាច់មុខសម្រាប់ផលប្រយោជន៍របស់ប៉ុស្តិ៍កុងស៊ុល[69]។ ស្ថានកុងស៊ុល ជាការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានី ឬទីក្រុងសំខាន់ៗរបស់រដ្ឋមួយទៀតក្នុងគោលបំណងជួយគាំទ្រ និងការពារប្រជាពលរដ្ឋរបស់គេក្នុងការធ្វើដំណើរ និងស្នាក់នៅទីនោះ។

**តាមប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១ បានចែងថា៖**

១. ទីតាំងនៃបេសកកម្មមិនអាចរំលោភបានឡើយ បណ្តារភ្នាក់ងារនៃរដ្ឋដែលបានទទួលមិនចូលក្នុងទីតាំងបេសកកម្មរបស់ពួកគេទេ លើកលែងតែមានការយល់ព្រមពីប្រធានបេសកកម្ម។

២. រដ្ឋដែលទទួលបានគឺស្ថិតនៅក្រោមកាតព្វកិច្ចពិសេសដើម្បីចាត់វិធានការសមស្របទាំងអស់ដើម្បីការពារបរិវេណនៃបេសកកម្មប្រឆាំងនឹងការឈ្លានពានឬការបំផ្លិចបំផ្លាញណាមួយនិងដើម្បីការពាររាល់ការរំខានដល់សន្តិភាពនៃបេសកកម្មឬការចុះខ្សោយសេចក្តីថ្លៃថ្នូររបស់ខ្លួន។

៣. ទីតាំងនៃបេសកកម្ម គ្រឿងសង្ហារឹមនិងទ្រព្យសម្បត្តិផ្សេងទៀតនិងមធ្យោបាយដឹកជញ្ជូនបេសកកម្មត្រូវតែមានភាពស៊ាំនឹងការរុករកភាពចាំបាច់ឯកសារភ្ជាប់ឬការប្រតិបត្តិ។

**រីឯច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ២០០៥ ប្រការ ៣១ បានចែងថា ៖ សិទ្ធិមិនត្រូវបានគេបំពារបំពាននៃបណ្តាប៉ុស្តិ៍កុងស៊ុល**

[68] ប្រការ ១ ចំណុច (ឈ) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ ១៩៦១

[69] ប្រការ ១ ចំណុច (ញ) ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ២០០៥

១. បណ្ណាទីឋានកុងស៊ុលមិនត្រូវគេបំពានបានក្នុងបែបបទដែលមានចែងក្នុងប្រកាសនេះ។

២. អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងភាគណាមួយនៃប៉ុស្តិ៍កុងស៊ុល ដែលប៉ុស្តិ៍កុងស៊ុលប្រើប្រាស់ដាច់មុខសម្រាប់ការងាររបស់ខ្លួនឡើយ លើកលែងតែមានការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុល ឬពីជនដែលប្រធានប៉ុស្តិ៍កុងស៊ុលបានចាត់តាំង ឬ ពីប្រធានបេសកកម្មទូតនៃរដ្ឋដាក់កុងស៊ុល។ ក៏ប៉ុន្តែការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុលអាចសន្មតថាបានទទួលក្នុងករណីមានអគ្គីភ័យ ឬ មហន្តរាយផ្សេងទៀតដែលតំរូវឲ្យមានវិធានការណ៍ការពារជាបន្ទាន់។

៣.ដោយស្ថិតនៅក្រោម ខ ទាំងឡាយក្នុងកថាខណ្ឌទី២ នៃប្រការនេះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេសក្នុងការចាត់គ្រប់វិធានាការណ៍សមស្រប ដើម្បីការពារទីស្ថានកុងស៊ុលកុំឲ្យមានគេលុកលុយ ឬធ្វើឲ្យខូតខាតនិងដើម្បីកុំឲ្យភាពសុខសាន្តរបស់ប៉ុស្តិ៍កុងស៊ុលត្រូវល្អក់កករ ឬ ក៏ភាពថ្លៃថ្នូររបស់ប៉ុស្តិ៍កុងស៊ុលត្រូវអាប់អោន។

៤. បណ្ណារទីប៉ុស្តិ៍កុងស៊ុលគ្រឿងសង្ហារឹម និងទ្រព្យសម្បត្តិនៃប៉ុស្តិ៍កុងស៊ុល ក៏ដូចជាមធ្យោបាយដឹកជញ្ជូនរបស់ប៉ុស្តិ៍កុងស៊ុល មិនអាចធ្វើជាកម្មវត្ថុនៃកំណែនសម្រាប់កិច្ចការពារជាតិ ឬ ការប្រើប្រាស់ជាសាធារណៈតាមរូបភាពណាមួយឡើង។ បើសិនជាចាំបាច់ត្រូវបានការដកហូតទ្រព្យសម្បត្តិសម្រាប់គោលបំណងនេះ គេត្រូវចាត់វិធានការសមស្រប ដើម្បីជៀសវាងកុំឲ្យមានឧបសគ្គដល់ការបំពេញមុខងារកុងស៊ុល ហើយប្រាក់សំណង នឹងត្រូវបានប្រគល់ជូនទៅរដ្ឋដាក់កុងស៊ុលវិញឲ្យបានរួសរាន់ និងគ្រប់គ្រាន់។

## ២.៣ ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

តាមច្បាប់កម្ពុជា ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះបទល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសដែលត្រូវបានរលត់ដោយអាជ្ញាយុកាល[70] ។ យើងអាចនិយាយបានថាមាត្រានេះគឺមានគោលបំណង និងការការពាររាល់ការចោទប្រកាន់ ពីរដង ឬធ្វើការជំនុំជម្រះពីរដង លើកបទល្មើសតែមួយ ហើយក៏មិនអាចធ្វើការចោទប្រកាន់បានលើអាជ្ញាអស់ជំនុំឡើយ។តុលាការកម្ពុជាពុំអាចបើកសវនាការសារឡើងវិញ ឬក៏សម្រេចផ្តន្ទាទោស និងដាក់ឱ្យអនុវត្តទោសចំពោះ បុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេស ឬបានអនុវត្តទោសរួចរាល់ ឬបានផុតរលត់អាជ្ញាយុកាលដោយយោងតាមច្បាប់បរទេសរួចរាល់បានឡើយ ។

**ដោយយោងតាមមាត្រា ២០ អំពីការជំនុំជំរះតែមួយលើក នៃច្បាប់ស្តីពី លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងថា៖**

[70] មាត្រា ២៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

១. លើកលែងតែមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវបានជំនុំជម្រះដោយតុលាការទាក់ទងលើការប្រព្រឹត្តដែលបានបង្កើតជាមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌដែលជននោះត្រូវបានតុលាការសម្រេចឲ្យមានពិរុទ្ធភាព(ឲ្យមានទោស) ឬ សម្រេចឲ្យរួចខ្លួន(គ្មានទោស) ម្តងរួចទៅហើយនោះទេ។
២. គ្មានជនណាម្នាក់ត្រូវបានជំនុំជម្រះនៅក្នុងតុលាការមួយទៀត ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងមាត្រា៥ ដោយជននោះត្រូវបានតុលាការសម្រេចឲ្យមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួចទៅហើយនោះទេ។
៣. គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជម្រះដោយតុលាការផ្សេងទៀតចំពោះការប្រព្រឹត្តដែលបានពណ៌នាផងដែរនៅក្នុងមាត្រា ៦ ៧ ឬ ៨ ត្រូវជំនុំជម្រះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តដូចគ្នាតែមួយទេ លើកលែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ ៖

ក. ត្រូវបានធ្វើឡើងសម្រាប់គោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សម្រាប់បទល្មើសដែលឋិតនៅក្នុងយុត្តាធិការនៃតុលាការ។ ឬ

ខ. បើមិនអញ្ចឹងទេ ត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬដោយគ្មានភាពឥតលំអៀងស្របតាមបទដ្ឋាននៃដំណើរការត្រឹមត្រូវតាមច្បាប់ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិហើយត្រូវបានធ្វើឡើងតាមរបៀបមួយដែល ក្នុងកាលៈទេសៈនានា មិនស្របតាមចេតនាខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តធម៌[71]។

សរុបមកចំពោះបទល្មើសដែលប្រព្រឹត្តនៅក្រៅប្រទេស តុលាការកម្ពុជាគឺមានសមត្ថកិច្ចដោយយោងតាមការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីដែលនៅក្នុងនោះរួមមានករណីបទល្មើសប្រព្រឹត្តដោយពលរដ្ឋដែលមានសញ្ជាតិខ្មែរចំពោះបទល្មើសជាបទឧក្រិដ្ឋ និងមជ្ឈិម និងនៅគ្រប់បទឧក្រិដ្ឋ ដែលជនរងគ្រោះមានសញ្ជាតិខ្មែរ ព្រមទាំងករណីបទឧក្រិដ្ឋដោយឡែកមួយចំនួនទៀតដែលបានប្រព្រឹត្តមកលើកម្ពុជា ។ ការកំណត់អំពីសមត្ថកិច្ចចំពោះបទល្មើសនៅក្រៅប្រទេសនេះគឺជាគោលការណ៍មួយដើម្បីធានាការពារដល់សិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ និងក៏ដូចជាការពារដល់ផលប្រយោជន៍របស់កម្ពុជា ដោយហេតុថាច្បាប់នៅឯបរទេសនោះ អាចមានការផ្តន្ទាទោសធ្ងន់ធ្ងរជាងច្បាប់នៅកម្ពុជា ឬក៏មានភាពចន្លោះប្រហោងណាមួយដែលនាំឱ្យជនល្មើសរួចផុតពីការផ្តន្ទាទោស ជាអាទិ៍ ។ តែទោះបីជាយ៉ាងក៏ដោយក៏ ព្រះរាជាណាចក្រកម្ពុជាគោរពនូវគោលការណ៍អធិបតេយ្យភាព និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋបរទេស ហេតុដូចនេះដើម្បីអនុវត្តនូវសមត្ថកិច្ចនៃច្បាប់កម្ពុជានេះបាន គឺត្រូវតែមានការព្រមព្រៀងឯកភាពពីរដ្ឋបរទេសនោះ តាមរយៈការចុះកិច្ចព្រមព្រៀងទ្វេរភាគី។

[71] មាត្រា ២០នៃច្បាប់ស្តីពី លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

# សេចក្តីសន្និដ្ឋាន

ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកអនុវត្តច្បាប់គ្រប់រូប ពិសេសសម្រាប់ ចៅក្រម ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌។ល។ ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទណ្ឌិតដែលបានទទួលនូវផលប្រយោជន៍ពីការចូលជាធរមាននៃអត្ថបទច្បាប់ថ្មី ឬក្រមព្រហ្មទណ្ឌថ្មីនេះទៅលើ គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស ណាមួយដែលខ្លួនបានប្រព្រឹត្តនៅក្នុងសម័យអន្តរកាលហើយក្រោយមកក៏មានក្រមព្រហ្មទណ្ឌថ្មីយើងនេះបានចូលជាធរមាន ហើយបានលុបចោលនូវអំពើដែលបានប្រព្រឹត្តនោះចេញដោយពុំចាត់ថាជាបទល្មើសនោះទេ។នេះក៏សម្រេចបានថា ក្រោយមានការលុបចោលនូវបទល្មើសណាមួយដែលបានប្រព្រឹត្តនៅក្នុងសម័យអន្តរកាល ឬ ប្រព្រឹត្តមុនការចូលជាធរមាននៃក្រមព្រហ្មទណ្ឌថ្មីយើងនេះ ហើយអំពើនោះត្រូវច្បាប់ក្រោយនេះពុំបានចាត់ថាជាបទល្មើសទេនោះ ហេតុនេះនាំអោយទណ្ឌិត ឬ ជនជាប់ចោទទាំងអស់ដែលត្រូវបានព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេត ឬក៏សម្រេចចោទប្រកាន់ហើយនោះ ត្រូវតែបញ្ឈប់ការចោទប្រកាន់ ឬបញ្ឈប់ការអនុវត្តទោសតែម្តង។នេះហើយជាអត្ថប្រយោជន៍ដែលជនល្មើសបានទទួលនៅក្រោមអានុភាពនៃច្បាប់ព្រហ្មទណ្ឌថ្មីយើងនេះដោយសារការលុបចោលនូវបទល្មើសណាមួយ។

ចំពោះការអនុវត្តទោសដែលស្រាលជាង ឬ ធ្ងន់ជាងវិញ ក៏មានការចាំបាច់សម្រាប់ការអនុវត្តផងដែរដោយសារថា ចៅក្រមដែលសម្រេចសេចក្តីពីបញ្ហារណាមួយទៅលើអំពើណាដែលបានប្រព្រឹត្តក្រោមកិច្ចនៃច្បាប់ចាស់ តែពុំទាន់បានចូលជាស្ថាពរនៅឡើយ ដោយសារតែមានការប្តឹងបន្តផ្សេងៗទៀត។លុះក្រោយមកច្បាប់ថ្មីក៏បានចែងពីអំពើដែលបានប្រព្រឹត្តដូចគ្នា គ្រាន់តែខុសគ្នានូវអតិបរមា និង អប្បបរមាប៉ុណ្ណោះ ដែល **ច្បាប់ថ្មីស្រាលជាងច្បាប់ចាស់នោះ គឺត្រូវអនុវត្តភ្លាមតែម្តង**[72] ឬអាចនិយាយបានថាច្បាប់ថ្មីមានអានុភាពប្រតិសកម្មក្រោយការចូលជាធរមានចំពោះទោសដែលស្រាលជាង។ក៏ប៉ុន្តែក្រមថ្មីនេះបានបញ្ជាក់បន្ថែមថា " **ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ** " [73]។នេះអាចបញ្ជាក់បានថា ច្បាប់ថ្មីមានអានុភាពប្រតិសកម្មទៅលើអំពើណាដែលបានប្រព្រឹត្តហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដែលមិនទាន់ចូលជាស្ថាពរប៉ុណ្ណោះ បើសិនណាតុលាការបានសម្រេចផ្តន្ទាទោស និងសេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយ ទោសដែលចេញពីសេចក្តីសម្រេចនោះត្រូវតែអនុវត្ត ទោះបីជាទោសនេះធ្ងន់ធ្ងរជាងច្បាប់ថ្មីយ៉ាងណាក៏ដោយ។

[72] មាត្រា ១០ កថាខណ្ឌទី ១ វាក្យខ័ណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា
[73] មាត្រា ១០ កថាខណ្ឌទី ១ វាក្យខ័ណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

ហើយចំពោះគោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហរវិញ គឺការអនុវត្ត ឬជាការកំណត់នូវភាពក្នុងដែនដី ឬក៏ក្រៅដែនដីនៃសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌកម្ពុជា។ចំពោះភាពជាដែនដី ច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមានវិសាលភាពអនុវត្តនៅលើដែនដីជាតិកម្ពុជាទាំងមូលដែលរួមមាន **ដែនទឹក ដែនគោក ដែនអាកាស** ជាដើម[74]។ តែអំពើខ្លះពុំបានប្រព្រឹត្ត ឬក៏សម្រេចផលនៅកម្ពុជាទេ តែច្បាប់បានចាត់ថា " **បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** " [75]។ នេះសរបញ្ជាក់អោយឃើញថា បើទោះបីជា បទល្មើសណាមួយបានប្រព្រឹត្តនៅលើទឹកដីកម្ពុជា ឬក៏ប្រព្រឹត្តនៅរដ្ឋបរទេសក៏ដោយ អោយតែមានបំពេញនូវល័ក្ខខ័ណ្ឌណាមួយដែលចេញពីកម្ពុជានោះបទល្មើសនេះចាត់ថាបានប្រព្រឹត្តនៅកម្ពុជាផងដែរ[76]។ ហើយចំពោះគោលការនៃការអនុវត្តច្បាប់ក្រៅដែនដីវិញ ក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជានៅតែមានអានុភាពអនុវត្តផងដែរ បើទោះបីជាបទល្មើសនោះប្រព្រឹត្តនៅបរទេសក៏ដោយ តែដោយសារបទល្មើសនេះមានការជាប់ពាក់ព័ន្ធនិងអធិបតេយ្យភាពរបស់កម្ពុជា ដូចជា **គោលការណ៍សញ្ជាតិ និង បទឧក្រិដ្ឋប្រឆាំងកម្ពុជា** ជាអាទិ៍[77]។ ហើយដែលគោលការណ៏សញ្ជាតិនេះ គឺគិតទាំងជនល្មើស និងជនរងគ្រោះជាពលរដ្ឋខ្មែរទាំងពីរភេទ ហើយបើទោះបីជាជននេះបានទទួលសញ្ជាតិខ្មែរក្រោយអំពើចោទប្រកាន់ ក៏ត្រូវទទួលបាននូវអត្ថប្រយោជន៍នេះផងដែរ។

សរុបជារួមមកវិញ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជាគឺពិតជាមានភាពចាំបាច់ ក៏ដូចជាសារះសំខាន់ខ្លាំងណាស់សម្រាប់ អ្នកអនុវត្តច្បាប់ដូចជា ចៅក្រម ព្រះរាជអាជ្ញា ក្រលាបញ្ជី នគរបាលយុត្តិធម៍ ពិសេស ពិតជាមានភាពចាំបាច់យ៉ាងខ្លាំងចំពោះទណ្ឌិតដែលបានទទួលប្រយោជន៍ពី ច្បាប់ដែលលុបចោលបទល្មើស និង ភាពប្រតិសកម្មនៃបទល្មើសដែលស្រាលជាងផងដែរ។ហើយចំពោះគោលការណ៍នៃភាពជាដែនដី ទាំងក្នុង និង ក្រៅដែនដី ក៏បានផ្តល់ភាពចាំបាច់ខ្លាំងដល់ជនល្មើស ក៏ដូចជាជនរងគ្រោះ ដែលជាជនជាតិខ្មែរផងដែរ។

[74] មាត្រា ១២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[75] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[76] មាត្រា ១២ ដល់ មាត្រា ១៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

[77] មាត្រា ១៩ ដល់ មាត្រា ២៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

## អនុសាសន៍

ដោយឆ្លងកាត់ការស្រាវជ្រាវអស់រយៈពេលយ៉ាងយូរកន្លងមកនេះពាក់ព័ន្ធនិងប្រធានបទស្តីអំពី « **ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » យើងសង្កេតឃើញថាច្បាប់ដែលសភាបានអនុម័តនៅមានភាពល្អប្រសើរយ៉ាងក្រៃលែង ក៏ប៉ុន្តែការអនុវត្តផ្សេងៗនៅខ្វះចន្លោះត្រង់ថា ៖

**១. ការផ្សព្វផ្សាយ** ៖ ដូចយើងបានដឹងស្រាប់មកហើយថា ក្រោយការប្រកាសអោយនូវក្រមព្រហ្មទណ្ឌថ្មីយើងនេះ គឺ ក្រសួងយុត្តិធម៌ បានសហការជាមួយនឹង ក្រសួងពត៌មានក្នុងការផ្សព្វផ្សាយនូវច្បាប់ថ្មី នេះតាមរយៈមធ្យោបាយទូរគមនាគម៍ផ្សេងៗដើម្បីអោយអ្នកអនុវត្តច្បាប់ទាំងឡាយ ក៏ដូចជាពលរដ្ឋខ្លួនមានការយល់ដឹងអោយបានកាន់តែច្រើនអំពីបញ្ហាផ្លូវច្បាប់។ប៉ុន្តែការផ្សព្វផ្សាយបែបនេះនៅមានភាពខ្វះចន្លោះ ព្រោះថាបើសិនជាអាជ្ញាធរមានសមត្ថកិច្ចបានធ្វើការផ្សព្វផ្សាយដោយមានការចុះផ្ទាល់ជាមួយពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីផ្សព្វផ្សាយ នោះច្បាប់ដែលបានប្រកាសអោយប្រើនេះគឺកាន់តែមានប្រសិទ្ធភាពអនុវត្ត ហើយពលរដ្ឋខ្លួនក៏យល់ដឹងច្រើនលើបញ្ហាផ្លូវច្បាប់ដែរ។

**២. ការចូលរួម** ៖ ការចូលរួមនៅក្នុងន័យនេះ គឺចង់សំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការចូលរួមសម្តែងជាមតិទាំងឡាយណាដែលខ្លួនយល់ឃើញចំពោះថាគួរ ឬមិនគួរនៅពេលដែលសភាធ្វើការអនុម័តនូវអត្ថបទច្បាប់ណាមួយ ព្រោះថាបើសិនណាច្បាប់ដែលចេញសម្រាប់អោយពលរដ្ឋអនុវត្ត តែច្បាប់នោះចេញមកពលរដ្ឋធ្វើការប្រឆាំង ឬសម្តែងការមិនពេញចិត្តផ្សេងៗ អញ្ចឹងតើច្បាប់នោះអនុវត្តទៅបានន័យអ្វី បើពលរដ្ឋខ្លួនអត់គាំទ្រផងនោះ។

**៣. ការបណ្តុះបណ្តាល** ៖ ការបណ្តុះបណ្តាលនេះ គឺពិតជាមានសារះសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសជាតិនានានៅទូទាំងសាកលលោក ព្រោះថាបើច្បាប់ចែងមកល្អហើយ តែមន្ត្រីអនុវត្តមិនល្អនោះប្រាកដណាស់និងធ្វើអោយរាស្ត្ររងទុក្ខទឹកភ្នែកជាក់ជាមិនខាន។ដូច្នេះគុណភាពមន្ត្រី គឺត្រូវតែមានសមត្ថភាព និងចំណេះជំនាញពិតប្រាកដទើបអាចអោយសង្គមជាតិខ្លួនរីកចម្រើនបន្តទៅមុខបាន ពិសេសក៏បានធ្វើអោយពលរដ្ឋខ្លួនមានភាពកក់ក្តៅ និង ទំនុកចិត្តកាន់តែច្រើនទៅលើមន្ត្រីអនុវត្តផងដែរ។

# ឯកសារយោង

## ១. ប្រភពឯកសារជាបទដ្ឋានគតិយុត្ត

- **បទដ្ឋានគតិយុត្តជាតិ**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
  - បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដោយសេចក្តីសម្រេចចុះថ្ងៃទី ១០ កញ្ញា ឆ្នាំ ១៩៩២
  - សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ចុះថ្ងៃទី៥ ខែ មិនា ឆ្នាំ ២០០៣
  - ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ នៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩
  - ច្បាប់ស្តីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០៣ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨
  - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧
  - ច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៨/០០៣ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៧
  - អនុក្រឹត្យស្តីពី សន្តិសុខនាវា និង សន្តិសុខបបនីយភណ្ឌផែ ត្រូវបានប្រកាសអោយប្រើដោយអនុក្រឹត្យ លេខ ៤០ អនក្រសក នៅថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ២០០៦
  - ពន្យល់ក្រមព្រហ្មទណ្ឌ រៀបរៀងដោយលោក លីន សិលា
  - ច្បាប់ឯកពន្ធភាព ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ធ្វើនៅព្រះបរមរាជវាំងនៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៦
- **បទដ្ឋានគតិយុត្តអន្តរជាតិ**
  - អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ
  - អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ១៩៦១ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត នៅថ្ងៃទី ៣១ ខែសីហា ១៩៦៥ និងចូលជាធរមាននៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦៥
  - ច្បាប់ស្តីពី លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

- ច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០២៦ នៅថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១០/០០៥ នៅថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១០
- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៤០៥/០០៧ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០០៥

## ២. ឯកសារជាសៀវភៅ

- មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពន្យល់ដោយ ឯកឧត្តម កើត រិទ្ធិ ឯកឧត្តម ប៊ុន ហ៊ុន ឯកឧត្តម ហ៊ី សោភា ឯកឧត្តម ផូវ សំភី លោកស្រី ចាំង ស៊ីណាត ចងក្រងដោយលោក សឿន មុន្នីវ័ត្ន ព្រះរាជអាជ្ញារងខេត្តកំពង់ធំ
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រី ចាំង ស៊ីណាត ឆ្នាំ ២០១២
- នីតិព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រ រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ី សោភា ប្រធានតុលាការខេត្តកណ្តាល
- នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀងនិងវាយអត្ថបទដោយ ៖ កៅ សីហា កំពុងសិក្សាថ្នាក់បណ្ឌិតច្បាប់ សាស្ត្រាចារ្យច្បាប់ និងជាមន្ត្រីរាជការនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ ២០១៣
- សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែនអនុវត្តន៍ក្នុងលំហនៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ របស់សិស្សនិស្សិតឈ្មោះ លោក ហោ ឈុនឡុង និង លោកស្រី អ៊ឹង សុជា សាស្ត្រាចារ្យណែនាំ លី ច័ន្ទតុលា ឆ្នាំ ២០១៧
- មេរៀននីតិព្រហ្មទណ្ឌ ក្រោមកិច្ចសហប្រតិបត្តការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ
- បាវឋកថាស្តីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ដែលរៀបរៀងដោយ ឯកឧត្តម កើត រិទ្ធិ

## ៣. ប្រភពឯកសារផ្សេងៗ

- សន្ទានុក្រមពាក្យថ្មី សាស្ត្រាចារ្យ ទូច គីមស្រ៊ាង សមាជិកក្រុមប្រឹក្សាជាភាសាខ្មែរ គ.ស ២០១៤
- ប្រសាសន៍ឯកឧត្តម កើត រិទ្ធិ ក្នុងពេលបង្រៀនសិស្សនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង

វិទ្យាសាស្រ្តសេដ្ឋកិច្ច

- ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ ឯកឧត្តម ប៊ុន ហុន ឯកឧត្តម ផូវ សំភី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០
- ការណែនាំ ក៏ដូចជាការបង្ហាត់បង្ហាញបន្ថែមពីសំណាក់សិស្សច្បង
- ការពន្យល់ពីអត្ថបទច្បាប់នៃគេហទំព័រ Law Asia។

# ឧបសម្ព័ន្ធ

**UNITED NATIONS**
UNITED NATIONS TRANSITIONAL
AUTHORITY IN CAMBODIA
(UNTAC)

**NATIONS UNIES**
AUTORITE PROVISOIRE DES NATIONS
UNIES AU CAMBODGE
(APRONUC)

# បទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល




*PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD*

*DISPOSITIONS RELATIVES AU SYSTEME JUDICIAIRE AU DROIT PENAL ET ALA PROCEDURE PENALE APPLICABLES AU CAMBODGE PENDANTLA PERIODE TRANSITOIRE*

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល

សេចក្តីសំរេចចុះថ្ងៃទី ១០ កញ្ញា ១៩៩២

**ក្រុមប្រឹក្សាជាតិជាន់ខ្ពស់** ដែលចាប់ពីពេលនេះទៅហៅថា «SNC» អេស អិន ស៊ី

- ដោយសំអាងលើអំណាចទាំងឡាយ ដែលប្រគល់ឡើងតាមមាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចុះថ្ងៃទី ២៣ តុលា ១៩៩១ ដែលចាប់ពីពេលនេះទៅហៅថា «កិច្ចព្រមព្រៀង» ទុកដូចជាអង្គការពេញច្បាប់តែមួយគត់ ហើយជាព្រភពនៃអាជ្ញាធរកម្ពុជា,
- ដោយរំលឹកឡើងវិញនូវមាត្រា៦ នៃកិច្ចព្រមព្រៀងដែលនៅក្នុងនោះ SNC បានប្រគល់ជូនដល់អង្គការសហប្រជាជាតិ នូវអំណាចទាំងអស់ដែលចាំបាច់សំរាប់អនុវត្តកិច្ចព្រមព្រៀង,
- ដោយរំលឹកបន្ថែមទៀតថា ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេចចិត្ត ៧៤៥ (១៩៩២) បានរៀបចំអាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ដែលចាប់ពីពេលនេះតទៅហៅថា «អ៊ុនតាក់» ស្របតាមមាត្រា ២ នៃកិច្ចព្រមព្រៀង ដើម្បីបំពេញតួនាទីភារកិច្ច ដែលចែងឡើងក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀង,
- ដោយយល់ថា អ៊ុនតាក់ ត្រូវបានទទួលបេសកកម្មមួយ, ស្របតាមមាត្រា ៦ និង ១៦ នៃកិច្ចព្រមព្រៀងប៉ារីស និងផ្នែក ខ និង ង នៃឧបសម្ព័ន្ធទី១, ក្នុងការត្រួតពិនិត្យផ្ទាល់ ឬ ការពិនិត្យត្រួតត្រាលើវិស័យទាំងឡាយ ស្តីអំពីការរក្សារបៀបរៀបរយ និងការគោរពច្បាប់, ការការពារសិទ្ធិមនុស្ស, ការអនុវត្តន៍ច្បាប់ និងដំណើរការក្នុងប្រព័ន្ធតុលាការ,
- ដោយយល់ឃើញថែមទៀតថា ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង បានទទួលស្គាល់ដោយជាក់លាក់, ក្នុងមាត្រា១៥, ថាមនុស្សគ្រប់រូបនៅប្រទេសកម្ពុជា និងជនភៀសខ្លួនទាំងអស់ និងជនផ្លាស់ប្តូរទីកន្លែងទាំងអស់នៅកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស

- ដោយយល់ឃើញម្យ៉ាងទៀតថា SNC បានយល់ព្រមចូលរួមក្នុង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិខាងវិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌ នៅថ្ងៃទី ២០ មេសា ១៩៩២ ហើយថាឧបករណ៍ទាំងនេះបានចូលជាធរមាននៅប្រទេសកម្ពុជានៅថ្ងៃ ២៦ សីហា ១៩៩២,

- ដោយមានកង្វល់ថា បណ្តារចនាសម្ព័ន្ធ, ច្បាប់ និងស្ថាប័នតុលាការនៅប្រទេសកម្ពុជាមិនបំពេញអោយបានពេញលេញតាមការតម្រូវរបស់កិច្ចព្រមព្រៀងប៉ារីស ព្រមទាំងពេលខ្លះមានការខ្វះខាតមួយផ្នែក ឬពុំទាន់មានអ្វីទាល់តែសោះ ហើយបើតាមការពិនិត្យពិច័យ គឺមិនសមស្របដើម្បីធានាអោយមានរបៀបរៀបរយ និងសិទ្ធិមនុស្ស នៅតាមទីកន្លែងនានាជាច្រើនក្នុងដែនដី,

- ដោយទទួលស្គាល់ថា ការទាំងនេះត្រូវនៅក្រោមការទទួលខុសត្រូវរបស់ UNTAC ដើម្បីសំរួលការរៀបចំរចនាសម្ព័ន្ធទាំងឡាយ ច្បាប់ និងស្ថាប័នតុលាការ នៅកន្លែងណាដែលខ្វះខាត ហើយជួយកែលំអកន្លែងណាដែលមានរួចហើយ ដើម្បីអោយសមស្របតាមការតម្រូវចាំបាច់នៃកិច្ចព្រមព្រៀង,

- ដោយមានជំនឿជាក់ទៅលើសេចក្តីត្រូវការជាបន្ទាន់ ដើម្បីបង្ហាញយ៉ាងច្បាស់ជូនភាតីកម្ពុជា នូវក្បួនច្បាប់ដែលត្រូវអនុវត្តទូទាំងប្រទេសកម្ពុជា និង នីតិវិធីតុលាការ ដែលត្រូវយកមកប្រតិបត្តិ ដើម្បីធានាអោយមានការអនុវត្តន៍ជាក់ស្តែង ក្នុងដំណាក់កាលអន្តរកាល,

- ដោយជឿជាក់ថែមទៀតថា ការអនុវត្តន៍ក្បួនច្បាប់ និងនីតិវិធីនេះ ជាការចាំបាច់ដើម្បីធានាបរិយាកាសនយោបាយអព្យាក្រឹត និងរៀបចំការបោះឆ្នោតសេរី និងតាមសមធម៌,

**ដូច្នេះ អនុម័ត** យកបទបញ្ញត្តិអស់ទាំងនេះ ដែលពាក់ព័ន្ធដល់របៀបចាត់ចែងតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងរយៈពេលអន្តរកាល ហើយ **ធ្វើសំណូមពរ** ជាឧឡារិកដល់ភាតីកម្ពុជាទាំងអស់ ដើម្បីអោយអនុវត្តដោយសុទ្ធចិត្ត រហូតដល់សភានីតិបញ្ញត្តិ ដែលកើតឡើងពីការបោះឆ្នោត កែសំរួលបញ្ញត្តិទាំងនេះ ឬ អនុម័តយកច្បាប់ថ្មីទៀតនៅក្នុងវិស័យនេះ ។

# មាតិកា មួយ : ប្រព័ន្ធតុលាការ

## មាត្រា១ : ឯករាជភាពនៃក្រុមចៅក្រម

១ : ឯករាជភាពនៃក្រុមចៅក្រមត្រូវតែធានាអោយមានលក្ខណៈស្របនឹង *គោលការណ៍មូលដ្ឋានស្តីអំពីឯករាជភាពនៃក្រុមចៅក្រម* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។ ចៅក្រមទាំងឡាយត្រូវកាត់ក្តីតាមភាពមិនលម្អៀង ផ្អែកលើហេតុការណ៍ ដែលមាននៅចំពោះមុខ ហើយក្នុងការគោរពច្បាប់ ដោយមិនព្រមទទួលការគាបសង្កត់, ការគំរាមកំហែង ឬការបំភិតបំភ័យ, ដោយចំពោះ ឬមិនចំពោះ អំពីភាគីណាមួយក្នុងរឿងកាត់ក្តី ឬ អំពីអ្នកឯទៀតណាក៏ដោយ ។

២ : ក្រុមចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ឬ ក្រោមភាគីនយោបាយណាឡើយ។ ជនដែលត្រូវគេជ្រើសរើសអោយបំពេញមុខងារក្នុងតុលាការ ត្រូវតែជាអ្នកសុចរិត និងមានសមត្ថភាពផង ។

៣ : គោលការណ៍ឯករាជភាពនៃក្រុមចៅក្រមប្រគល់សិទ្ធិ និងករណីយកិច្ចជូនចៅក្រមដើម្បីធានាអោយការកាត់ក្តីប្រព្រឹត្តទៅក្នុងភាពសុចរិត និង ក្នុងការគោរពដល់សិទ្ធិនៃភាគីដែលត្រូវកាត់ក្តីទាំងអស់ ។ ចៅក្រមត្រូវមានលទ្ធភាពបំពេញមុខងារខ្លួនតាមស្ថានភាពសម្ភារៈសមរម្យ និង គ្រប់គ្រាន់ ។ ចៅក្រមត្រូវទទួលការហ្វឹកហាត់ត្រឹមត្រូវ មានប្រាក់បៀវត្សគ្រប់គ្រាន់ ដើម្បីធានានូវភាពឥតលម្អៀង និង ឯករាជភាពរបស់ពួកគេ ។

## មាត្រា ២ : មុខងារនៃតុលាការ

សមាសភាពនៃក្រុមចៅក្រមមាន ចៅក្រម និង រដ្ឋអាជ្ញា ។ មានតែចៅក្រមទេដែលមានអំណាចសម្រេចសេចក្តី ។ រដ្ឋអាជ្ញាមានបន្ទុកខាងបណ្តឹងអាជ្ញាព្រហ្មទណ្ឌ ដែលមានតែរដ្ឋអាជ្ញាទេដែលមានអំណាចធ្វើកិច្ចការហ្នឹង ។ រដ្ឋអាជ្ញាជាអ្នករៀបចំសំណុំពាក្យចោទប្រកាន់ សំរាប់ដាក់ជូនតុលាការជំនុំជំរះ និងដាក់ជូនអង្គប្រជុំផ្សេងៗទៀត ដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ។ ម្យ៉ាងវិញទៀត អគ្គរដ្ឋអាជ្ញាជាអ្នកលើកយកសំណុំពាក្យចោទប្រកាន់ដាក់ជូនតុលាការកំពូល ក្នុងផលប្រយោជន៍ខាងផ្លូវច្បាប់, ពិនិត្យមើលនូវភាពពេញលក្ខណៈច្បាប់នៃបណ្តឹងចោទទាំងឡាយរបស់រដ្ឋអាជ្ញាខេត្ត, ចាត់ចែង និងណែនាំកិច្ចការរបស់រដ្ឋអាជ្ញា ។

## មាត្រា ៣ : សាលាជំរះក្តី

១ : ដោយមានសហការជាមួយអ៊ុនតាក់ ភាគីកម្ពុជាទាំងអស់សន្យាថានឹងចាត់ចែងអោយមានសាលាដំបូងមួយ យ៉ាងតិច នៅក្នុងតំបន់ ឬខេត្តណាដែលខ្លួនមិនទាន់បានចាត់តាំង ។ ចៅក្រមនានានឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំងឡើង, តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាដំបូងត្រូវមានចៅក្រមម្នាក់ និង រដ្ឋអាជ្ញាម្នាក់ ។ សាលាកាត់ក្តីទាំងនេះមានសមត្ថកិច្ចទាំងស្រុងក្នុងការអនុវត្តន៍បទបញ្ញត្តិបច្ចុប្បន្ននេះ ព្រមទាំងមានសមត្ថកិច្ចលើច្បាប់ ឬបទដ្ឋានទាំងឡាយឯទៀតៗជាធរមាន តាមយុត្តាធិការរៀងៗខ្លួន ។

៣ : ចៅក្រមជំនួស អាចត្រូវគេតែងតាំងក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងចៅក្រមដែរ ដើម្បីជំនួសចៅក្រមដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬក្នុងករណីអសមត្ថភាព ។

## មាត្រា ៤ : សាលាឧទ្ធរណ៍

១ : ដោយសហការណ៍ជាមួយអ៊ុនតាក់ ភាគីទាំងឡាយសន្យាថានឹងចាត់ចែងអោយមានសាលាឧទ្ធរណ៍មួយ យ៉ាងតិច នៅក្នុងតំបន់ ឬដែនដីណាដែលខ្លួនមិនទាន់បានបង្កើតនៅឡើយ ។ ចៅក្រមទាំងឡាយនឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំង, តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាឧទ្ធរណ៍នេះមានចៅក្រមបីនាក់ និង រដ្ឋអាជ្ញាម្នាក់ ដែលតែងតាំងឡើងដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ក្រោមកិច្ចត្រួតពិនិត្យរបស់ អ៊ុនតាក់ ។ ចៅក្រមជំនួសអាចត្រូវគេតែងតាំងក្នុងល័ក្ខខ័ណ្ឌដូចគ្នា ដើម្បីជំនួសចៅក្រមណាដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬ ក្នុងករណីអសមត្ថភាព ។

៣ : បណ្ដាភាគីដែលមានទាក់ទិនក្នុងរឿងក្ដីនេះ, ភាគីរដ្ឋប្បវេណី, ទណ្ឌិត ឬទីប្រឹក្សារបស់ភាគីទាំងសង្ខាង, រដ្ឋអាជ្ញាអាចប្ដឹងឧទ្ធរណ៍ពីសេចក្ដីសំរេចរបស់សាលាដំបូងនានា ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃដែលចៅក្រមប្រកាសសាលក្រមនោះ បើសិនជាសាលក្រមនោះធ្វើឡើងចំពោះមុខសាមីខ្លួន, ហើយបន្ថែមពេលបណ្ដឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើការកាត់ទោសនេះធ្វើឡើងដោយគ្មានសាមីខ្លួន ។ សាលក្រមចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះសោតទេ នឹងទុកដូចជាការកាត់ក្ដីមិនចំពោះមុខ ។

៤ : សាលាឧទ្ធរណ៍ជំនុំជំរះទាំងអង្គច្បាប់ ទាំងអង្គហេតុ ។

## មាត្រា ៥ : តុលាការជាន់ខ្ពស់

ដោយអនុលោមតាមសំណូមពររបស់ភាគី «រដ្ឋកម្ពុជា» ដំណើរការនៃតុលាការជាន់ខ្ពស់បច្ចុប្បន្ននឹងត្រូវកែលំអ ដើម្បីអោយមានលទ្ធភាពគោរពតាមកាតព្វកិច្ច ដែលចែងក្នុងមាត្រា ១ ព្រមទាំងបំពេញមុខងារដូចខាងក្រោមនេះ ៖

ក- តុលាការនេះជាតុលាការជំនុំជំរះអង្គច្បាប់

ខ- តុលាការនេះអាចទទួលពាក្យបណ្ដឹងកែតម្រូវចំពោះសេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ ពីអគ្គរដ្ឋអាជ្ញា, ជនជាប់ទោស, ភាគីរដ្ឋប្បវេណី ឬ ទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលចេញសាលដីកាជំនុំជំរះ បើសាលដីកានោះធ្វើឡើងចំពោះមុខ ហើយនិង បន្ថែមពេលបណ្ដឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើសាលដីកានេះធ្វើឡើងដោយមិនចំពោះមុខ ។ សាលដីកាចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះទេនឹងទុកដូចជាមិនចំពោះមុខ ។

គ- តុលាការនេះអាចបញ្ជូនសំណុំរឿងទាំងឡាយត្រឡប់ទៅសាលាឧទ្ធរណ៍មួយដែលមានសមាសភាពផ្សេងខុសពីមុន ហើយបើសាលាឧទ្ធរណ៍ថ្មីនេះមិនសម្រេចតាមសាលដីកាខ្លួនទេនោះ តុលាការនេះអាចទទួលបណ្ដឹងពីអគ្គរដ្ឋអាជ្ញា ទណ្ឌិត ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលប្រកាសសាលដីកា ក្នុងល័ក្ខខ័ណ្ឌដែលដូចបានចែងនៅក្នុងវគ្គ ខ នៃមាត្រានេះ ។ ពេលនោះ តុលាការជាន់ខ្ពស់អាចជំនុំជំរះទាំងអង្គហេតុ និងទាំងអង្គច្បាប់ ហើយធ្វើសេចក្ដីសំរេចជាស្ថាពរតែម្ដង ។

## មាត្រា ៦ : នគរបាល

១ : នគរបាលត្រូវប្រតិបត្តិតាម *បទបញ្ជាសីលធម៌សំរាប់អ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់*, ហើយបើអាចធ្វើទៅបាន ត្រូវប្រតិបត្តិតាម *គោលច្បាប់ជាមូលដ្ឋានស្តីអំពីការប្រើកម្លាំង និងការប្រើកាំភ្លើងនៃអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

២ : បណ្តាភាគី ដែលកងកំលាំងរបៀបរៀបរយរបស់ខ្លួនមិនមានលទ្ធភាពបំពេញតាមការតម្រូវនៃបទបញ្ញត្តិនេះ សន្យាសហការជាមួយអ៊ុនតាក់ ដើម្បីរៀបចំអោយមាន និង បង្ហាត់ហ្វឹកហ្វឺនកងកំលាំងនគបាលមួយអោយបានត្រឹមត្រូវ ។

## មាត្រា ៧ : មេធាវី និង ទីប្រឹក្សា

១ : មេធាវីទាំងឡាយនឹងត្រូវអនុញ្ញាតអោយបង្កើតជាអង្គការមេធាវី ដែលមានរូបភាពជាសមាគមមួយ ដោយមានអំណាចខាងវិន័យ និងបទបញ្ជាទៅលើសមាជិកខ្លួនទាំងអស់ ។ អង្គការមេធាវីមិនត្រូវទទួលការបង្គាប់បញ្ជា ជាដាច់ខាត ពីគណៈបក្សនយោបាយណាមួយ, ពីសំណាក់អំណាចនីតិបញ្ញត្តិណាមួយ ឬ ពីអំណាចនីតិប្រតិបត្តិណាមួយ ដែលនៅក្រោមនិវាទនៃភាគីកម្ពុជាណាមួយ ក្នុងកិច្ចព្រមព្រៀងប៉ារីស ។

ក្នុងរយៈពេលអន្តរកាល ជនដែលអាចធ្វើជាមេធាវីបាន គឺជនទាំងឡាយណាដែល យ៉ាងហោចណាស់ មានសញ្ញាប័ត្រស្មើនឹងបរិញ្ញាប័ត្រនីតិសាស្រ្ត ឬមានការពិសោធន៍ប្រាំឆ្នាំក្នុងវិស័យច្បាប់ ឬ វិស័យតុលាការ ប្រកបដោយកិរិតខ្ពស់ទទួលខុសត្រូវក្នុងកិច្ចការបាន ។

២ : ដោយចំនួនមេធាវីមានតិចតួចពេកនៅប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរៈកាលនេះ ជនកម្ពុជាគ្រប់រូបដែលមានសញ្ញាប័ត្រមធ្យមសិក្សា អាចតំណាងជនជាប់ចោទនៅចំពោះមុខតុលាការបាន ល្គឹកណាដែលអ្នកនោះគ្មានឋានន្តរស័ក្តិជាអ្នករដ្ឋការក្នុងបណ្តាថ្នាក់ដឹកនាំ, ជាអ្នកជាប់ឆ្នោតក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬក្នុងគណៈបក្សនយោបាយដែលគេទទួលស្គាល់ទាំងឡាយ ។ លើសពីនោះទៀត ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារខ្លួន អោយធ្វើជាជំនួយការពារខ្លួនបាន ទោះបីមានកិរិតសិក្សាថ្នាក់ណាក៏ដោយ ។

៣ : នៅចំពោះមុខតុលាការ អ្នកតំណាងជនជាប់ចោទមានសិទ្ធិដូចជាមេធាវីដែរ ក្នុងការជូនដំណឹងពីឯកសារ ក្នុងការធ្វើលិខិតនីតិវិធី ឬ ក្នុងការជជែកការពារជនជាប់ចោទ ។ ក្នុងបទបញ្ញត្តិនេះ ពាក្យថា «ទីប្រឹក្សា» មានន័យមិនខុសពីពាក្យមេធាវី ឬ អ្នកតំណាងគ្រប់ប្រភេទរបស់ជនជាប់ចោទឡើយ ។

៤ : មេធាវីបរទេសអាចជជែកការពារចំពោះតុលាការកម្ពុជា ក្នុងកាលៈទេសៈណាដែលគេអាចបង្ហាញភស្តុតាងថា គេបានចុះឈ្មោះក្នុងអង្គការមេធាវីមួយ ឬ ក៏គេបានសេចក្តីអនុញ្ញាតជាផ្លូវការអោយជជែកការពារនៅក្នុងប្រទេសរបស់គេ ។ រចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃសន្យាថានឹងជួយសម្រួលក្នុងការផ្តល់ទិដ្ឋាការចូល ដល់មេធាវីដែលមកបំពេញការងារនៅក្នុងប្រទេសកម្ពុជា ។

## មាត្រាទី ៨ : ប្រព័ន្ធពន្ធនាគារ

១ : ប្រព័ន្ធពន្ធនាគារមានគោលដៅធ្វើអោយមាននីតិសម្បទាសង្គមឡើងវិញ ។ ការប្រព្រឹត្តិចំពោះអ្នកជាប់ទោស ត្រូវតែស្របទៅតាម *បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកទោស* ដែលអង្គការសហប្រជាជាតិបានអនុមម័ត ។

២ : បណ្តាអាជ្ញាធរទាំងឡាយណាដែលចាប់ឃាត់ឃាំងជនជាប់សង្ស័យ ឬឃុំឃាំងមនុស្សក្នុងពេលមុន ឬក្រោយការកាត់ទោស ត្រូវមានបញ្ជីគុកដែលមានរដ្ឋអាជ្ញា និង ចៅក្រមម្នាក់ប្រចាំខេត្ត ឬតំបន់ចុះហត្ថលេខារាល់ខែ ដើម្បីពិនិត្យបញ្ជាក់ឈ្មោះ អាយុ, អាស័យដ្ឋាន, ថ្ងៃ ខែ ឆ្នាំ និងមូលហេតុនៃការចាប់ខ្លួន, ថ្ងៃ ខែ ឆ្នាំដែលបានបញ្ជូនខ្លួនទៅចៅក្រម, ហើយនឹងថ្ងៃ ខែ ឆ្នាំដែលត្រូវគេកាត់ទោស និងទោសដែលគេបានកាត់ហើយ ចំពោះទណ្ឌិត ។

## មាត្រា ៩ : ការពិនិត្យកន្លែងឃុំឃាំង

១- រដ្ឋអាជ្ញា ឬ ចៅក្រមទាំងឡាយអាចចូលពិនិត្យពន្ធនាគារ និងអ្នកទោសបានគ្រប់ពេលវេលា ។

២- ភ្នាក់ងារដែលអនុញ្ញាតដោយផ្នែកសិទ្ធិមនុស្ស រដ្ឋបាលស៊ីវិល និង ប៉ូលីសរបស់អ៊ុនតាក់ ក៏មានសិទ្ធិដូចគ្នាដែរ ។ ក្នុងរឿងនេះ ភាគីខ្មែរទាំងអស់នៃកិច្ចព្រមព្រៀងប៉ារីស ត្រូវធ្វើបញ្ជីរាយទីកន្លែងឃុំឃាំងរបស់ខ្លួនទាំងអស់ អោយបានយ៉ាងយឺតបំផុតនៅពេលដែលបទបញ្ញត្តិនេះចូលជាធរមាន ហើយបញ្ជូនបញ្ជីនេះទៅទីចាត់ការកណ្តាលនៃផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់ ។

## <u>មាតិកា</u> ពីរ : នីតិវិធីព្រហ្មទណ្ឌ

### <u>មាត្រា ១០ : ជំនួយផ្នែកច្បាប់</u>

១ : សិទ្ធិពឹងពាក់មេធាវី ឬទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ ។

២ : ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវជាប់ឃុំឃាំង នៅលើទឹកដីកម្ពុជា លើសពីរយៈពេល ៤៨ម៉ោង ដោយគ្មានបានទទួលជំនួយពីទីប្រឹក្សា, ពីមេធាវី ឬ ពីអ្នកតំណាង ដែលបទបញ្ញត្តិនេះបានអនុញ្ញាតឡើយ ។

### <u>មាត្រា ១១ : តុលាការយោធា</u>

តុលាការយោធាទទួលជំនុំជំរះតែបទល្មើសយោធាទេ។ បទល្មើសយោធា គឺជាបទល្មើសដែលទាក់ទិនដល់យោធិន, ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា ។ បទឧក្រិដ្ឋ ឬ បទល្មើសនឹងច្បាប់សាមញ្ញ ដែលប្រព្រឹត្តដោយយោធិន នឹងត្រូវទទួលការជំនុំជំរះនៅតុលាការស៊ីវិល ។

## មាត្រា ១២ : ការគ្រប់គ្រងជនជាប់ឃុំ

១ : គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬ ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ, អមនុស្សធម៌ ឬនាំអោយបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និង ធ្វើទារុណកម្មឡើយ ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ ។ អ្នកទោសទាំងឡាយមិនត្រូវបានគេចង ឬ ដាក់អោយនៅឯកោម្នាក់ឯង, ទោះស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នក្តី ឬត្រូវបានកាត់ទោសរួចហើយក្តី ។ ទោះក្នុងករណីណាក៏ដោយ គ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោសមិនត្រូវមានគេយាយី ដោយសារតែការប្រព្រឹត្តិរបស់ជននោះឡើយ ។

២ : ការចាប់ខ្លួន និងការឃុំខ្លួនត្រូវតែគោរពតាម *បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកជាប់ឃុំ* ព្រមទាំងត្រូវគោរពតាម *គោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រាទី ១៣ : ការចាប់ខ្លួន និង ការឃុំខ្លួន

១ : គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនលើសពី ៤៨ម៉ោង ដោយមិនបានបញ្ជូនទៅចៅក្រម តាមរយៈបណ្តឹងរបស់រដ្ឋអាជ្ញាឡើយ ។ ក្នុងករណីណាដែលពុំអាចគោរពតាមបិរៈវេលានេះបាន ដោយសារស្ថានភាពនៃការដឹកជញ្ជូនក្នុងតំបន់និមួយៗនោះ គេអាចបន្ថបន្ថែមបាននូវពេលវេលាចាំបាច់សំរាប់តែដឹកនាំអ្នកជាប់ឃុំឃាំងនេះ ទៅជូនចៅក្រមតាមមធ្យោបាយយ៉ាងឆាប់ដែលអាចធ្វើបាន ។

២ : រដ្ឋអាជ្ញាសុំអោយចៅក្រមចោទប្រកាន់ ព្រមទាំង ជាយថាហេតុ ឃុំខ្លួនជនជាប់សង្ស័យ ក្រោយពីបានពិនិត្យសំណុំរឿងពីនគរបាល ដោយរៀបរៀងដីកាសន្និដ្ឋានមួយ ទុកជាសេចក្តីផ្តើមចោទ យោងតាមអង្គហេតុជាក់ស្តែង និងដែលកំណត់បទល្មើសតាមច្បាប់អោយស្របទៅតាមបទបញ្ញត្តិព្រហ្មទណ្ឌនេះ ។

៣ : ក្នុងខណៈនោះ ដោយផ្អែកលើសេចក្តីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា ៖

- ត្រូវចោទប្រកាន់ជនជាប់សង្ស័យ ដោយអោយឃុំឃាំង ឬ មិនអោយឃុំឃាំង,
- អោយដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកថាភស្តុតាងនៃពិរុទ្ធភាពមិនគ្រប់គ្រាន់,

- សំរេចអោយបន្តការស៊ើបអង្កេត ដោយមិនប្រាប់ឈ្មោះជនជាប់សង្ស័យ ។

៤ : ក្នុងរយៈពេលយ៉ាងច្រើន ៤៨ម៉ោងដូចគ្នានេះ ក្រោយការចាប់ខ្លួន ហើយ ជាយថាហេតុ ត្រូវបានពន្យាថេរៈវេលាចាំបាច់ក្នុងការដឹកនាំ ដូចបានចែងនៅវគ្គទី១ ទីប្រឹក្សាត្រូវបានទទួលសំណុំរឿង ដែលទាក់ទងក្នុងការចោទប្រកាន់ចំពោះជនជាប់សង្ស័យ ។

## មាត្រាទី ១៤ : ការឃុំខ្លួនជាបណ្តោះអាសន្ន

១ : មានតែចៅក្រមទេ ដែលអាចសម្រេច ដោយមានចែងមូលហេតុ អោយឃុំខ្លួនជនជាប់ចោទទុកក្នុងមន្ទីរឃុំឃាំងតាមសេចក្តីស្នើសុំរបស់រដ្ឋអាជ្ញា ហើយមានតែក្នុងករណីដែលបារម្ភខ្លាចក្រែងជននោះរត់គេចខ្លួន និងដោយគ្មានអ្វីអាចអោយធានាបានថា ជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ មានន័យថា សាមីជនគ្មានការងារធ្វើ គ្មានគ្រួសារ គ្មានទីលំនៅពិតប្រាកដ ឬដោយខ្លាចជនជាប់ចោទនោះប្រើឥទ្ធិពលលើសាក្សី ឬលើដំណើរការស៊ើបអង្កេត ។

២ : ជនជាប់ចោទមានសិទ្ធិសុំចៅក្រម អោយដោះលែងខ្លួន តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈទីប្រឹក្សារបស់ខ្លួន ។ ក្នុងរយៈពេលប្រាំថ្ងៃ ចៅក្រមត្រូវឆ្លើយតាមដីកាដែលមានចែងមូលហេតុ ។

៣ : ក្នុងរយៈពេល៥ថ្ងៃក្រោយពីដីកានោះមក ជនជាប់ចោទ, ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់ភាគីទាំងសង្ខាង ឬរដ្ឋអាជ្ញាអាចសុំឧទ្ធរណ៍ពីសេចក្តីសំរេចរបស់ចៅក្រម ។ ក្នុងរយៈពេល១៥ថ្ងៃ សាលាឧទ្ធរណ៍ត្រូវសំរេចលើពាក្យសុំឧទ្ធរណ៍ទាំងឡាយដែលទាក់ទិនក្នុងរឿងឃុំខ្លួននេះ ។

៤ : រយៈពេលឃុំឃាំងជាបណ្តោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវអោយហួសពីបួនខែទេ ។ ប៉ុន្តែតាមការសំរេច ដែលមានចែងមូលហេតុរបស់ចៅក្រម រយៈពេលនេះអាចបន្តដល់ប្រាំមួយខែ ប្រសិនបើមានការចាំបាច់សំរាប់ធ្វើការស៊ើបអង្កេត ។

៥ : អនីតិជនអាយុតិចជាង ១៣ឆ្នាំមិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ ។ អនីតិជនដែលមានអាយុ ១៣ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី ១ខែទេ ។ រយៈពេលនេះអាចទ្វេឡើងជាពីរ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

## មាត្រា ១៥ : ការឃុំខ្លួនតាមបទរដ្ឋបាល

នៅប្រទេសកម្ពុជាមិនត្រូវមានជនណាត្រូវឃុំឃាំង ដោយនគរបាលរដ្ឋបាលណាមួយ ឬពីបទល្មើសណាដែលគ្មានចែងនៅក្នុងបទបញ្ញត្តិនេះ ឬ ក្នុងច្បាប់ឯទៀត ឬអត្ថបទឯទៀតៗខាងវិស័យព្រហ្មទណ្ឌឡើយ ។

## មាត្រា ១៦ : ការដោះលែងជនជាប់ឃុំ

ជនដែលជាប់ឃុំឃាំង ឬឃាត់ខ្លួនទុកនៅតាមមន្ទីរឃុំឃាំងនានា ដែលគ្មានឈ្មោះក្នុងបញ្ជីដូចមានរៀបរាប់នៅក្នុងមាត្រា ៩ នៃបទបញ្ញត្តិនេះ នឹងត្រូវចាត់ទុកថាបានជាប់ឃុំឃាំងខុសច្បាប់ ហើយត្រូវតែដោះលែងភ្លាមមួយរំពេច តាមសេចក្តីសុំរបស់រដ្ឋអាជ្ញា, គ្រប់សាលាដំបូង, ទីប្រឹក្សារបស់អ្នកជាប់ឃុំ ឬបុគ្គលិកដែលមានសេចក្តីអនុញ្ញាតពីផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់, ផ្នែកសិទ្ធិមនុស្ស និង នគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ រីឯអ្នកដែលត្រូវគេឃុំឃាំង ឬឃាត់ខ្លួនទុកនៅក្នុងមន្ទីរឃុំឃាំងដែលបានប្រកាស ហើយដែលគ្មានឈ្មោះលើបញ្ជីឃុំឃាំង ក៏ត្រូវគេដោះលែងដូចគ្នាដែរ ។

## មាត្រា ១៧ : សិទ្ធិពិនិត្យសំណុំរឿង

១ : ប្រសិនបើចៅក្រមសំរេចថា ចាំបាច់ត្រូវស៊ើបអង្កេតបន្ថែមទៀត, តាមលំដាប់លំដោយនៃការស៊ើបអង្កេតនេះ, ទីប្រឹក្សារបស់ជនជាប់ចោទត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភ័ស្តុតាងថ្មីៗទៀត ប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។

២ : ទីប្រឹក្សាមានសិទ្ធិពិនិត្យសំណុំរឿងអ្នកជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយល័ក្ខអក្សរ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រម នូវគ្រប់លទ្ធផលដែលបានមកអំពីការស៊ើបអង្កេត, អំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬអំពីសវនកម្មដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។

## មាត្រា ១៨ : បទល្មើសជាក់ស្តែង

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺថា ៖

- បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប្រជាប់ចាប់ប្រតឹង
- បើជនសង្ស័យត្រូវបានសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ បទល្មើស ថាជាពិរុទ្ធិកជន
- បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ។

## មាត្រា ១៩ : ការចាប់ខ្លួនដោយសំអាងលើភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់

១ : ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបានលុះត្រាតែមានភ័ស្តុតាងជាក់ស្តែងយ៉ាងខ្លាំង, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញអោយឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទបញ្ញើមមែន ។

២ : បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា ឬ ចៅក្រម ដែលនឹងត្រូវអនុវត្តដោយនគរបាលតុលាការ ។

៣ : ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយ ដែលនាំអោយមានការចាប់ខ្លួនជនជាប់សង្ស័យនោះ ។

៤ : ជោគវាសនារបស់ជនដែលត្រូវគេចាប់ខ្លួន ត្រូវបានចាត់ចែង តាមលក្ខន្តិកៈនៅក្នុងមាត្រា១៣ នៃបទបញ្ញត្តិនេះ ។

៥ : ម្យ៉ាងទៀត តាមដីកាបង្គាប់អោយឡើងសាលារបស់រដ្ឋអាជ្ញា ឬ ចៅក្រម នគរបាលអាចនាំខ្លួនជនគ្រប់រូប ដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកាកោះ មកបង្ហាញខ្លួនចំពោះមុខនាយនគរបាល ឬចៅក្រម ឬរដ្ឋអាជ្ញា។ ក្រោយពីតុលាការបានសាកសួរហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់ លើកលែងតែក្នុងករណីមានភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី ១៣ នៃបទបញ្ញត្តិនេះ ។

## មាត្រា ២០ : ការឆែកឆេរក្នុងផ្ទះ

១ : ក្នុងករណីបទល្មើសជាក់ស្តែង នគបាលអាចធ្វើការឆែកឆេរ ។

២ : ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងសាក្សីពីរនាក់ ហើយបើអាចធ្វើបាន សាក្សី គួរយកអ្នកនៅជិតខាង ឬ អ្នកម្ចាស់ផ្ទះ ។

៣ : បើមិនមែនជាបទល្មើសដែលគេទាន់ជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមានសេចក្តីអនុញ្ញាតអំពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬ ពីរដ្ឋអាជ្ញា ។ ការឆែកឆេរទាំងនេះអាចធ្វើបានតែក្នុងចន្លោះម៉ោង ៦ ព្រឹក ទៅម៉ោង ៦ ល្ងាច ។ ហើយបើអាចធ្វើបាន ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងចំពោះមុខសាក្សីពីរនាក់ ដែលជ្រើសយកពីក្នុងចំណោមសមាជិកគ្រួសារជនជាប់សង្ស័យ ។ ភ័ស្តុតាងទាំងឡាយណា ដែលបានមកដោយរំលោភនឹងមាត្រានេះ មិនអាចយកជាការបានឡើយ ក្នុងពិធីកាត់សេចក្តី ។

## មាត្រា ២១ : កំណត់ពេល

១ : គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តី យ៉ាងយូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃចាប់ខ្លួន ។

២ : ទីប្រឹក្សា ឬ មេធាវីត្រូវបានទទួលដំណឹង ១៥ ថ្ងៃ មុនថ្ងៃជំនុំជំរះក្តីខ្លួន ។

## មាត្រា ២២ : ការដោះលែងដោយមូលហេតុខុសនីតិវិធី

១ : ការមិនបានគោរពតាមនីតិវិធីដែលចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នាំអោយដោះលែងជនជាប់ចោទ អោយមានសេរីភាពជាបន្ទាន់ ប្រសិនបើការខុសឆ្គងនោះ ធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិនៃការការពារ ។ ការប្រគល់សេរីភាពជាបន្ទាន់នេះ អាចធ្វើឡើងតាមសេចក្តីសុំរបស់ទីប្រឹក្សានៃជនជាប់ចោទ ឬមន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល, ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ ដល់ថ្ងៃដែលបទបញ្ញត្តិនេះបានចូលជាធរមាន ជនជាប់ឃុំឃាំង ឬជាប់ព័ន្ធនាគារទាំងអស់ ត្រូវមានសំណុំរឿងសមស្របតាមលក្ខខណ្ឌនៃបទបញ្ញត្តិនេះ សំរាប់ត្រួតពិនិត្យជាបន្ទាន់ពីសំណាក់ចៅក្រម រដ្ឋអាជ្ញា ឬភ្នាក់ងារដែលមានការអនុញ្ញាតរបស់អ៊ុនតាក់ ។ បើគ្មានសំណុំរឿងបែបនេះទេ ជនទាំងនោះនឹងត្រូវបាន

ដោះលែងអោយមានសេរីភាព តាមសេចក្តីសុំរបស់ទីប្រឹក្សា, មន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល, ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ចៅក្រម ឬ រដ្ឋអាជ្ញា ។

២ : ការរំលោភ ពីសំណាក់ភ្នាក់ងារសាធារណៈ លើសិទ្ធិបុគ្គល ដូចមានចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នៃបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៥៧ ។

## មាតិកា បី : ពិធីកាត់ក្តី

### មាត្រា ២៣ : ការជំនុំជំរះជាអសាធារណៈ

ការកាត់ក្តីទាំងអស់ត្រូវតែធ្វើជាសាធារណៈ លើកលែងតែអ្នករងគ្រោះ ឬ សិទ្ធិវ័ន្តរបស់គេស្នើសុំអោយជំនុំជំរះជាអសាធារណៈ ហើយចៅក្រមយល់ព្រមផង ។

### មាត្រា ២៤ : មធ្យោបាយបង្ហាញភ័ស្តុតាង

១ : សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងបុគ្គលិកនគរបាលផង ត្រូវតែ បាននិយាយជូនតុលាការស្តាប់ ។ សាក្សីទាំងឡាយអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ, ជនជាប់ចោទ ឬ ទីប្រឹក្សារបស់គេ ហើយនឹងពីសំណាក់រដ្ឋអាជ្ញា ។

២ : ភ័ស្តុតាំងទាំងអស់អាចលើកមកជជែកវែកញែកបាននៅពេលជំនុំជំរះ ដោយរួមទាំងរបាយការណ៍នគរបាលផង ដែលមិនអាចចាត់ទុកថាជាភ័ស្តុតាងដែលច្រានចោលមិនបាននោះទេ ។

៣ : បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភ័ស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចទុកជាមូលដ្ឋានសំរាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំ តាមបែបណាមួយក៏ដោយត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើសុំទៅចៅក្រម ដោយទីប្រឹក្សារបស់ជនជាប់ចោទ នៅមុនពេលកាត់ក្តី ។

៤ : អ្នកការពារចុងចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥ : សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំអោយបង្ហាញខ្លួនចំពោះមុខតុលាការ តាមរយៈដីកានាំខ្លួនរបស់តុលាការ ដោយត្រូវពិន័យជាប្រាក់ពី ១០០,០០០ ទៅ ១,០០០,០០០ រៀល បើមិនព្រមប្រព្រឹត្តតាម ។

## មាត្រា ២៥ : ការសន្មត់ជាមុនថាគ្មានទោស

គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទ ត្រូវទទួលការសន្មត់ជាមុនថា គ្មានកំហុសជាដាច់ខាត ។

## មាត្រា ២៦ : អំពីសាលក្រម

១ : គ្រប់សាលក្រមព្រហ្មទណ្ឌត្រូវប្រកាស «ក្នុងនាមប្រជាជាតិកម្ពុជា» សាលក្រមត្រូវចង្អុលអំពើដែលចោទប្រកាន់លើជនជាប់ចោទ ចង្អុលសាក្សី ឬ ភស្តុតាង ដែលចាត់ទុកជាត្រឹមត្រូវ ហើយដែលមានចែងមូលហេតុច្បាស់លាស់ ក្នុងការផ្តន្ទាទោស ។

២ : សាលក្រមដែលមានមូលហេតុច្បាស់លាស់ស្តីពីការផ្តន្ទាទោស និងសេចក្តីវិនិច្ឆ័យត្រូវអានទៅក្នុងពេលសវនាការ ។ សេចក្តីចម្លងសាលក្រមមួយច្បាប់ នឹងចែកជូនដល់ភាគីទាំងអស់ តាមសេចក្តីសុំរបស់គេ ។

## មាត្រា ២៧ : ការតាំងខ្លួនជាភាគីរដ្ឋប្បវេណី

១ : ជនរងគ្រោះ ឬ សិទ្ធិវន្តរបស់ជនរងគ្រោះទាំងឡាយ ដោយផ្ទាល់ ឬតាមរយៈទីប្រឹក្សា អាចតាំងខ្លួនជាភាគីរដ្ឋប្បវេណី នៅពេលអង្កេតស៊ើបសួរ ឬពេលសវនាការជំនុំជំរះ ដើម្បីទារសំណងជម្ងឺចិត្តពីអ្នកប្រព្រឹត្ត ឬដៃគូអ្នកប្រព្រឹត្តបទល្មើស និងអ្នកសមគំនិតក្នុងបទល្មើស ។ ទីប្រឹក្សារបស់អ្នកទាំងនោះ មានសិទ្ធិពិនិត្យសំណុំរឿង ដូចជនជាប់ចោទដែរ ។

២ : ជនប្រព្រឹត្តបទល្មើស និងអ្នកសមគំនិត ត្រូវទទួលខុសត្រូវរួម ក្នុងការជួសជុល ឬសងជំងឺចិត្ត ក្នុងលក្ខណៈទាំងឡាយដែលឆ្លើយតបទៅនឹងការតម្រូវនៃ *សេចក្តីថ្លែងការណ៍ ស្តីអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ ទាក់ទិនទៅនឹងជនរងគ្រោះពីបទឧក្រិដ្ឋ និងជនរងគ្រោះពីការរំលោភអំណាច* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រា ២៨ : បទល្មើសក្នុងការសំដែងមតិ

១ : គ្មានជនណាម្នាក់ត្រូវគេឃាឃាំងខានពីរឿងមតិនយោបាយ ជំនឿសាសនា និងពីការដែលខ្លួនជាប់ពូជសាសន៍ ឬជាតិពន្ធណាមួយឡើយ ។

២ : ច្បាប់ព្រហ្មទណ្ឌទាំងឡាយ ដែលមានជាធរមានសព្វថ្ងៃទូទាំងប្រទេសកម្ពុជា មិនអាចយកមកសំអាងលើបទល្មើសក្នុងការសំដែងមតិនយោបាយ ឬបទល្មើសមនោគមន៍វិជ្ជាទៀតឡើយ ហើយត្រូវទុកជានិរាករណ៍ ។

## មាត្រា ២៩ : ការពិនិត្យសារឡើងវិញលើរឿងក្តីខ្លះ

ជនដែលត្រូវបានជំនុំជំរះរួចហើយក្តី អាច ដោយខ្លួនឯង ឬតាមរយៈទីប្រឹក្សា ឬមេធាវី សុំអោយសើរើពិនិត្យរឿងក្តីសារជាថ្មី បើសិនជាយល់ថាខ្លួនត្រូវគេផ្តន្ទាទោសក្នុងមូលដ្ឋានគំនិតមតិ, សេចក្តីថ្លែងការណ៍, ការដែលខ្លួនជាប់ ឬមិនជាប់ពូជសាសន៍, ជាតិពន្ធ, សាសនា, នយោបាយ និង សង្គម ។

## មាត្រា ៣០ : អាជ្ញាយុកាល

អាជ្ញាយុកាលសំរាប់បទមជ្ឈិមមានរយៈពេលបីឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទឧក្រិដ្ឋមានរយៈពេលដប់ឆ្នាំ។ អាជ្ញាយុកាលត្រូវចប់នៅពេលណាសកម្មភាពនីតិវិធីទាំងអស់បានសម្រេច ។

# មាតិកា បួន : បទឧក្រិដ្ឋ

## មាត្រា ៣១ : ឃាតកម្មគិតទុកជាមុន

១ : ជនណាដែលសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬ ដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាដគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ២០ឆ្នាំ ។

២ : ការគិតទុកជាមុន គឺគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់ គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ ។

## មាត្រា ៣២ : អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនាដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា ៣១ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី ៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៣ : បទរំលោភសេពសន្ថវៈ

១ : ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀតទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

២ ៖ បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬ ដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬ ជនមានសតិវិបល្លាស ឬ ពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើនាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនដែលមានអំណាចលើអ្នករងគ្រោះទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៤ ៖ អំពើប្លន់

១ ៖ ជនណាដែលបានលួច ឬប៉ុនប៉ងនឹងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះ ៖

- ការលួចធ្វើដោយអំពើហិង្សា, មានអាវុធ ឬឥតអាវុធ, បណ្តាល ឬមិនបណ្តាលឲ្យមានរបួស

- ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយមានគាស់ទំលុះទំលាយ, ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២ ៖ អំពើលួចប្លន់គឺការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

## មាត្រា ៣៥ ៖ ការបង្ខាំងមនុស្សដោយខុសច្បាប់

ជនណាដោយគ្មានបញ្ជាពីអាជ្ញាធរតុលាការបានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស ៖

- ដាក់គុកជាបទឧក្រិដ្ឋ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬ ការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ

- ដាក់គុកពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈតិចជាង ១ខែ

## មាត្រា ៣៦ : ក្រុមជនប្រដាប់អាវុធ

គ្រប់ជនដែលបានចូលរួមសមាគមមួយ ដែលមានការចាត់តាំង ឬក្នុងការព្រមព្រៀងគ្នាមួយដោយមានសម្ភារៈនៃហេតុមួយ ឬច្រើន ដើម្បីនឹងរៀបចំការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ឬបទមជ្ឈិមមួយ ឬច្រើន ប្រឆាំងនឹងមនុស្សឬសម្បត្តិទ្រព្យទាំងឡាយ ត្រូវផ្តន្ទាជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៧ : ការកេងបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ

១ : ជនជាតំណាងជាប់ឆ្នោត អ្នករដ្ឋការស៊ីវិល និង យោធាទាំងអស់ គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ នៃកម្ពុជាទាំងបួន នៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវខាងនយោបាយដែលក្នុងក្របខ័ណ្ឌមុខងារខ្លួន ឬ ក្នុងឱកាសបំពេញមុខងារនេះ បានយកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន, លក់, ជួល, កេងបំបាត់ជាប្រយោជន៍ខ្លួន ឬ ជាប្រយោជន៍តតិយជនណាមួយនូវសម្បត្តិទ្រព្យ សេវាកម្ម ប្រាក់កាស បុគ្គលិក ផលប្រយោជន៍ ឯកសារ សេចក្តីអនុញ្ញាត ឬមុខងារដែលជារបស់សមូហភាពណាមួយធ្វើជាកម្មសិទ្ធិ ឬជាសិទ្ធិអាស្រ័យផល ត្រូវមានទោសពីបទឧក្រិដ្ឋកេងបំបាត់សម្បត្តិសាធារណៈ ហើយត្រូវផ្តន្ទាទោសដាក់គុកពីបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២ : ជនណាដែលបានប្រព្រឹត្តបទល្មើសខាងលើនោះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងអាចត្រូវហាមឃាត់មិនឲ្យឈរឈ្មោះបោះឆ្នោត ឬមិនឲ្យកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈក្នុងរយៈពីរឆ្នាំ ក្រោយពីបានរងទោសរបស់ខ្លួនរួចហើយ ។

៣ : ម្យ៉ាងទៀត ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ស្មើនឹងពីរដងនៃតម្លៃទ្រព្យសម្បត្តិ ឬទឹកប្រាក់ដែលបានកេងបំបាត់ដោយបន្លំនោះ ។

## មាត្រា ៣៨ : ការស៊ីសំណូក

១ : ដោយមិនគិតដល់ទណ្ឌកម្មខាងវិស័យជាយថាហេតុ គ្រប់អ្នករដ្ឋបាលស៊ីវិល ឬយោធា គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវនយោបាយដែលស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬទទួល ឬប៉ុនប៉ងនឹងទទួល ក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ ក្នុងឱកាសបំពេញការងារ នូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គល មុខងារ ឯកសារ សេចក្ដីអនុញ្ញាត ឬ ផលប្រយោជន៍អ្វីមួយ ជាថ្នូរនៃរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គឺបានប្រព្រឹត្តបទឧក្រិដ្ឋស៊ីសំណូកអកម្ម ហើយត្រូវផ្ដន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ៧ឆ្នាំ ។

២ : ជនដែលបានប្រព្រឹត្តបទល្មើសខាងលើនោះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងអាចហាមឃាត់មិនឲ្យឈរឈ្មោះក្នុងអាណត្តិនៃការបោះឆ្នោត ឬមិនឲ្យកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈ ក្នុងរយៈពេលពីរឆ្នាំ ក្រោយពីបានរងទោសរបស់ខ្លួនរួចហើយ ។

៣ : ម្យ៉ាងទៀត ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ នឹងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ស្មើនឹងពីរដងនៃតម្លៃទ្រព្យសម្បត្តិ ឬ ទឹកប្រាក់ដែលបានគៃបំបាត់ដោយបន្លំនោះ ។

## មាត្រា ៣៩ : ជំនួញគ្រឿងញៀនខុសច្បាប់

១ : លើកលែងតែមានការបញ្ជាផ្ទុយ ក្នុងមូលហេតុសុខភាពសាធារណៈ ដោយមានការយល់ព្រមពីមន្ទីរសុខាភិបាលសាធារណៈ នៃរចនាសម្ព័ន្ធរដ្ឋបាលនីមួយៗដែលមានសព្វថ្ងៃ ការផលិត ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការរក្សាទុក ជំនួន ការផ្ទេរសម្បត្តិឲ្យ ការទទួលយក និង ការប្រើប្រាស់រុក្ខជាតិមានជាតិពុល គ្រឿងញៀន នឹង គ្រឿងស្រវឹង ដែលមានរាយក្នុងបញ្ជីកំណត់របស់អនុសញ្ញាសហប្រជាជាតិស្ដីអំពីការប្រឆាំងនឹងជំនួញខុសច្បាប់នៃគ្រឿងញៀន និង គ្រឿងស្រវឹង ចុះថ្ងៃទី ២០ ធ្នូ ១៩៨៨, ថ្ងៃទី ២៧ មិនា ១៩៧២, ថ្ងៃទី ២១ កុម្ភៈ ១៩៧១ និងថ្ងៃទី ៣០ មិនា ១៩៦១ ត្រូវហាមឃាត់នៅក្នុងដែនដីកម្ពុជាទាំងមូល ។

២ : ជនដែលប្រព្រឹត្តបទល្មើសនឹងមាត្រានេះ ត្រូវផ្ដន្ទាទោសដាក់គុកតម្រូវឲ្យធ្វើការពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ម្យ៉ាងទៀតសារជាតិហាមឃាត់ទាំងអស់ត្រូវរឹបអូស ហើយតុលាការបញ្ជាឲ្យ

បំផ្លាញចោល ក្រោយពីបានធ្វើវិភាគហើយ ។

## មាតិកា ប្រាំ : បទល្មើសមជ្ឈិម

### មាត្រា ៤០ : អំពើមនុស្សឃាតដោយអចេតនា

ជនណា ដោយខ្វះការប្រុងប្រយ័ត្ន ដោយការធ្វេសប្រហែស ដោយមិនប្រយ័ត្ន ឬ ដោយមិនគោរពតាមបទបញ្ជា ធ្វើអោយស្លាប់ជនម្នាក់ទៀតដោយគ្មានចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយអចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

### មាត្រា ៤១ : អំពើបង្ករបួសដោយចេតនា

ជនណាវាយតប់ បណ្តាលអោយមានរបួស ដែលនាំអោយពិការជាអចិន្ត្រៃយ៍ ឬ ពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី ៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

- បើពិការភាពបណ្តោះអាសន្ននោះតិចជាង ៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី ៦ខែ ដល់ ២ឆ្នាំ ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាគឺដាក់គុកពី ២ខែ ទៅ ១ឆ្នាំ ។
- បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។

## មាត្រា ៤២ : អំពើបៀតបៀនផ្លូវភេទ

១ : ជនណាដែលបៀតបៀនផ្លូវភេទនៃជនណាម្នាក់ទៀត ដែលមានភេទដូចគ្នា ឬមិនដូចគ្នា ដោយប្រព្រឹត្តទៅលើជននោះ តាមការស្ទាប អង្អែល ឬ អំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនផ្លូវភេទ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

២ : បើការបៀតបៀនផ្លូវភេទនោះ ធ្វើឡើងដោយការបង្ខំ ដោយអំពើហិង្សា ដោយការគំរាមកំហែង, បើអ្នករងគ្រោះមានអាយុតិចជាង ១៦ឆ្នាំ ឬ អ្នកប្រព្រឹត្តអំពើនោះជាអ្នកមានអំណាចលើជនរងគ្រោះ ការផ្តន្ទាទោសត្រូវទ្វេមួយជាពីរ ។

៣ : នឹងត្រូវផ្តន្ទាទោសដាក់គុកពី ២ឆ្នាំ ទៅ ៦ឆ្នាំដែរ ចំពោះជនណាដែលបានល្បួង, អូសទាញ ឬបង្វែងគំនិតអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជននោះបើមានការព្រមព្រៀងក៏ដោយ ។

## មាត្រា ៤៣ : អំពើចោរកម្ម

គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយពុំមានស្ថានទម្ងន់ទោសដូចមានចែងក្នុងមាត្រា៣៤ ត្រូវមានទោសពីបទលួច ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៥ឆ្នាំ ។

## មាត្រា ៤៤ : បទល្មើសទាក់ទងទៅនឹងសម្បត្តិវប្បធម៌

១- គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិវប្បធម៌ដែលជារបស់រដ្ឋ ឬរបស់ឯកជនជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយសម្បត្តិវប្បធម៌នោះចូលជាបេតិកភ័ណ្ឌជាតិកម្ពុជា ត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ១០ឆ្នាំ ។ ជនណាដែលនាំចេញ ឬប៉ុនប៉ងនឹងនាំចេញ ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដោយខុសច្បាប់ ត្រូវមានទោសដូចគ្នា ។

២- តាមគោលបំណងនៃបទបញ្ញត្តិនេះ សម្បត្តិវប្បធម៌ គឺសម្បត្តិទាំងឡាយដែលកំណត់ដោយ *អនុសញ្ញារបស់អ៊ុយណេស្កូ ស្ដីអំពីវិធានការដែលត្រូវចាត់ ដើម្បីហាមឃាត់ និងរារាំងការនាំចូល, ការនាំចេញ និងការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ ដោយខុសច្បាប់* ចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧០ ដែលប្រទេសកម្ពុជាបានអោយសច្ចានុម័តនៅថ្ងៃទី ២៦ កញ្ញា ១៩៧២ ។ ដែលសន្មតថាជាបេតិកភ័ណ្ឌជាតិកម្ពុជា គឺសម្បត្តិវប្បធម៌ទាំងអស់ ដែលមិនបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឬ អង្គការចាត់តាំងដើម្បីគោលបំណងនេះ ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះ អោយផ្ទេរ ឬ នាំចេញ ។

៣ : ការធ្វើអោយខូចគុណភាពដោយចេតនា នូវសម្បត្តិវប្បធម៌ដែលជាបេតិកភ័ណ្ឌជាតិកម្ពុជា ដោយការរុករកគ្មានការអនុញ្ញាត ឬដោយលួចលាក់, ដោយអំពើបំផ្លិចបំផ្លាញ ឬដោយមធ្យោបាយផ្សេងទៀត នឹងត្រូវមានទោសដូចគ្នា ។

## មាត្រា ៤៥ : អំពើឆបោក

ជនណាដែលធ្វើអោយគេអោយមកខ្លួន ឬប៉ុនប៉ងធ្វើអោយគេអោយមកខ្លួន នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកនៃទ្រព្យសម្បត្តិរបស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដោយប្រើល្បិចបន្លំ ឬក្លែងឈ្មោះ ឬក្លែងគុណភាព ដើម្បីបញ្ឆេះបញ្ឆូលជនរងគ្រោះ អោយជឿតាមអំណាចក្នុងការស្រម័យ ឬដោយធ្វើអោយជនរងគ្រោះខ្លាច ឬសង្ឃឹមលើព្រឹត្តិការណ៍អ្វីមួយ ត្រូវមានទោសមជ្ឈឹមពីបទឆបោក ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៤៦ : ការរំលោភលើសេចក្ដីទុកចិត្ត

ជនណាដែលគេបន្លំ ឬបំបាត់ អោយខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬគ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់អោយមកខ្លួន ក្នុងលក្ខណៈជាការជួល ជាការដាក់ដឹកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស, ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ត្រូវមានទោសមជ្ឈឹមពីបទរំលោភលើទំនុកចិត្ត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៤៧ : អំពើក្លែងត្រា ក្រដាសប្រាក់ ផលប័ត្រសាធារណៈ និង ដែកបោះ, តែមប្រៃ និង ម៉ាកសញ្ញាផ្សេងៗ

១ : ជនណាដែលបានក្លែងត្រារបស់រចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬប្រើប្រាស់ត្រាក្លែងក្លាយទាំងនោះ,

២ : ជនណាដែលក្លែង ឬបន្លំក្រដាសប្រាក់, តែមប្រៃប្រៃសណីយ៍, និមិត្តសញ្ញា, ធនប័ត្រ, ភាគហ៊ុន, កាតព្វកិច្ច ឬវិបឹយវត្ថុដែលប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់នៅក្នុងប្រទេសកម្ពុជា លិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណនៃរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬដែលបានប្រើប្រាស់ ឬបាននាំយករបស់ទាំងនោះចូលមកក្នុងដែនដីនៃប្រទេសកម្ពុជា,

៣ : ជនណាដែលបានក្លែងឬបន្លំក្រដាសប្រាក់ តែមប្រៃប្រៃសណីយ៍ និមិត្តសញ្ញា, ធនប័ត្រ, ភាគហ៊ុន, សញ្ញាប័ណ្ណ ឬវិបឹយវត្ថុដែលប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់នៅប្រទេសក្រៅ, លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណនៃប្រទេសក្រៅណាមួយ ឬដែលបានប្រើប្រាស់ ឬបាននាំយករបស់ទាំងនោះចូលមកក្នុងដែនដីនៃប្រទេសកម្ពុជា,

ត្រូវមានទោសមជ្ឈិមពីបទក្លែងបន្លំ ហើយផ្តន្ទាទោសដាក់គុកពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៤៨ : អំពើក្លែងកម្មសិទ្ធិនៃបញ្ញា

១ : ការបោះពុម្ពផ្សាយគ្រប់ជំពូក នូវអត្ថបទសរសេរ, ការតែងបទភ្លេង, គំនូរ, វិចិត្រកម្ម, ខ្សែភាពយន្ត, រូបថត ឬផលិតកម្មបោះពុម្ព ឬ ចម្លាក់ផ្សេងៗទាំងអស់ ដោយរំលោភសិទ្ធិនៃបញ្ញារបស់អ្នកនិពន្ធ គឺជាការក្លែងបន្លំ ។

២ : គ្រប់ការនាំចូល ឬនាំចេញ, គ្រប់ផលិតកម្មចម្លង ការសំដែង ឬការផ្សាយផលិតកម្មចម្លងនៃស្នាដៃខាងផ្លូវគំនិត ដោយរំលោភសិទ្ធិអ្នកនិពន្ធ គឺជាការក្លែងបន្លំមួយដែរ ។

៣ : សិទ្ធិរបស់អ្នកនិពន្ធដែលបទបញ្ញត្តិនេះយោងដល់  គឺសិទ្ធិដែលការពារដោយអនុសញ្ញាក្រុងប៊ែន ចុះថ្ងៃទី ៩ កញ្ញា ១៨៨៦, ពិនិត្យឡើងវិញនៅក្រុងប៉ារីស ថ្ងៃទី ២៤ កក្កដា ១៩៧១ និងដោយអនុសញ្ញាជាសាកលស្តីអំពីសិទ្ធិអ្នកនិពន្ធ ដែលចុះហត្ថលេខានៅហ្សឺណែវ ថ្ងៃទី ៦ កញ្ញា ១៩៥២ ហើយពិនិត្យឡើងវិញនៅប៉ារីស ថ្ងៃទី ២៤ កក្កដា ១៩៧១ ។

## មាត្រា ៤៩ : ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ

គ្រប់ជនជ្រើសតាំងដោយការបោះឆ្នោត, គ្រប់អ្នករដ្ឋការស៊ីវិល ឬយោធា, គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណៈបក្សនយោបាយដែលបានចុះក្នុងបញ្ជី, អ្នកទទួលខុសត្រូវរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬ របស់គ្រប់គណៈបក្សនយោបាយដែលបានចុះក្នុងបញ្ជី ដែលក្នុងការបំពេញមុខងាររបស់ខ្លួន បានប្រព្រឹត្តបទក្លែង ដោយក្លែងហត្ថលេខា ឬដោយលួចកែលិខិតផ្លូវការ, កែអក្សរ ឬកែហត្ថលេខា, ដោយសន្មតជនម្នាក់ថាជាជនម្នាក់ទៀត, ដោយធ្វើអក្សរ ឬសិកបញ្ចូលអក្សរលើបញ្ជី ឬលិខិតសាធារណៈឯទៀតៗ, ចាប់ពីការធ្វើ ឬការបញ្ចប់បញ្ជី ឬលិខិតសាធារណៈទាំងនោះ, អ្នកណាដែលបានប្រើប្រាស់ ដោយដឹងខ្លួន នូវរបស់ក្លែងបន្លំអស់ទាំងនេះ នឹងត្រូវមានទោសឧក្រិដ្ឋពីបទក្លែងលិខិតសាធារណៈ ហើយត្រូវផ្ដន្ទាទោសពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៥០ : ការក្លែងបន្លំលិខិតឯកជន, លិខិតពាណិជ្ជកម្ម ឬលិខិតធនាគារ

១ : ជនណាបានប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្តការក្លែងលិខិតឯកជន, លិខិតពាណិជ្ជកម្ម ឬលិខិតធនាគារ តាមមធ្យោបាយណាមួយនៃមធ្យោបាយដែលបានចែងនៅក្នុងមាត្រា៤៩ នឹងត្រូវផ្ដន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ រៀល ទៅ ១០,០០០,០០០ រៀល ។

២ : ជនណាដែលបានប្រើប្រាស់ ដោយដឹងខ្លួននូវ លិខិតឯកជនក្លែង, លិខិតពាណិជ្ជកម្មក្លែង និង លិខិតធនាគារក្លែង នឹងត្រូវផ្ដន្ទាទោសដូចគ្នា ។

## មាត្រា ៥១ : អំពើទទួលផលចោរកម្ម

ជនណាដែលទទួល ឬទិញទ្រព្យសម្បត្តិដែលខ្លួនបានដឹងថា ទ្រព្យសម្បត្តិនោះបានមកអំពីអំពើចោរកម្ម, ពីការឆបោក ឬមកអំពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ ត្រូវមានទោសមជ្ឈិម

ពីបទទទួលផលចោរកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។ អំពើទទួលផលចោរកម្ម ជាបទល្មើសមិនចេះរលត់ ដែលអាយុកាលឈប់ចោទប្រកាន់ *(អាជ្ញាយុកាល)* របស់វាចាប់ផ្តើមនៅថ្ងៃណាដែលការទទួលផលចោរកម្មនេះបានចប់ ។

## មាត្រា ៥២ : ការធ្វើអោយខូចខាតដោយចេតនា

ជនណាដែលធ្វើអោយខូចខាត ឬប៉ុនប៉ងធ្វើអោយខូចខាត ដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ត្រូវមានទោសមជ្ឈិមពីបទធ្វើអោយខូចខាតដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។ បើការខូចខាតនោះមានលក្ខណៈស្រាល ឬទ្រព្យនោះមានតំលៃតិចតួច ទោសដាក់គុកត្រូវបញ្ចុះមកត្រឹម ២ខែ ទៅ ១ឆ្នាំ ។ ការធ្វើអោយខូចខាតសម្បត្តិវប្បធម៌ ដែលជាបេតិកភ័ណ្ឌជាតិកម្ពុជា ត្រូវមានទោសតាមមាត្រា ៤៤ ។

## មាត្រា ៥៣ : អំពើបង្កអគ្គីភ័យដោយចេតនា

១ : ជនណាដែលធ្វើអោយខូចខាត ឬប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនា នូវទ្រព្យសម្បត្តិអ្នកដទៃ ដោយបង្កអគ្គីភ័យ ឬដោយប្រើជាតិផ្ទុះ ត្រូវមានទោសមជ្ឈិមពីបទបង្កអគ្គីភ័យដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

២ : បើទ្រព្យដែលភ្លើងឆេះនោះ ជាទ្រព្យដែលមានមនុស្សអាស្រ័យនៅពី ១នាក់ ទៅច្រើននាក់ ក៏រឹតកំណត់ទណ្ឌកម្មនឹងត្រូវទ្វេមួយជាពីរ ។

## មាត្រា ៥៤ : ការកាន់អាវុធ ឬដឹកជញ្ជូនអាវុធដែលហាមឃាត់

១ : ជនណាដែលកាន់ ឬ ដឹកជញ្ជូនកាំភ្លើង, គ្រឿងផ្ទុះ ឬ អាវុធយុទ្ធភ័ណ្ឌ ដោយគ្មានការអនុញ្ញាតតាមល័ក្ខខ័ណ្ឌកំណត់តាមការណែនាំរបស់អ៊ុនតាក់ ស្តីអំពីការរក្សាទុក និងការកាន់កាប់អាវុធ ត្រូវមានទោសពីបទកាន់អាវុធ ឬដឹកជញ្ជូនអាវុធហាមឃាត់ដោយខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៣ឆ្នាំ ។

២ : គ្រប់ជនគ្មានឯកសណ្ឋានប្រដាប់អាវុធ ត្រូវមានលទ្ធភាពបង្ហាញដល់អាជ្ញាធរ ដែលត្រួតពិនិត្យទាំងអស់ ជាអាទិតីភ្នាក់ងារ អ៊ុនតាក់ នូវលិខិតអនុញ្ញាតអោយកាន់អាវុធរបស់ខ្លួន ។ បើគ្មានលិខិតអនុញ្ញាតទេ អាវុធនោះត្រូវរឹបអូស និងបំផ្លាញចោលភ្លាម ហើយរបាយការណ៍មួយ ដែលមានតម្លៃដូចកំណត់ហេតុ ត្រូវសរសេរជូនដល់អាជ្ញាធរតុលាការមានសមត្ថកិច្ច ។

## មាត្រា ៥៥ : ការគៀបសង្កត់លើសាក្សី

ជនណាដែលគំរាមកំហែង, សំឡុត ឬធ្វើការគៀបសង្កត់លើសាក្សីណាមួយ ក្នុងនីតិវិធីតុលាការ ត្រូវមានទោសមជ្ឈិមពីបទសំឡុត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ២ឆ្នាំ ។

## មាត្រា ៥៦ : សក្ខីភាពក្លែងក្លាយ.

ជនណាដែលបានបង្ហាញនូវសក្ខីភាពក្លែងក្លាយ ក្នុងនីតិវិធីតុលាការ ដោយបង្ហាញនូវហេតុផលដែលខ្លួនដឹងថាភាន់ច្រឡំ ឬមិនពិត ហើយដែលក្រោយមកតុលាការទទួលស្គាល់ថាដូច្នោះមែន ត្រូវមានទោសពីបទធ្វើសក្ខីភាពក្លែងក្លាយ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ២ឆ្នាំ ។

## មាត្រា ៥៧ : អំពើរំលោភលើសិទ្ធិបុគ្គល

គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរួញរាទៅលើសិទ្ធិបូរណាភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៥៨ : អំពើសូកប៉ាន់

ជនណាដែលសូក ឬប៉ុនប៉ងសូក គ្រប់អ្នកតំណាងជាប់ឆ្នោត គ្រប់អ្នករដ្ឋការស៊ីវិល និងយោធា គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀង

ប៉ារីស ឬគ្រប់គណៈបក្សនយោបាយដែលបានចុះឈ្មោះក្នុងបញ្ជី ក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងារអស់ទាំងនេះ ដោយសន្យាប្រគល់ដល់អ្នកទាំងនោះ នូវទ្រព្យសម្បត្តិ, សេវាកម្ម, ប្រាក់, បុគ្គលិក, មុខងារ, ឯកសារ, សេចក្តីអនុញ្ញាត ឬក៏រៃអ្វីមួយជាថ្នូរ ដើម្បីអោយបានរបស់ណាមួយក្នុងចំណោមរបស់ទាំងនោះ គឺជាការប្រព្រឹត្តបទមជ្ឈិមសូកប៉ាន់សកម្ម ហើយត្រូវមានទោសជាប់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

## មាត្រា ៥៩ : ការញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋដោយបានសំរេចផល

នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ថាជាបទឧក្រិដ្ឋតាមបទបញ្ញត្តិនេះ ជនទាំងឡាយណាដែល តាមរយៈសន្ទរកថា, តាមសម្រែក ឬ ការគំរាមកំហែង បន្ទរឡើងក្នុងកន្លែងនានាឬ ក្នុងទីប្រជុំជនសាធារណៈ, តាមការសរសេរ, ការបោះពុម្ព, គំនូរ, ចម្លាក់, វិចិត្រកម្ម, និម្មិតរូប, រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ, សំដី ឬរូបភាព ដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ, តាមផ្ទាំងបដា ឬប័ណ្ណប្រកាសដែលតាំងអោយសាធារណៈជនឃើញ, តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សន៍ បានបង្កដោយផ្ទាល់អោយមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសំរេចផល ។

លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ ។

## មាត្រា ៦០ : ការញុះញង់អោយប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិមដោយពុំបានសំរេចផល

ជនណា តាមមធ្យោបាយណាមួយដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ដែលបានញុះញង់ដោយផ្ទាល់អោយមានបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ដែលមានចែងក្នុងបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ក្នុងករណីណាដែលការញុះញង់នោះពុំបានសំរេចផល ។

## មាត្រា ៦១ : ការញុះញង់អោយមានការរើសអើង

១ : ជនណា តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ ដែលបានញុះញង់អោយមានសម្អប់ជាតិ, ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់អោយមានការរើសអើង, អរិភាព ឬហិង្សា នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ ទៅ ១០,០០០,០០០រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

២ : ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើន ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត ១០,០០០,០០០ រៀល ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈឹមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមដែលតាំងឡើងតាមវិធាន ដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៣ : ក្នុងករណីណាក៏ដោយ និយោជក, អ្នកបោះពុម្ភ, ក្រុមហ៊ុនបោះពុម្ភផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ ឬច្រើននាក់ ។

## មាត្រា ៦២ : ការផ្សាយពត៌មានមិនពិត

ពេលណាមានការចុះផ្សាយ, ការផ្សព្វផ្សាយ ឬការផ្សាយបន្ត តាមមធ្យោបាយណាក៏ដោយ នូវពត៌មានមិនពិត, ពត៌មានប្រឌិត, ពត៌មានក្លែងក្លាយ ឬដោយកុហក់ ទំលាក់កំហុសដោយអសុទ្ធចិត្តទៅលើជនទីបី ក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើអោយកើតកោលាហលដល់សន្តិសុខសាធារណៈ ឬអាចបណ្តាលអោយកើតកោលាហលដល់សន្តិសុខសាធារណៈ នាយក ឬអ្នកទទួលខុសត្រូវផ្សេងទៀតនៃការផ្សាយ ឬ អ្នកទទួលខុសត្រូវលើមធ្យោបាយតមនាគមន៍ឯទៀត

ដែលពាក់ព័ន្ធ ដែលបានសំរេចទទួលចុះផ្សាយ, ផ្សព្វផ្សាយ ឬ ផ្សាយបន្តនូវពត៌មានទាំងនោះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៣ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ ទៅ ១០,០០០,០០០ រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

## មាត្រា ៦៣ : ការបរិហាកេរ្តិ៍ និង ការជេរប្រមាថ

១ : គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្ត នូវអំពើជាកំណត់ណាមួយ ដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហាកេរ្តិ៍ ។ ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវនូវការពោលអះអាងនោះ ឬការទម្លាក់កំហុសនោះ ត្រូវមានទោស ទោះបីសំដៅទៅលើជនណាមួយដោយមិនចេញឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថា, តាមសម្រែក, តាមការគំរាមកំហែង, តាមការសរសេរ ឬតាមការបោះពុម្ព, តាមផ្ទាំងបដារឬប័ណ្ណប្រកាស, តាមការផ្សាយសោតទស្សនៈដែលជាប់ចោទ ។ គ្រប់ការពោលអះអាង ឬការទំលាក់កំហុស ដែលអ្នកនិពន្ធ, អ្នកសារពត៌មាន, អ្នកទទួលខុសត្រូវខាងការផ្សាយ, អ្នកទទួលខុសត្រូវខាងបោះពុម្ពផ្សាយ នាយកកម្មវិធី ដែលដឹងថាមិនពិតហើយ នៅតែផ្សាយ, បោះពុម្ពផ្សាយ, សរសេរ ឬ ផ្សព្វផ្សាយ ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺជាការបរិហារកេរ្តិ៍ ។

២ : គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ, ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

៣ : ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ ប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៨ថ្ងៃ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០រៀល ទៅ ១០,០០០,០០០រៀល ឬត្រូវផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

៤ : ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើន ដោយអោយជនជាប់ទោស

ទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត ១០,០០០,០០០ រៀល ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមដែលតាំងឡើងតាមវិធានដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៥ : ក្នុងករណីណាក៏ដោយ និយោជក, អ្នកបោះពុម្ព, ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ ឬច្រើននាក់ ។

## មាត្រា ៦៤ : ការបន្លំក្នុងការបោះឆ្នោត

ជនណាក៏ដោយ តាមការគំរាមកំហែង, ការឈ្លានពានលើរូបកាយ, ការបង្ខិតបង្ខំប្រភេទណាក៏ដោយ ធ្វើអោយប៉ះពាល់ដល់ការប្រព្រឹត្តដោយសេរីនៃសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ឬប៉ះពាល់ដល់ភាពត្រឹមត្រូវនៃប្រតិបត្តិការបោះឆ្នោតទាំងឡាយ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

## មាត្រា ៦៥ : ការប្រើប្រាស់គ្រឿងញៀន

ជនណា ដែលប្រើប្រាស់ ដោយផ្ទាល់ខ្លួន នូវរុក្ខជាតិមានជាតិពុល, គ្រឿងញៀន ឬសារជាតិទាក់ទិននឹងសរសៃប្រសាទ ដូចដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ក្នុងមាត្រា ៣៩ និងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ម្យ៉ាងទៀត សារជាតិហាមឃាត់ទាំងនេះនឹងត្រូវរឹបអូស ហើយតុលាការនឹងបញ្ជាអោយបំផ្លាញចោល ក្រោយពីធ្វើការវិភាគហើយ ។

# មាតិកា ប្រាំមួយ : អំពីទណ្ឌកម្ម

## មាត្រា ៦៦ : សមភាពនៃទណ្ឌកម្ម

គោលការណ៍សមភាពនៃពលរដ្ឋទាំងអស់ចំពោះមុខច្បាប់ព្រហ្មទណ្ឌ តម្រូវអោយទណ្ឌកម្មទាំងឡាយ ដែលត្រូវអនុវត្តន៍នៅប្រទេសកម្ពុជា មានភាពដូចគ្នានៅគ្រប់ខេត្ត ឬតំបន់។ ដូច្នេះ ទណ្ឌកម្ម ដែលមានចែងក្នុងបទបញ្ញត្តិនេះ ចាប់ពីពេលនេះតទៅ ត្រូវអនុវត្តនៅទូទាំងប្រទេសកម្ពុជា ។

## មាត្រា ៦៧ : ទោសប្រហារជីវិត

ទោសប្រហារជីវិតត្រូវបានលប់ចោលនៅប្រទេសកម្ពុជា ។

## មាត្រា ៦៨ : ស្ថានសំរាលទោស និង គ្រាប្រណីចំពោះអនីតិភាព

១ : ចៅក្រមទាំងឡាយត្រូវគិតដល់ស្ថានសំរាលទោស ដើម្បីបញ្ចុះទោសរហូតដល់ក្រោមអប្បបរិមា នៃទោសដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ហើយជាអាទិ៍គឺ ៖

- យុវភាពនៃអ្នកជាប់ទោស,
- ប្រវត្តិរូបផ្ទាល់នៃអ្នកជាប់ទោស ដែលមានលក្ខណៈអាចអោយបន្ថយភាពទទួលខុសត្រូវរបស់ខ្លួន,
- ស្ថានភាពចិត្តសាស្ត្រ ឬសរសៃប្រសាទនៃអ្នកត្រូវចោទ ដោយមានសញ្ញាប័ត្របញ្ជាក់ពីគ្រូពេទ្យខាងសរសៃប្រសាទ ឬគ្រូពេត្យខាងចិត្តសាស្ត្រ,
- កាលៈទេសៈនៃអំពើឧក្រិដ្ឋ ឬមជ្ឈិម ដែលបណ្តាលអោយអ្នកជាប់ទោសមានប្រតិកម្មដោយខានពុំបាន ។

២ : ចំពោះជនជាប់ចោទដែលមានអាយុតិចជាង ១៨ឆ្នាំ ទណ្ឌកម្មដែលមានក្នុងបណ្ដាមាត្រាមុនៗ ត្រូវកាត់បន្ថយពាក់កណ្ដាល នេះដោយមិនទាន់គិតដល់លក្ខន្តិកៈអនុគ្រោះផ្សេងៗលើសពីនេះទៀត ដែលមាននៅក្នុងបទដ្ឋានកំណត់ដោយរចនាសម្ព័នរដ្ឋបាលដែលមានសព្វថ្ងៃ ។

## មាត្រា ៦៩ : អំពើសមគំនិត

ជនណា ដែលបានផ្ដល់មធ្យោបាយសំរាប់ប្រព្រឹត្តបទល្មើស, ដែលបានអោយបញ្ជាអោយគេប្រព្រឹត្តបទល្មើស, ដែលបានសំរួលដល់ការប្រព្រឹត្តបទល្មើស នឹងត្រូវចាត់ទុកថាជាអ្នកសមគំនិត ហើយត្រូវផ្ដន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសនោះដែរ ។

## មាត្រា ៧០ : ការព្យួរទោស

ទោសជាប់ព័ន្ធនាគារ ប៉ុន្តែមិនមែនជាទោសឧក្រិដ្ឋបង្ខំអោយធ្វើការទេនោះ ជានិច្ចជាកាលតែងតែអាចនឹងត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនពុំបានប្រព្រឹត្តិបទល្មើសមួយផ្សេងទៀត ដែលមានចែងនៅក្នុងបណ្ដាមាត្រាមុនៗ ក្នុងរយៈពេល ៥ឆ្នាំ ក្រោយការកាត់ទោសរបស់ខ្លួន ។

## មាត្រា ៧១ : ការដោះលែងដោយមានល័ក្ខខ័ណ្ឌ

១ : ក្រោយពីបានរងទោសបានពាក់កណ្ដាលនៃទោសគុក ឬ ២ ភាគ ៣ នៃទោសគុកបង្ខំអោយធ្វើការ ជនជាប់គុក ឬជាប់គុកបង្ខំអោយធ្វើការ អាចទទួលផលនៃវិធានការមួយ ស្ដីពីការដោះលែងដោយមានល័ក្ខខ័ណ្ឌ តាមការកំណត់របស់តុលាការដែលកាត់ទោសខ្លួន ក្រោយពីបានយោបល់ពីអាជ្ញាធរព័ន្ធនាគារ ហើយប្រសិនបើតុលាការយល់ឃើញថា ការដោះលែងនេះអាចជួយសម្រួលដល់ការចូលរួបរួមក្នុងសង្គមវិញជាថ្មីរបស់ជនជាប់ទោស ។

២ : គ្រប់បទល្មើសកំណត់នៅក្នុងបណ្តាមាត្រាមុនៗ ដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងពេលដោះលែងដោយមានល័ក្ខខ័ណ្ឌនេះ នឹងបណ្តាលអោយមានការដាក់អនុវត្តន៍ជាបន្ទាន់ នូវទោសដែលនៅសល់ ។

### មាត្រា ៧២ : ការកំណត់អោយទុកប្រាក់ពិន័យ

គ្រប់ប្រាក់ពិន័យដែលទទួលក្នុងរយៈអន្តរកាលនេះ នឹងត្រូវដាក់ចូលទៅក្នុងគណនីបញ្ញើរ ចាំមួយ ក្រោមការទទួលខុសត្រូវរបស់ អ៊ុនតាក់ ដើម្បីទុកបង់ជូនអនាគតរដ្ឋាភិបាល ដែលកើតឡើងពីការបោះឆ្នោត ។

## មាតិកា ប្រាំពីរ : វិធានអនុវត្តន៍

### មាត្រា ៧៣ : ការទុកជានិរាករណ៍នៃវិធានដែលមិនស្របគ្នា

១ : គ្រប់អត្ថបទ, គ្រប់លក្ខន្តិកៈ, គ្រប់វិធានសរសេរ ឬមិនសរសេរ ដែលផ្ទុយនឹងបទបញ្ញត្តិនេះ, ទាំងខ្លឹមសារ ទាំងស្មារតី, ត្រូវទុកជានិរាករណ៍សុទ្ធសាធតែម្តង ។

២ : រចនាសម្ព័ន្ធរដ្ឋបាលនិមួយៗដែលមានសព្វថ្ងៃ សន្យាថានឹងអនុវត្ត តាមគ្រប់មធ្យោបាយ, ទាំងសម្ភារៈ និងបុគ្គលិក, ចាំបាច់ដើម្បី ក្នុងរយៈពេលយ៉ាងគួរបំផុត សម្របនូវអត្ថបទ និងការប្រតិបត្តិរបស់ខ្លួន តាមបទបញ្ញត្តិនេះ និងតាមឧបករណ៍ទាំងឡាយរបស់អង្គការសហប្រជាជាតិដែលបានចែង ។

### មាត្រា ៧៤ : ឧបករណ៍អន្តរជាតិ

១ : ឧបករណ៍ទាំងឡាយនៃអង្គការសហប្រជាជាតិ ដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ត្រូវអនុវត្តជាគោលច្បាប់ក្នុងប្រទេសកម្ពុជា ពេលណាអត្ថបទទាំងនោះត្រូវបានផ្សាយជាផ្លូវការដោយ អ៊ុនតាក់ ។

២ : ឧបករណ៍អន្តរជាតិឯទៀតៗ ដែលសមហេតុផល អាចយកមកប្រើប្រាស់ដើម្បីធ្វើការបកស្រាយបទបញ្ញត្តិនេះបាន ។

## មាត្រា ៧៥ : ការចូលជាធរមាន

អត្ថបទនេះត្រូវចូលជាធរមាន ៩៥ ថ្ងៃគត់ ក្រោយថ្ងៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត លើកលែងតែអ្វីៗដែលទាក់ទងនឹងមាតិកា បួន, ប្រាំ, ប្រាំមួយ និងប្រាំពីរ ដែលត្រូវចូលជាធរមានមួយថ្ងៃ ក្រោយថ្ងៃដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត ។

***************************

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ក្រម

# ព្រហ្មទណ្ឌ

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## មាតិកាទី ១

## ច្បាប់ព្រហ្មទណ្ឌ

### ជំពូកទី ១

### គោលការណ៍ទូទៅ

**មាត្រា ១.–** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.–** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ នៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.–** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.–** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការខិតខំប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.–** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.–** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.–** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.–** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិរោធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.–** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬ ត្រូវតែឈប់អនុវត្ត ។

**មាត្រា ១០.–** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទា-

ទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.–** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

### ផ្នែកទី ១

### បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.–** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.–** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានទង់សញ្ញាជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

ROYAUME DU CAMBODGE * MINISTÈRE DU PALAIS ROYAL *

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញ :

-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬ ដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.-** ការធ្វើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩(បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០(ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬ ពីសិទ្ធិវន្ត ឬ បណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

គ្មានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២
## ការទទួលខុសត្រូវព្រហ្មទណ្ឌ
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ព្រះរាជក្រម

នស/រកម/០១០២/០០៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ និងដែលព្រឹទ្ធសភាបានអនុម័តលើកចោលពុំពិចារណាលើច្បាប់នេះព្រោះមិនស្របនឹងទម្រង់ច្បាប់ កាលពីថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ប៉ុន្តែដោយយោងតាមវាក្យខ័ណ្ឌទី១ និងទី២ នៃមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាបានពិនិត្យឃើញថា អត្ថបទច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានពិនិត្យរួចហើយ។ ដែលព្រឹទ្ធសភាមិនព្រមផ្តល់យោបល់លើខ្លឹមសារនៃច្បាប់នេះត្រូវចាត់ទុកជាជាបានអការ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
## ស្តីពី
## ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

**មាត្រា ១.-** គោលបំណង

ច្បាប់នេះមានគោលបំណងកំណត់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដើម្បីពង្រឹងវិស័យសន្តិសុខសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-** មធ្យោបាយបង្ហាញភស្តុតាង

១-សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងមន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវតែបានអនុញ្ញាតនិយាយជូនតុលាការស្តាប់ ។ សាក្សីអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សា ពីសំណាក់ជនជាប់ចោទ ឬទីប្រឹក្សា ហើយនិងពីសំណាក់ព្រះរាជអាជ្ញា ។

២-នៅពេលជំនុំជម្រះ ភស្តុតាងទាំងអស់រួមទាំងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវលើកយកមកជជែកវែកញែក ហើយភស្តុតាងនិងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងនោះ មិនអាចចាត់ទុកជាភស្តុតាងដែលមិនអាចប្រកែកបានទេ ។

៣-បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចចាត់ទុកជាមូលដ្ឋានសម្រាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំតាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើទៅចៅក្រមដោយទីប្រឹក្សារបស់ជនជាប់ចោទនៅមុនពេលកាត់ក្តី ។

៤-អ្នកការពារជនជាប់ចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥-សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំឱ្យបង្ហាញខ្លួនចំពោះមុខតុលាការតាមរយៈដីកានាំខ្លួនរបស់តុលាការ ក្នុងករណីមិនព្រមប្រព្រឹត្តតាមការនាំខ្លួនរបស់តុលាការត្រូវពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន)រៀល ទៅ ៥០០.០០០ (ហាសិបម៉ឺន)រៀល ។

**មាត្រា ៣.-** ឃាតកម្មគិតទុកជាមុន

១-ជនណាដែលសម្លាប់ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួនឬដោយបានរៀបចំការលួចស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

២-ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាម្នាក់ ។

ការលួចស្ទាក់គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ ។

**មាត្រា ៤.-** អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនាឬប៉ុនប៉ងសម្លាប់ជនណាដោយចេតនាដោយគ្មានស្ថានទម្ងន់ណាដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ ទៅ ១៥ឆ្នាំ ។

ជនណាដែលសម្លាប់មនុស្សដោយចេតនាដោយឃោរឃៅក្នុងកាលៈទេសៈនិងក្នុងទីកន្លែងតែមួយបណ្តាលឱ្យជនណាម្នាក់ឬច្រើននាក់ស្លាប់ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៥.-** បទរំលោភសេពសន្ថវៈ

១-ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះបីភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

២-បទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិឬមធ្យោបាយផ្សេងទៀតដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។

ប្រសិនបើការរំលោភសេពសន្ថវៈបានប្រព្រឹត្តឡើងដោយការគំរាមកំហែងដោយអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬលើអនីតិជន អាយុតិចជាង ១៤ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តម្នាក់ឬច្រើននាក់ ឬដោយអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ។

**មាត្រា ៦.-** អំពើប្លន់

អំពើប្លន់ ជាការបន្លំនិងជាការជំរិតយកទ្រព្យសម្បត្តិអ្នកដទៃ តាមគ្រប់រូបភាព ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

ជនណាដែលបានលួច ឬប៉ុនប៉ងលួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសណាមួយដូចខាងក្រោម :

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធ ឬអត់អាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស

-ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយការកាប់គាស់ទម្លុះ ទម្លាយ បំផ្លិចបំផ្លាញ ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធក្តី ឬអត់អាវុធក្តី បណ្តាលឱ្យស្លាប់ម្ចាស់ទ្រព្យ ក្រុមគ្រួសារ ឬអ្នកការពារ អ្នកថែរក្សា ត្រូវមានទោសពីបទឧក្រិដ្ឋឃាតកម្មគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៧.–** ការចាប់ជំរិតនិងការបង្ខាំងមនុស្សដោយខុសច្បាប់

១-ជនណាដែលគ្មានបញ្ជាពីអាជ្ញាធរតុលាការ បានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស :

-ដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួននោះមានរយៈពេលតិចជាង ១ខែ

-ដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ ។

២-ជនណាដែលគំរាមតាមគ្រប់រូបភាព តាមមធ្យោបាយណាក៏ដោយ ដើម្បីកំណត់ឱ្យប្រគល់ជាប្រាក់ ឬជាទ្រព្យសម្បត្តិ ក្នុងបំណងដែលខ្លួនចង់បាននោះ ត្រូវមានទោសពីបទឧក្រិដ្ឋជំរិត ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

៣-ជនណាដែលប្រព្រឹត្តដោយចេតនា ចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ យកមកឃុំខ្លួន ឬបង្ខាំងខ្លួន ឬគំរាមធ្វើទារុណកម្មដោយគ្រប់រូបភាពបណ្តាលឱ្យជនណាម្នាក់ស្លាប់ក្តី ឬមិនស្លាប់ក្តី ហើយគំរាមឱ្យតតិយជន ឬជនរងគ្រោះប្រគល់ជាប្រាក់ ឬទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀត ដើម្បីជាថ្នូរទៅតាមបំណងរបស់ខ្លួនត្រូវមានទោសពីបទឧក្រិដ្ឋចាប់ជំរិតនិងបង្ខាំងមនុស្សខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៨.–** ការព្យួរទោស

ចំពោះបទឧក្រិដ្ឋនិងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករាឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

៣រស.០២.០១.០០០៤

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង យូ ហុកគ្រី

លេខ : ០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រម

នស/រកម/០៥១០/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងអំពើភេរវកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងអំពើភេរវកម្ម

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងអំពើភេរវកម្ម ដែលធ្វើនៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នាថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.១០០៥.៤១៤

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៣៧៨ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១០

អគ្គលេខាធិការរងទីស្ដីការរដ្ឋាភិបាល

[illegible] ជិនកេន

# អនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងអំពើភេរវកម្ម

បណ្តាប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន (ASEAN) រួមមាន ប្រទេសប្រ៊ុយណេដារ៉ូស្សាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម អំណឹះតទៅហៅថា "ភាគី" ។

រំលឹកឡើងវិញនូវធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃច្បាប់អន្តរជាតិដែលពាក់ព័ន្ធ អនុសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធការប្រឆាំងនឹងអំពើភេរវកម្ម និងសេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិ ស្តីពីបណ្តាវិធានការក្នុងការប្រឆាំងអំពើភេរវកម្មអន្តរជាតិ ព្រមទាំងបញ្ជាក់ឡើងវិញនូវការប្តេជ្ញារបស់យើង ដើម្បីការពារសិទ្ធិមនុស្ស ភាពយុត្តិធម៌ នីតិរដ្ឋ និងដំណើរការតាមនីតិវិធី ក៏ដូចជាគោលការណ៍ដែលបានចែងក្នុងសន្ធិសញ្ញាចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលបានធ្វើនៅកោះបាលី កាលពីថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។

បញ្ជាក់អះអាងឡើងវិញថា អំពើភេរវកម្មមិនអាច ហើយក៏មិនត្រូវបានជាប់ពាក់ព័ន្ធជាមួយនឹងសាសនា សញ្ជាតិ អរិយធម៌ ឬក៏ក្រុមជនជាតិភាគតិចណាមួយឡើយ ។

រំលឹកឡើងវិញផងដែរ នូវសេចក្តីប្រកាសរបស់អាស៊ាន ស្តីពីសកម្មភាពរួមក្នុងការប្រឆាំងអំពើភេរវកម្ម និងសេចក្តីប្រកាសស្តីពីអំពើភេរវកម្មដែលបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ានជាបន្តបន្ទាប់ក្នុងឆ្នាំ ២០០១ និង ២០០២ ។

បញ្ជាក់អះអាងឡើងវិញនូវការប្តេជ្ញារបស់យើងស្របតាមកម្មវិធីសកម្មភាពក្រុងវៀងច័ន្ទ កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ជាពិសេសបង្កើនការជំរុញរបស់ខ្លួនលើការកែសំរួល និងការចែករំលែកនូវបទដ្ឋាន និងសេចក្តីត្រូវការក្នុងចំណោមបញ្ហាផ្សេងៗទៀត ដើម្បីធ្វើការឆ្ពោះទៅរកការសំរេចបង្កើត នៃកិច្ចព្រមព្រៀងលើការជួយផ្នែកច្បាប់ទៅវិញទៅមករបស់អាស៊ាន និងអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ព្រមទាំងធ្វើការបង្កើតឡើងនូវសន្ធិសញ្ញាបត្យាប័នអាស៊ានមួយ ដែលបានគ្រោងទុកតាមរយៈសេចក្តីប្រកាសនៃកិច្ចព្រមព្រៀងអាស៊ាន កាលពីឆ្នាំ ១៩៧៦ ។

មានក្តីបារម្ភយ៉ាងជ្រាលជ្រៅលើគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ដែលបានបង្កដោយអំពើភេរវកម្មដល់អាយុជីវិតជន ស្លូតត្រង់ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន សន្តិភាព និងស្ថេរភាពក្នុងតំបន់ និងអន្តរជាតិក៏ដូចជាការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

យល់ឃើញនូវសារសំខាន់នៃការស្គាល់ច្បាស់ពីអត្តសញ្ញាណ និងការដោះស្រាយប្រកបដោយប្រសិទ្ធិភាពនៃឫសគល់ ដែលបង្កអោយមានអំពើភេរវកម្មក្នុងការរៀបចំយ៉ាងជាក់លាក់នូវបណ្តាវិធានការប្រឆាំងនឹងអំពើភេរវកម្ម ។

បញ្ជាក់ឡើងវិញជាថ្មីម្តងទៀតថា រាល់លក្ខណៈ និងទំរង់គ្រប់ប្រភេទនៃអំពើភេរវកម្មដែលបានកើតឡើង ទោះជានៅកន្លែងណា ពេលណា និងប្រព្រឹត្តដោយអ្នកណាក៏ដោយ គឺជាការគំរាមកំហែងមួយដ៏ខ្លាំងក្លាដល់សន្តិភាព និងសន្តិសុខជាលក្ខណៈអន្តរជាតិ និងគឺជាការប្រឈមដោយផ្ទាល់ចំពោះមុខ ដើម្បីឈានដល់គោលដៅសម្រេចនៃសន្តិភាព វឌ្ឍនភាព និងវិបុលភាពរបស់អាស៊ាន និងការយល់ដឹងអំពីចក្ខុវិស័យអាស៊ានឆ្នាំ ២០២០ ។

បញ្ជាក់អះអាងឡើងវិញពីការប្តេជ្ញាដ៏ខ្ជាប់ខ្ជួនរបស់យើង ដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងនឹងអំពើភេរវកម្មព្រមទាំងធ្វើការទប់ស្កាត់ និងបង្ក្រាបនូវរាល់ទំរង់គ្រប់ប្រភេទនៃសកម្មភាពរបស់ពួកភេរវករ ។

បញ្ជាក់ឡើងវិញជាថ្មីម្តងទៀតនូវសេចក្តីត្រូវការដ៏ចាំបាច់ ដើម្បីធ្វើអោយប្រសើរឡើងលើកិច្ចសហប្រតិបត្តិការនៅតាមតំបន់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម និងអនុវត្តនូវបណ្តាវិធានការប្រកបដោយប្រសិទ្ធិភាព តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជ្រាលជ្រៅក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរដែលពាក់ព័ន្ធរបស់អាស៊ានក្នុងការប្រឆាំងទៅនឹងអំពើភេរវកម្ម ។

លើកទឹកចិត្តដល់ភាគីទាំងឡាយ ដើម្បីអោយក្លាយជាភាគីក្នុងពេលដ៏ឆាប់ខាងមុខនេះចំពោះអនុសញ្ញា និងពិធីសារអន្តរជាតិ ដែលជាប់ពាក់ព័ន្ធក្នុងការប្រឆាំងទៅនឹងអំពើភេរវកម្ម ។

បានព្រមព្រៀងគ្នាដូចខាងក្រោម:

## មាត្រា ១
## គោលបំណង

អនុសញ្ញានេះផ្តល់នូវគ្រប់ខ័ណ្ឌសំរាប់ធ្វើកិច្ចសហប្រតិបត្តិការនៅតាមតំបន់ ដើម្បីប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ក្រាបនូវរាល់លក្ខណៈ និងទំរង់គ្រប់ប្រភេទនៃអំពើភេរវកម្ម និងដើម្បីធ្វើកិច្ចសហប្រតិបត្តិការអោយកាន់តែខ្លាំងក្លាឡើងក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរដែលពាក់ព័ន្ធរបស់ភាគីទាំងឡាយក្នុងការប្រឆាំងនឹងអំពើភេរវកម្ម ។

## មាត្រា ២
## សកម្មភាពឧក្រិដ្ឋនៃអំពើភេរវកម្ម

១. ក្នុងគោលបំណងនៃអនុសញ្ញានេះ "បទល្មើស" មានន័យថា បទល្មើសទាំងឡាយណាស្ថិតក្នុងវិសាលភាព និងបានផ្តល់នូវអត្ថន័យដែលបានកំណត់ក្នុងសន្ធិសញ្ញាទាំងឡាយដូចខាងក្រោម:

ក. អនុសញ្ញា ស្តីពីការបង្ក្រាបលើការចាប់ជំរិតយន្តហោះដោយខុសច្បាប់ ដែលបានចុះហត្ថលេខាកាលថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៧០ នៅឡាអេ ។

ខ. អនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល ដែលបានអនុម័តកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧១ នៅម៉ុងត្រេអាល់ ។

គ. អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះបទល្មើសឧក្រិដ្ឋប្រព្រឹត្តលើបុគ្គល ដែលមានសិទ្ធិការពារជាអន្តរជាតិរួមទាំងភ្នាក់ងារការទូត ដែលបានអនុម័តកាលពី ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៣ នៅទីក្រុងញូវយ៉ក ។

ឃ. អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ដែលបានអនុម័តកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ នៅទីក្រុងញូវយ៉ក ។

ង. អនុសញ្ញាស្តីពីការការពាររាងកាយពីសាធាតុនុយក្លេអ៊ែរ ដែលបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៧៩ នៅវីអេណា ។

ច. ពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពបំពានខុសច្បាប់ នៃអំពើហិង្សានៅព្រលានអាកាសចរណ៍ស៊ីវិលអន្តរជាតិបន្ថែមទៅលើអនុសញ្ញា ស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងអាកាសចរណ៍ស៊ីវិល បានធ្វើនៅទីក្រុង ម៉ុងត្រេអាល់ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៨៨ ។

ឆ. អនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងទៅនឹងសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលបានធ្វើនៅទីក្រុងរ៉ូម កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨។

ជ. ពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ បានធ្វើនៅក្នុងទីក្រុងរ៉ូម កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨។

ឈ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់បំផ្ទុះគ្រាប់បែករបស់ពួកភេរវករ ដែលបានអនុម័តកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ នៅទីក្រុងញូវយ៉ក។

ញ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបលើការផ្តត់ផ្គង់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលបានអនុម័តកាលពីថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៩ នៅទីក្រុងញូវយ៉ក។

ដ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបលើសកម្មភាពនៃអំពើភេរវកម្មនុយក្លេអ៊ែរ ដែលបានអនុម័តកាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ នៅទីក្រុងញូវយ៉ក។

ឋ. ការធ្វើវិសោធនកម្ម ចំពោះអនុសញ្ញាស្តីពីការការពាររាង្គកាយពីសារធាតុនុយក្លេអ៊ែរ បានធ្វើនៅវីអេណាកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥។

ឌ. ពិធីសារឆ្នាំ២០០៥ ចំពោះអនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្របានធ្វើនៅទីក្រុងឡុង កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥។

ឍ. ពិធីសារឆ្នាំ ២០០៥ ទៅនឹងពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាព នៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្របានធ្វើនៅក្នុងទីក្រុងឡុង កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០០៥។

២. ដាក់លិខិតុកនូវឯកសាររបស់ខ្លួនស្តីពីការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ភាគីមួយដែលមិនមែនជាភាគីនៃសន្ធិសញ្ញាមួយដែលបានកំណត់ក្នុងកថាខ័ណ្ឌទី១ អាចនឹងប្រកាសថា សន្ធិសញ្ញាមិនត្រូវបានចាត់ទុកថាបានដាក់បញ្ចូលក្នុងកថាខ័ណ្ឌទី១ ចំពោះការអនុវត្តន៍នៃអនុសញ្ញានេះចំពោះភាគីនោះ។ សេចក្តីប្រកាសនេះបានបញ្ឈប់សុពលភាពភ្លាម ខណៈពេលដែលសន្ធិសញ្ញាចូលជាធរមានសំរាប់ភាគីដែលបានធ្វើសេចក្តីប្រកាសខាងលើ ដែលត្រូវជូនដំណឹងដូចបានចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រា២០ នៃការចូលជាធរមាននេះ។

៣. នៅពេលដែលភាគីមួយបញ្ឈប់ជាភាគីមួយចំពោះសន្ធិសញ្ញាមួយដែលបានកំណត់ក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ភាគីនេះអាចធ្វើនូវសេចក្តីប្រកាសមួយផ្តល់សំរាប់មាត្រានេះចំពោះសន្ធិសញ្ញានោះ។

## មាត្រា ៣

## សមភាពអធិបតេយ្យ, បូរណភាពដែនដី និងការមិនជ្រៀតជ្រែក

ភាគីទាំងឡាយត្រូវអនុវត្តន៍នូវកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះ ក្នុងលក្ខណៈមួយស្របទៅតាមគោលការណ៍នៃសមភាពអធិបតេយ្យ និងបូរណភាពដែនដីរបស់ភាគីទាំងឡាយ ហើយនឹងការមិនជ្រៀតជ្រែកនូវរាល់កិច្ចការផ្ទៃក្នុងនៃភាគីទាំងឡាយផ្សេងទៀត។

## មាត្រា ៤

## ការការពារអធិបតេយ្យភាព

នៅក្នុងអនុសញ្ញានេះមិនមានការផ្ដល់សិទ្ធិដល់ភាគីណាមួយ ដើម្បីអនុវត្តក្នុងដែនដីនៃភាគីមួយផ្សេងទៀតលើការអនុវត្តន៍នូវដែនសមត្ថកិច្ចយុត្តាធិការ ឬក៏បំពេញមុខងារដែលបំរុងទុកយ៉ាងពិសេសចំពោះអាជ្ញាធរ នៃភាគីណាផ្សេងទៀតតាមរយៈច្បាប់ជាតិរបស់ខ្លួន ។

## មាត្រា ៥

## ការមិនអនុវត្តន៍

អនុសញ្ញានេះមិនត្រូវបានយកមកអនុវត្ត នៅពេលណាដែលបទល្មើសបានប្រព្រឹត្តឡើងនៅក្នុងទឹកដីរបស់ភាគីមួយ ជនល្មើសដែលត្រូវបានចោទប្រកាន់ និងជនរងគ្រោះជាពលរដ្ឋនៃភាគីនោះ បទល្មើសដែលបានចោទប្រកាន់ត្រូវបានរកឃើញនៅក្នុងដែនដីនៃភាគីនោះ ហើយភាគីផ្សេងទៀតមិនមានគោលការណ៍ដ៏សំខាន់មួយដែលជាមូលដ្ឋានគ្រឹះ តាមអនុសញ្ញានេះដើម្បីអនុវត្តនូវដែនសមត្ថកិច្ចយុត្តាធិការ ។

## មាត្រា ៦

## វិស័យនានានៃកិច្ចសហប្រតិបត្តិការ

១. វិស័យនានានៃកិច្ចសហប្រតិបត្តិការតាមអនុសញ្ញានេះ រួមមានទាំងបណ្ដាវិធានការដ៏សមស្របដោយអនុលោមទៅតាមច្បាប់ជាតិរបស់ភាគីនីមួយៗក្នុងនោះមាន:

ក. ចាត់នូវបណ្ដាវិធានការដ៏ចាំបាច់ ដើម្បីទប់ស្កាត់ទៅនឹងការប្រព្រឹត្តនៃសកម្មភាពរបស់ពួកភេរវករ រួមមានទាំងការផ្ដល់នូវការក្រើនរំលឹកជាមុនដល់ភាគីផ្សេងៗទៀត តាមរយៈការផ្លាស់ប្ដូរពត៌មាន ។

ខ. ទប់ស្កាត់នូវរាល់ជនទាំងឡាយណាដែលផ្ដល់ផ្នែកហិរញ្ញវត្ថុ រៀបចំផែនការ ផ្ដល់លក្ខណៈងាយស្រួល ឬក៏ប្រព្រឹត្តនូវសកម្មភាពភេរវកម្មពីការប្រើប្រាស់ទឹកដីនីមួយៗរបស់គេក្នុងគោលបំណងប្រឆាំងនឹងភាគីផ្សេងៗទៀត ឬក៏ប្រជាពលរដ្ឋរបស់គេ ។

គ. ទប់ស្កាត់ និងបង្ក្រាបនូវការធ្វើហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម ។

ឃ. ទប់ស្កាត់នូវចលនារបស់ពួកភេរវករ ឬក៏ក្រុមរបស់ពួកភេរវករដោយធ្វើការត្រួតពិនិត្យនៅតាមព្រំដែន និងត្រួតពិនិត្យលើការចេញនូវលិខិតបញ្ជាក់អត្តសញ្ញាណ និងឯកសារធ្វើដំណើរប្រកបដោយប្រសិទ្ធិភាព និងតាមរយៈបណ្ដាវិធានការសំរាប់ធ្វើការទប់ស្កាត់ការក្លែងបន្លំលើការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណ និងឯកសារធ្វើដំណើរក្លែងក្លាយ ។

ង. បង្កើនការពង្រឹងសមត្ថភាព រួមមានទាំងការបណ្ដុះបណ្ដាល ការធ្វើកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស និងប្រារព្ធឡើងនូវកិច្ចប្រជុំនៅតាមតំបន់ ។

ច. ជំរុញអោយមានការយល់ដឹងជាសាធារណៈ និង ការចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រឆាំងនឹងអំពើភេរវកម្មក៏ដូចជាបង្កើននូវកិច្ចពិភាក្សាលើសេចក្ដីទុកចិត្តគ្នាទៅវិញទៅមក និងក្នុងផ្នែកលទ្ធិសាសនាព្រមទាំងធ្វើការពិភាក្សាលើផ្នែកអរិយធម៌ជឿនលឿន ។

ឆ. បង្កើនកិច្ចសហប្រតិបត្តិការលើការឆ្លងកាត់ព្រំដែន ។

ជ. បង្កើនការផ្លាស់ប្ដូរពត៌មានចារកម្ម និងចែករំលែកពត៌មាន ។

ឈ. បង្កើនកិច្ចសហប្រតិបត្តិការឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យកុំព្យូទ័រ ដែលមានស្រាប់នៅតាមតំបន់ក្រោមរង្វង់សមត្ថកិច្ចរបស់គណៈកម្មាការអាស៊ានដែលពាក់ព័ន្ធ ។

ញ. ពង្រឹងនូវសមត្ថភាព និងការរៀបចំទុកជាមុន ដើម្បីដោះស្រាយលើអំពើភេរវកម្មផ្នែកគីមីសាស្ត្រ ជីវសាស្ត្រ វិទ្យុសាស្ត្រ នុយក្លេអ៊ែរ អំពើភេរវកម្មពត៌មានវិទ្យា និងរាល់ទំរង់ថ្មីណាមួយនៃអំពើភេរវកម្ម ។

ដ. ទទួលខុសត្រូវ ស្រាវជ្រាវរក និងការបង្កើននូវបណ្តាវិធានការ ដើម្បីប្រឆាំងនឹងអំពើភេរវកម្ម ។

ឋ. ជំរុញទឹកចិត្តដល់ការប្រើប្រាស់នូវរាល់ឧបករណ៍ សន្និសិទតាមវីដេអូ ឬក៏សន្និសិទតាមទូរទស្សន៍ សំរាប់ចំណាត់ការរបស់តុលាការនៅពេលដែលសមស្រប ។

ឌ. ធានាអោយប្រាកដថា ជនណាមួយដែលបានចូលរួមក្នុងការធ្វើហិរញ្ញប្បទាន មានផែនការ ការរៀបចំ ឬក៏ការប្រព្រឹត្តនូវសកម្មភាពភេរវកម្ម ឬក៏ជួយឧបត្ថម្ភដល់សកម្មភាពរបស់ពួកភេរវករត្រូវនាំយកមកកាត់ទោស ។

២. អាស្រ័យលើការព្រមព្រៀងគ្នារបស់ភាគីទាំងឡាយដែលពាក់ព័ន្ធភាគីទាំងនោះ ត្រូវធ្វើសហប្រតិបត្តិការ ដើម្បីដោះស្រាយនូវឫសគល់ដែលបង្កអោយមានអំពើភេរវកម្ម និងលក្ខណៈដែលនាំទៅរកការរីករាលដាលនៃអំពើភេរវកម្ម ដើម្បីទប់ស្កាត់លើការប្រព្រឹត្តនូវសកម្មភាពរបស់ពួកភេរវករ និងការកើនឡើងនូវក្រុមតូចៗរបស់ភេរវករ ។

## មាត្រា ៧

## ដែនសមត្ថកិច្ចយុត្តាធិការរបស់ភាគី

១. ភាគីមួយត្រូវចាត់នូវបណ្តាវិធានការចាំបាច់សមស្រប ដើម្បីបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ នៅពេលដែល:

ក. បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃភាគីនោះ ឬក៏

ខ. បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅលើនាវាដែលដោតទង់ជាតិនៃភាគីនោះ ឬក៏នៅលើយន្តហោះមួយដែលបានចុះបញ្ជីឈ្មោះតាមច្បាប់នៃភាគីនោះនៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង ឬក៏

គ. បទល្មើស ត្រូវបានប្រព្រឹត្តឡើងដោយពលរដ្ឋម្នាក់នៃភាគីនោះ

២. ភាគីមួយអាចនឹងបង្កើតឡើងផងដែរនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសណាមួយខាងលើ នៅពេលដែល:

ក. បទល្មើសត្រូវបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងពលរដ្ឋម្នាក់នៃភាគីនោះ ឬក៏

ខ. បទល្មើសត្រូវបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងភាគីមួយ ឬក៏សេវាកម្មសាធារណៈរបស់រដ្ឋាភិបាល នៃភាគីនោះ ដែលនៅក្រៅប្រទេស រួមមានទាំងស្ថានទូត ឬក៏ទីបរិវេណកុងស៊ុល ឬក៏ផ្នែកការទូតផ្សេងទៀត របស់ខ្លួន ឬក៏

គ. បទល្មើសត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងមួយដើម្បីបង្ខិតបង្ខំអោយភាគីនោះធ្វើ ឬក៏រារាំងពីការធ្វើសកម្មភាពអ្វីមួយ ឬក៏

ឃ. បទល្មើសត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលម្នាក់ដែលមិនមែនជាពលរដ្ឋនៃប្រទេសណាមួយ ប៉ុន្តែបានស្នាក់នៅជាប្រក្រតីក្នុងដែនដីនៃភាគីនោះ ។

៣. ភាគីមួយត្រូវបង្កើតឡើងផងដែរនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសដែលបានចែងក្នុងមាត្រា២ ក្នុងករណីដែលជនល្មើសត្រូវបានចោទប្រកាន់ មានវត្តមាននៅក្នុងដែនដីរបស់ខ្លួន ហើយភាគីនោះមិនទាន់បានធ្វើបត្យាប័នជនល្មើសនោះជូនទៅភាគីទាំងឡាយណា ដែលបានបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការរបស់គេ ដោយអនុលោមទៅតាមកថាខ័ណ្ឌទី ១ ឬ ទី២ នៃមាត្រានេះ។

៤. អនុសញ្ញានេះមិនរាប់បញ្ចូលលើការអនុវត្តន៍នៃដែនសមត្ថកិច្ចយុត្តាធិការព្រហ្មទណ្ឌណាមួយដែលបានបង្កើតឡើងដោយភាគីមួយដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន។

## មាត្រា ៨

## ការយកចិត្តទុកដាក់ថែទាំដ៏ត្រឹមត្រូវ

១. ជនណាដែលត្រូវបានចាប់ឃុំខ្លួន ឬក៏ជាប់ពាក់ព័ន្ធទៅនឹងការចាត់បណ្តាវិធានការ ឬក៏ចំណាត់ការក្តីណាមួយផ្សេងទៀតដែលបានអនុវត្តស្របទៅតាមអនុសញ្ញានេះ ត្រូវបានធានាអោយមានការយកចិត្តទុកដាក់ថែទាំត្រឹមត្រូវរួមមានទាំងការទទួលនូវសិទ្ធិ និងការធានា ដែលអនុលោមទៅតាមច្បាប់ក្នុងដែនដីរបស់ភាគីដែលជនទនោះមានវត្តមាន និងអនុវត្តនូវរាល់បទបញ្ញត្តិនៃច្បាប់អន្តរជាតិ ដោយរួមមានទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

២. ក្រោយពេលទទួលបានពត៌មានថា មានជនម្នាក់បានប្រព្រឹត្តឬក៏ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តបទល្មើសមួយដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះមានវត្តមានក្នុងទឹកដីរបស់ខ្លួន ភាគីដែលជាប់ពាក់ព័ន្ធ ត្រូវចាត់នូវបណ្តាវិធានការដ៏ចាំបាច់សមស្របតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេតលើហេតុការណ៍ ដែលទាក់ទងទៅនឹងពត៌មាន។

៣. បន្ទាប់ពីបានយល់ព្រមនូវលក្ខណៈនៃការធានាលើជនល្មើស ឬក៏ជនដែលត្រូវបានចោទប្រកាន់មានវត្តមានក្នុងដែនដីរបស់ភាគី ភាគីនោះត្រូវចាត់នូវបណ្តាវិធានការដ៏សមស្រមទៅតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធានាអោយប្រាកដថា វត្តមានរបស់ជននោះក្នុងគោលបំណងធ្វើការកាត់ទោស ឬក៏ធ្វើបត្យាប័ន។

៤. ជនណាដែលជាប់ពាក់ព័ន្ធទៅនឹងការចាត់នូវបណ្តាវិធានការណាមួយ ដែលបានចែងក្នុងកថាខ័ណ្ឌទី៣ នៃមាត្រានេះត្រូវបានផ្តល់សិទ្ធិ:

ក. ធ្វើការទំនាក់ទំនងដោយមិនបង្អែរង្អង់យូរជាមួយនឹងតំណាងដ៏សមស្របរបស់ភាគីនៅជិតបំផុត ដែលជននោះជាពលរដ្ឋ ឬក៏ផ្តល់សិទ្ធិផ្សេងពីនេះ ដើម្បីការពារសិទ្ធិរបស់ជននោះ។

ខ. មកសាកសួរសុខទុក្ខដោយតំណាងណាម្នាក់នៃភាគីនោះ។

គ. ជូនដំណឹងពីសិទ្ធិរបស់ជននោះស្របតាមអនុកថាខ័ណ្ឌ ក និង ខ កថាខ័ណ្ឌទី៤ នៃមាត្រានេះ។

៥. រាល់សិទ្ធិដែលបានចែងក្នុងកថាខ័ណ្ឌទី៤ នៃមាត្រានេះ ត្រូវបានអនុវត្តន៍ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ភាគីដែលជនល្មើស ឬក៏ជនល្មើសដែលត្រូវបានចោទប្រកាន់មានវត្តមានក្នុងដែនដីនោះ អាស្រ័យលើច្បាប់និងបទបញ្ញត្តិដូចបានចែងខាងលើ ត្រូវមានសុពលភាពពេញលេញផ្តល់អោយក្នុងគោលបំណងសំរាប់សិទ្ធិស្របទៅតាមកថាខ័ណ្ឌទី៤ នៃមាត្រានេះ ដែលបានបំរុងទុកមក។

៦. នៅពេលដែលភាគីមួយបានចាប់ឃុំខ្លួនជនណាម្នាក់ ត្រូវជូនដំណឹងជាបន្ទាន់ដោយផ្ទាល់ ឬក៏តាមរយៈអគ្គលេខាធិការអាស៊ានដោយអនុលោមទៅតាមមាត្រានេះ ភាគីដែលបានបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការអនុលោមទៅតាមមាត្រា៧ កថាខ័ណ្ឌទី១ ឬក៏ ទី២ ហើយនឹងប្រសិនបើពិចារណាឃើញថា អាចធ្វើទៅបានភាគីទាំងឡាយណាមួយផ្សេងទៀតដែលបានចាប់អារម្មណ៍លើហេតុការណ៍ថា ជននោះស្ថិតក្នុងមន្ទីរឃុំឃាំង និងស្ថិតលើលក្ខណៈដែលធានាការការពារដល់ជននោះ។ ភាគីដែលកំពុងស៊ើបអង្កេត យោងទៅតាមកថាខ័ណ្ឌទី២ នៃមាត្រានេះ ត្រូវជូនដំណឹងជាបន្ទាន់

ដល់ភាគីទាំងឡាយ ដែលបានចែងខាងលើ លើការយល់ឃើញរបស់ខ្លួន និងត្រូវបង្ហាញថា ខ្លួនមានបំណងអនុវត្តនូវដែនសមត្ថកិច្ច យុត្តាធិការដែរឬទេ ។

## មាត្រា ៩

## បទបញ្ញត្តិនុនោរ

១. ភាគីទាំងឡាយត្រូវអនុម័តនូវរាល់បណ្តាវិធានការដ៏ចាំបាច់សមស្រប ដោយរួមមានទាំងការបង្កើតច្បាប់ជាតិមានលក្ខណៈសមស្រប ដើម្បីធានាអោយប្រាកដថា រាល់សកម្មភាពឧក្រិដ្ឋត្រូវបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ជាពិសេសនៅពេលដែលវាមានបំណងធ្វើការបំភិតបំភ័យដល់ប្រជាពលរដ្ឋ ឬក៏ដើម្បីបង្ខិតបង្ខំរដ្ឋាភិបាលមួយ ឬក៏អង្គការអន្តរជាតិមួយធ្វើ ឬក៏រារាំងពីការធ្វើសកម្មភាពអ្វីមួយ ដែលស្ថិតក្នុងលក្ខណៈមិនត្រឹមត្រូវ តាមរយៈធ្វើការពិចារណាលើផ្នែកនយោបាយ ទស្សនវិជ្ជា មនោគមវិជ្ជា ជាតិសាសន៍ ជនជាតិភាគតិច សាសនា ឬក៏លក្ខណៈស្រដៀងគ្នាផ្សេងៗទៀត ។

២. អនុលោមទៅតាមមាត្រា៦ នៃអនុសញ្ញានេះ ភាគីទាំងឡាយត្រូវបង្កើតឡើងនូវបណ្តាញទំនាក់ទំនងតាមលទ្ធភាពរវាងបណ្តាភ្នាក់ងារមានសមត្ថកិច្ច ដើម្បីផ្តល់នូវលក្ខណៈងាយស្រួលដល់ការផ្លាស់ប្តូរព័ត៌មានក្នុងការទប់ស្កាត់ការប្រព្រឹត្តបទល្មើស ដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ។

៣. ជនល្មើសដែលបានចោទប្រកាន់ ដោយភាគីមួយ ត្រូវនាំយកមកកាត់ទោស នៅពេលដែលទទួលបានការស្នើសុំពីភាគីផ្សេងៗទៀត ដែលប្រកាសនូវដែនសមត្ថកិច្ចយុត្តាធិការមានលក្ខណៈដូចគ្នានោះ ធ្វើការទំនាក់ទំនងពីស្ថានភាពនៃករណីបទល្មើសទៅតាមដំណាក់កាលលើចំណាត់ការក្តីណាមួយទៅកាន់ភាគីផ្សេងៗទៀតទាំងនោះ ។

## មាត្រា ១០

## ឋានៈនៃជនភៀសខ្លួន

ភាគីទាំងឡាយត្រូវចាត់នូវរាល់បណ្តាវិធានការដ៏សមស្រប ដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់ជាតិនីមួយៗរបស់ខ្លួន និងដែលជាប់ពាក់ព័ន្ធច្បាប់អន្តរជាតិដែលអាចអនុវត្តបាន រួមមានទាំងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិមុនពេលផ្តល់ជូនពីស្ថានភាពរបស់ជនភៀសខ្លួន ខណៈពេលដែលភាគីទាំងឡាយទទួលស្គាល់ និងផ្តល់ឱ្យពីស្ថានភាពបែបនេះក្នុងគោលបំណងធានាអោយប្រាកដថា អ្នកស្វែងរកសិទ្ធិជ្រកកោនមិនបានមានផែនការផ្តល់លក្ខណៈងាយស្រួល ឬក៏បានចូលរួមក្នុងការប្រព្រឹត្តនូវសកម្មភាពភេរវកម្ម ។

## មាត្រា ១១

## កម្មវិធីស្តារនីតិសម្បទា

ភាគីទាំងឡាយត្រូវខិតខំខ្នះខ្នែង ដើម្បីបង្កើនការចែករំលែកលើការអនុវត្តន៍ប្រកបដោយភាពល្អប្រសើរស្តីពីកម្មវិធីស្តារនីតិសម្បទា រួមមានទាំងការធ្វើសមាហរណកម្មសង្គមឡើងវិញ មានលក្ខណៈសមស្របចំពោះជនទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តនូវបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ជាមួយនឹងទិសដៅលើការទប់ស្កាត់ នូវការប្រព្រឹត្តសកម្មភាពភេរវកម្ម ។

## មាត្រា ១២

## ការជួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្ម

១- ភាគីទាំងឡាយត្រូវចាត់នូវបណ្តាវិធានការដ៏ទូលំទូលាយ ដោយអនុលោមទៅតាមច្បាប់ជាតិនីមួយៗរបស់ខ្លួនលើការជួយដែលជាប់ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ឬក៏នីតិវិធីព្រហ្មទណ្ឌចំពោះបទល្មើសដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ។

២-ភាគីទាំងឡាយត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ដោយអនុលោមទៅតាមសិទ្ធិសញ្ញានោះ នៅពេលដែលភាគីទាំងឡាយនោះជាភាគីចំពោះសិទ្ធិសញ្ញា ស្តីពីការជួយផ្អែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្ម បានធ្វើនៅទីក្រុងកូឡាឡាំពួរ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤។

**មាត្រា ១៣**

**បត្យាប័ន**

១- ជនល្មើសដែលត្រូវបានចោទប្រកាន់មានវត្តមាន នៅក្នុងដែនដីរបស់ភាគីមួយត្រូវគោរពក្នុងករណីអនុវត្តទៅតាមមាត្រា៧ នៃអនុសញ្ញានេះ ប្រសិនបើភាគីនេះមិនបានធ្វើបត្យាប័នចំពោះជននោះ ដើម្បីដាក់ជូននូវករណីបទល្មើស ដោយមិនបង្អែបង្អង់យូរទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងធ្វើការកាត់ទោស តាមរយៈចំណាត់ការក្តី ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ភាគីនោះ ទោះបីជាគ្មានការលើកលែង និងថាតើបទល្មើសត្រូវបានប្រព្រឹត្ត ឬក៏មិនបានប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួន។ អាជ្ញាធរទាំងនោះ ត្រូវធ្វើការសំរេចចិត្តរបស់ខ្លួនស្ថិតក្នុងលក្ខណៈដូចគ្នាទៅតាមករណីនៃបទល្មើសណាមួយផ្សេងទៀត មានលក្ខណៈធ្ងន់ធ្ងរដោយផ្អែកទៅតាមច្បាប់ជាតិរបស់ភាគីនោះ។

២- បទល្មើសដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ត្រូវចាត់ទុកថាបានបញ្ចូលនូវរាល់បទល្មើសទាំងឡាយដែលអាចធ្វើបត្យាប័នបាននៅក្នុងសិទ្ធិសញ្ញាបត្យាប័នណាមួយ ដែលមានស្រាប់រវាងភាគីទាំងឡាយណាមុនពេលអនុសញ្ញានេះចូលជាធរមាន។ ភាគីទាំងឡាយត្រូវអនុវត្ត ដើម្បីបញ្ចូលបទល្មើសខាងលើ ដែលជាបទល្មើសអាចធ្វើបត្យាប័នបាននូវគ្រប់សិទ្ធិសញ្ញាបត្យាប័ន ត្រូវបានបញ្ចប់ជាបន្តបន្ទាប់រវាងភាគីទាំងឡាយនោះ។

៣- នៅពេលដែលភាគីមួយធ្វើល័ក្ខខ័ណ្ឌបត្យាប័ន ដែលមាននៅក្នុងសិទ្ធិសញ្ញាទទួលនូវការស្នើសុំធ្វើបត្យាប័នពីភាគីមួយផ្សេងទៀត ដែលគ្មានសិទ្ធិសញ្ញាបត្យាប័ន ភាគីដែលត្រូវស្នើសុំពិចារណាទៅលើអនុសញ្ញានេះ ដោយផ្អែកលើច្បាប់សំរាប់ធ្វើបត្យាប័នចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន។

**មាត្រា ១៤**

**ការលើកលែងបទល្មើសផ្នែកនយោបាយ**

មិនមានបទល្មើសទាំងឡាយណា ដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ត្រូវបានចាត់ទុកក្នុងគោលបំណងនៃការធ្វើបត្យាប័ន តាមមាត្រា១៣ នៃអនុសញ្ញានេះ ឬក៏ការជួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្ម តាមមាត្រា១២ នៃអនុសញ្ញានេះ ដូចជាបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជំរុញទឹកចិត្តអោយធ្វើផ្នែកនយោបាយ។ ហេតុដូច្នេះហើយ ការស្នើសុំសំរាប់ការធ្វើបត្យាប័ន ឬក៏ការជួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមក ក្នុងបញ្ហាឧក្រិដ្ឋកម្មផ្អែកលើបទល្មើសខាងលើ មិនត្រូវបានទទួលយកដោយបញ្ជាក់យ៉ាងច្បាស់ថា វាពាក់ព័ន្ធទៅនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជំរុញទឹកចិត្តអោយធ្វើផ្នែកនយោបាយ។

**មាត្រា ១៥**

**ការរៀបចំអាជ្ញាធរកណ្តាល ឬទេនាសម្ព័ន្ធសម្របសម្រួល**

ភាគីនីមួយៗត្រូវរៀបចំអាជ្ញាធរកណ្តាលមួយមានលក្ខណៈសមស្រប ឬក៏ការសម្របសម្រួលលើរចនាសម្ព័ន្ធដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការតាមអនុសញ្ញានេះ។

**មាត្រា ១៦**

**ការអនុវត្តន៍ ការតាមដាន និង ការពិនិត្យឡើងវិញ**

គណៈកម្មការតំបន់អាស៊ានដែលពាក់ព័ន្ធបានជាប់ទាក់ទងក្នុងការធ្វើកិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម នឹងទទួលខុសត្រូវលើការត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវការអនុវត្តន៍នៃ អនុសញ្ញានេះ។

## មាត្រា ១៧

### កិច្ចការសម្ងាត់

១- ភាគីនីមួយៗត្រូវរក្សានូវការសម្ងាត់ និងការសម្ងាត់នៃរាល់ឯកសារទាំងឡាយ កំណត់ហេតុ និងព័ត៌មានផ្សេងៗទៀត ដែលទទួលបានមកពីភាគីណាមួយផ្សេងទៀត ក្នុងនោះរួមមានប្រភពធនធាន។

២- ឯកសារ កំណត់ហេតុ ឬក៏ព័ត៌មានផ្សេងៗទៀត ដែលប្រមូលបានជាប់ទាក់ទងទៅនឹងអនុសញ្ញានេះមិនត្រូវបានប្រកាស ឬក៏ចែករំលែកដល់ភាគីណាមួយផ្សេងទៀត រដ្ឋ ឬបុគ្គល លើកលែងតែការព្រមព្រៀងរបស់ភាគីសរសេរជាលាយលក្ខ័អក្សរជាមុនទើបបានផ្តល់ជូននូវឯកសារ កំណត់ហេតុ ឬក៏ព័ត៌មានទាំងនោះ។

## មាត្រា ១៨

### ភាពទំនាក់ទំនងជាមួយនឹងលិខិតតុបករអន្តរជាតិផ្សេងៗទៀត

អនុសញ្ញានេះនឹងមិនធ្វើអោយប៉ះពាល់ដល់កាតព្វកិច្ចរបស់ភាគីទាំងឡាយ ដែលមានស្រាប់ជាប់ទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្សេងៗទៀត ជាលក្ខណៈអន្តរជាតិ ហើយថែមទាំងមិនរាំងដល់ភាគីទាំងឡាយ នៅពេលដែលភាគីទាំងនោះបានព្រមព្រៀងគ្នា ក្នុងការផ្តល់នូវការជួយឧបត្ថម្ភទៅវិញទៅមកទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្សេងៗទៀត ជាលក្ខណៈអន្តរជាតិ ឬក៏បទបញ្ញត្តិទាំងឡាយនៃច្បាប់ជាតិរបស់ខ្លួន។

## មាត្រា ១៩

### ការដោះស្រាយជម្លោះ

ភាពខុសគ្នា ឬក៏ជម្លោះណាមួយរវាងភាគីទាំងឡាយដែលកើតឡើងពីការបកស្រាយ ឬក៏ការអនុវត្តន៍នូវរាល់បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ត្រូវបានដោះស្រាយដោយសន្តិវិធី តាមរយៈការពិគ្រោះយោបល់ និងការចរចាររវាងភាគីទាំងឡាយ តាមរយៈទំនាក់ទំនងការទូត ឬក៏មធ្យោបាយដ៏ស្រុះស្រួលណាមួយផ្សេងទៀត លើការដោះស្រាយនៃជម្លោះដែលបានព្រមព្រៀងគ្នា ខាងលើរវាងភាគីទាំងនោះ។

## មាត្រា ២០

### ការផ្តល់សច្ចាប័ន ការយល់ព្រម និងការដាក់ដំកល់

១. អនុសញ្ញានេះ អាស្រ័យទៅលើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ដោយអនុលោមទៅតាមនីតិវិធីផ្ទៃក្នុងរបស់ភាគីទាំងឡាយ។

២. រាល់ឯកសារច្បាប់ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមរួចហើយនោះ ត្រូវបានដាក់ដំកល់ទុកជូនទៅអគ្គលេខាធិការអាស៊ាន ជាមួយនឹងការជូនដំណឹងជាបន្ទាន់ដល់ភាគីទាំងឡាយផ្សេងៗទៀតលើការដាក់ដំកល់ទុកនេះ។

## មាត្រា ២១

### ការចូលជាធរមាន និងការធ្វើវិសោធនកម្ម

១. អនុសញ្ញានេះនឹងត្រូវចូលជាធរមានរយៈពេល ៣០ថ្ងៃ ស្របទៅតាមការបរិច្ឆេទនៃការដាក់ដំកល់ទុកនូវរាល់ឯកសារចំនួន៦ច្បាប់ ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ហើយដាក់ជូនទៅអគ្គលេខាធិការអាស៊ាន

ក្នុងនោះដែរចំពោះតែភាគីទាំងឡាយណាដែលបានដាក់ជូនពិនិត្យនូវរាល់ឯកសារដែលបានធ្វើការផ្តល់សច្ចាប័ន និងការយល់ព្រមហើយនោះ ។

២. ចំពោះភាគីណាមួយដែលធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមនូវអនុសញ្ញានេះ បន្ទាប់ពីបានដាក់ដំកល់នូវរាល់ឯកសារចំនុនទ៦ច្បាប់ លើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមហើយនោះ ប៉ុន្តែឱ្យបានមុនថ្ងៃអនុសញ្ញានេះចូលជាធរមាន។ អនុសញ្ញានេះ ត្រូវជូនដំណឹងផងដែរ ដល់ភាគីនោះ ស្តីពីការបរិច្ឆេទលើការចូលជាធរមាននៃអនុសញ្ញា។

៣. ចំពោះភាគីមួយដែលធ្វើការផ្តល់សច្ចាប័ន និងការយល់ព្រមលើអនុសញ្ញានេះ ក្រោយពីការចូលជាធរមានរបស់ខ្លួន ដោយអនុលោមទៅតាមកថាខ័ណ្ឌទី១ របស់ភាគីនោះ ស្របតាមកាលបរិច្ឆេទនៃការដាក់ដំកល់ទុកនូវឯកសារច្បាប់ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមហើយនោះ។

៤. អនុសញ្ញានេះត្រូវបានកែសម្រួល ឬក៏ធ្វើវិសោធនកម្មនៅពេលណាមួយតាមការយល់ព្រមជាលាយល័ក្ខអក្សរទៅវិញទៅមករបស់ភាគីទាំងឡាយ។ ការកែសម្រួល ឬក៏ការធ្វើវិសោធន៍កម្មទាំងនោះ ត្រូវចូលជាធរមានតាមកាលបរិច្ឆេទ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមកខាងលើដោយភាគីទាំងឡាយ ព្រមទាំងបង្កើតឡើងជាផ្នែកនៃអនុសញ្ញានេះ។

៥. ការកែសម្រួល ឬក៏ការធ្វើវិសោធនកម្មណាមួយ នឹងមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងឡាយដែលកើតមានឡើង ឬក៏ផ្អែកទៅលើរាល់បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមុនពេលការចូលជាធរមានលើការកែសម្រួល ឬក៏ការធ្វើវិសោធនកម្មខាងលើ។

**មាត្រា ២២**

**ការដកខ្លួន**

១. ភាគីណាមួយ អាចដកខ្លួនពីអនុសញ្ញានេះ នៅពេលណាមួយបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់ខ្លួន។

២. ការដកខ្លួននឹងត្រូវផ្តល់ដំណឹងតាមរយៈឯកសារច្បាប់មួយពីការដកខ្លួន ដាក់ជូនទៅអគ្គលេខាធិការអាស៊ាន។

៣. ការដកខ្លួននឹងមានសុពលភាពរយៈពេល១៨០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ាន បានទទួលលិខិតតូបករណ៍ ពីការសុំដកខ្លួន។

៤.អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីទាំងឡាយផ្សេងទៀតលើការដកខ្លួនរបស់ភាគីណាមួយ ។

**មាត្រា ២៣**

**ការចុះបញ្ជី**

អនុសញ្ញានេះត្រូវបានចុះបញ្ជីតាមរយៈអគ្គលេខាធិការអាស៊ាន ជូនទៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ដោយអនុលោមទៅតាមមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

បានធ្វើនៅក្នុងទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ ជាភាសាអង់គ្លេស។

បានចុះហត្ថលេខាដោយថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ានទាំង ១០ មានដូចខាងក្រោម:

ព្រះចៅស៊ុលតង់ HAJI HASSANAL BOLKIAH នៃប្រទេសប្រ៊ុយណេ ដារ៉ូស្សាឡឹម

សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

បណ្ឌិត SUSILO BAMBANG YUDHOYONO ប្រធានាធិបតី នៃសាធារណៈរដ្ឋឥណ្ឌូនេស៊ី

ឯកឧត្តម BOUASONE BOUPHAVANH នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម DATO'SERI ABDULLAH AHMAD BADAWI នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី

ឧត្តមសេនីយ៍ SOE WIN នាយករដ្ឋមន្ត្រី នៃសហភាពមីយ៉ាន់ម៉ារ

លោកជំទាវ GLORIA MACAPAGAL-ARROYO ប្រធានាធិបតី នៃសាធារណៈរដ្ឋហ្វីលីពីន

ឯកឧត្តម LEE HSIEN LOONG នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋសិង្ហបុរី

ឧត្តមសេនីយ៍ SURAYUD CHULANONT នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់

ឯកឧត្តម NGUYEN TAN DUNG នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម